សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មិថុនា ឆ្នាំ ២០១៩

# លីអាហូណា



**យើងគឺជាព្រះហស្ត របស់ព្រះអម្ចាស់ ទំព័រ ៨, ១២, ២០**

តើព្រះអាចប្រើ *អ្នក* តាមរបៀបណាខ្លះ ? ទំព័រ ២៨

ការជួយជ្រោមជ្រែងកុមារដែលគ្មានការគាំទ្រដំណឹងល្អនៅផ្ទះ ទំព័រ ៤០

សាសនាចក្រ
នៅទីនេះ

# ទីក្រុងថាស្សកូ ប្រទេសម៉ិកស៊ិក





រូបថតពី GETTY IMAGES

ទោះបីវាធ្លាប់ជាទីក្រុងមួយដែលសម្បូរប៉ាក់ ទីក្រុងថាស្សកូ ឌឺ អាឡាខុន ហ្គែរ៉ូ ប្រទេសម៉ិកស៊ិក ត្រូវបានគេស្គាល់ថា ជា *pueblos magicos* ( ទីក្រុងវេទមន្ត ) នាពេលបច្ចុប្បន្ននេះ មានកេរ្តិ៍ឈ្មោះដោយសារតែផលិតផលគ្រឿងអលង្ការប្រាក់របស់ទីក្រុងនេះ ស្ថាបត្យកម្មនៃអាណានិគមអេស្ប៉ាញ និង សម្រស់ដ៏ស្រស់បំព្រងនៃទីជនបទដែលព័ទ្ធជុំវិញទីក្រុងនេះ ។ ទីក្រុងនេះមានទីតាំងស្ថិតនៅភូមិសាស្ត្រដែលមានដីរដិបរដុប និងចំណោត ផ្លូវឆេតឆូត ។ កន្លែងប្រវត្តិសាស្ត្រដ៏សំខាន់របស់ទីក្រុងនេះគឺជាព្រះវិហារ សាន់តា ព្រីសស្កា សតវត្សរ៍ទី ១៨ ។

ទីក្រុងថាស្សកូក៏ជាទីតាំងនៃសាខាថាស្សកូនៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលជួបប្រជុំគ្នាជារៀងរាល់សប្តាហ៍នៅក្នុងអគារមួយនៅលើ *avenida de los Plateros* ( *វិថីស៊ីលវើរស្មីធ* ) ។ សាខានេះគឺជាសាខាមួយរបស់ស្តេក អ៊ីហ្គោឡា ម៉ិកស៊ិក គឺជាក្រុមជំនុំមួយនៃក្រុមជំនុំ ១៩៨៧ នៅក្នុងប្រទេសម៉ិកស៊ិក ជាកន្លែងដែលព្រះវិហារមានសមាជិកជាង ១.៤ លាននាក់ ៣៤ បេសកកម្ម និង ព្រះវិហារបរិសុទ្ធចំនួន ១៣ ។ ប្រទេសម៉ិកស៊ិកក៏ជាគ្រឹះស្ថាននៃមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាទីក្រុងម៉ិកស៊ិក ជា អិម. ធី. ស៊ី ធំបំផុតទីពីររបស់សាសនាចក្រ ។ មជ្ឈមណ្ឌលនេះអាចផ្តល់ទីស្នាក់អាស្រ័យដល់អ្នកផ្សព្វផ្សាយសាសនាជាង ១០០០ នាក់ក្នុងពេលបំពាក់បំប៉នម្តង ។

- សមាជិកប្រាំនាក់ដំបូងនៅប្រទេសម៉ិកស៊ិកបានទទួលបុណ្យជ្រមុជទឹកនៅឆ្នាំ ១៨៧៦ ។
- ប្រទេសម៉ិកស៊ិកគឺជាប្រទេសទីមួយនៅក្រៅសហរដ្ឋអាមេរិកដែលមានស្តេកចំនួន ១០០ ។
- ព្រះវិហារបរិសុទ្ធ ម៉ិកស៊ីកូ ស៊ីធី ម៉ិកស៊ិក គឺជាព្រះវិហារបរិសុទ្ធដំបូងគេត្រូវបានឧទ្ទិសឆ្លងនៅឆ្នាំ ១៩៨៣ ។ ព្រះវិហារបរិសុទ្ធថ្មីបំផុតដែលទើបបានឧទ្ទិសឆ្លងនៅឆ្នាំ ២០១៥ នោះគឺ ព្រះវិហារបរិសុទ្ធ ទីហ្វូណា ម៉ិចស៊ិក ។ ព្រះវិហារបរិសុទ្ធ ហ្វៀប្លា ម៉ិកស៊ិក ត្រូវបានប្រកាសកាលពីខែតុលា ឆ្នាំ ២០១៨ ។
- ពេលប្រធាន ហាវើដ ដបុលយូ ហឺនធើរ ( ១៩០៧–១៩៩៥ ) បានទៅទស្សនកិច្ចនៅប្រទេសម៉ិកស៊ិក ឆ្នាំ ១៩៩៤ នោះលោកបានបង្កើតស្តេក ខុនត្រេអាស ម៉ិកស៊ិក ស៊ីធី ដែលជាស្តេកទី ២០០០ របស់សាសនាចក្រ ។



# តើការងារបម្រើរបស់យើងអាចជួយមនុស្ស ដទៃឲ្យជាសះស្បើយដែរឬទេ ?

នៅថ្ងៃអាទិត្យមួយ ខ្ញុំកំពុងអង្គុយនៅក្នុងការប្រជុំសាក្រាម៉ង់ពិចារណាពេលខ្ញុំអានព្រះគម្ពីរខ្ញុំថា យើងត្រូវធ្វើកិច្ចការដែលព្រះអង្គសង្គ្រោះបានធ្វើ ( សូមមើល នីហ្វៃទី៣ ២៧:២១ ) ។ ខ្ញុំបានគិតតែឯងថា « តើកិច្ចការរបស់ព្រះគ្រីស្ទនៅលើផែនដីនេះមានអ្វីខ្លះ ? » ខ្ញុំបានគិតពីកិច្ចការសំខាន់ពីរ ៖ ការបម្រើ និងការព្យាបាល ។ ការបម្រើខ្ញុំអាចធ្វើបាន ប៉ុន្តែចុះការព្យាបាលវិញនោះ ?

គំនិតនៃការព្យាបាលនេះបានក្លាយជាអ្វីមួយដែលខ្ញុំបានពិចារណាជារឿយៗ ។ ខ្ញុំធ្លាប់បានទទួលការវះកាត់ ១៦ ដងមកហើយនៅក្នុងជីវិត ហើយខ្ញុំធ្លាប់ទទួលការជាសះស្បើយ *ច្រើន* ដងផងដែរ ! ប៉ុន្តែខ្ញុំឆ្ងល់ពីរបៀបដែលខ្ញុំអាចធ្វើដូចព្រះយេស៊ូវគ្រីស្ទ និងជួយមនុស្សដទៃឲ្យជាសះស្បើយ ។ ប្រាកដណាស់ ខ្ញុំគ្មានអំណាយនៃការព្យាបាលដូចទ្រង់មាននោះទេ ។ ដូច្នេះ តើទ្រង់សព្វព្រះទ័យឲ្យខ្ញុំធ្វើកិច្ចការនៃការព្យាបាលរបស់ទ្រង់នៅលើផែនដីនេះតាមរបៀបណា ? តើខ្ញុំអាច *ធ្វើ* អ្វីទៅ ?

ពេលខ្ញុំពិចារណាពីរបៀបដែលមនុស្សដទៃបានជួយខ្ញុំឲ្យជាសះស្បើយ នោះចិត្តខ្ញុំបានបើកឡើងទៅរកកិច្ចការដ៏អស្ចារ្យនៃការព្យាបាល—ការលួងលោម ការបម្រើ និងការងារបម្រើ—ដែលមនុស្សដទៃបានធ្វើដល់ខ្ញុំក្នុងជីវិតរបស់ខ្ញុំ ។ ជាមួយនឹងការផ្ដោតចិត្តទុកដាក់របស់យើងលើការងារបម្រើដល់មនុស្សដទៃតាមរបៀបដែលព្រះអង្គសង្គ្រោះធ្វើ នោះគំនិតនៃការជួយមនុស្សដទៃឲ្យជាសះស្បើយគឺជាគំនិតដ៏មានឥទ្ធិពលមួយ ។យើងទាំងអស់គ្នារងទុក្ខអំឡុងពេលជីវិតរមែងស្លាប់របស់យើងនៅលើផែនដីនេះ ។ ដូច្នេះមនុស្សជាច្រើនមានជំងឺខាងរាងកាយ ឬជំងឺផ្លូវចិត្ត ឬរងទុក្ខខាងវិញ្ញាណ ។ យើងទាំងអស់គ្នាត្រូវការការព្យាបាល ។ ដូចខ្ញុំបានពន្យល់នៅក្នុងអត្ថបទរបស់ខ្ញុំ ( ទំព័រ ២០ ) និងដូចអែលឌើរ នែល អិល អាន់ឌើរសិន បង្រៀននៅក្នុងអត្ថបទរបស់លោក ( ទំព័រ ១២ ) យើងទាំងអស់គ្នាអាចចូលរួមក្នុងការងារបម្រើ ដល់មនុស្សដទៃតាមរបៀបដែលនឹងជួយពួកគេឲ្យជាសះស្បើយ ។

ដោយស្មោះស្ម័គ្រ
មើរីលី បិយយ៉ាក



ការងារបម្រើគឺជាការមើលទៅមនុស្សដទៃដូចព្រះអង្គសង្គ្រោះទ្រង់ទតឃើញ
៨



ការងារបម្រើតាមមធ្យោបាយមួយកាន់តែបរិសុទ្ធ
*អែលឌើរ នែល អិល អាន់ឌើរសិន*
១២



ការជួយមនុស្សដទៃឲ្យទទួលការព្យាបាលរបស់ព្រះអម្ចាស់
*មើរីលី ប្រោន បិយយ៉ាក*
២០



ភាពជាសិស្សដែលបានដឹកនាំដោយព្រះ
*ប៊ីស្សព ឌីន អិម ដេវីស*
២៨

# មាតិកា


**៥ ការហៅរបស់ឪពុក** ⏱
សូមអានពីការបង្រៀនដ៏គួរឲ្យពេញចិត្តអំពីភាពជាឪពុកមកពីព្រះគម្ពីរ និងប្រសាសន៍របស់ពួកព្យាការី ។

**៦ ការបង្ហាញអំពីសេចក្ដីជំនឿ ៖**
រ៉ូជ្រីហ្គោ ឃ្វីនតានីលឡា—ទីក្រុង វ៉ាលប៉ាប៉សសូ ប្រទេសឈីលី ⏱

**៨ គោលការណ៍នៃការងារបម្រើ ៖**
ការងារបម្រើគឺជាការមើលទៅមនុស្សដទៃដូចព្រះអង្គសង្គ្រោះទ្រង់ទតឃើញ

**១២ ការងារបម្រើតាមមធ្យោបាយមួយកាន់តែបរិសុទ្ធ**
*ដោយអែលឌើរ នែល អិល អាន់ឌើរសិន*
ពេលអ្នកស្វែងរករបៀបដើម្បីផ្ដល់ការងារបម្រើ ព្រះនឹងដឹកនាំអ្នកទៅរកបុត្រា និងបុត្រីរបស់ទ្រង់ ។

**២០ ការជួយមនុស្សដទៃឲ្យទទួលការព្យាបាលរបស់ព្រះអម្ចាស់**
*ដោយ មេរីលី ប្រោន ឌូយ៉ាក*
រៀនអំពីរបៀបដែលយើងអាចជួយព្យាបាលអ្នកដែលរងទុក្ខ ។

**២៤ ពរជ័យនៃភាពខ្លួនទីពឹងខ្លួន ៖**
ផ្កា និង ស្ថេរភាពផ្នែកហិរញ្ញវត្ថុ ⏱
*ដោយ ម៉ែឆែល វ៉ល*

**២៦ មេរៀនមកពីព្រះគម្ពីរសញ្ញាថ្មី ៖**
ម៉ាថា និង ម៉ារា ⏱
*ដោយ កាមីលេ ហ្វូក អូស្ទុន*

**២៨ ភាពជាសិស្សដែលបានដឹកនាំដោយព្រះ**
*ដោយប៊ីស្សព ឌីន អិម ដេវីស*
ព្រះនឹងប្រទានការដឹកនាំដ៏ទេវភាពដល់អ្នក ពេលអ្នកព្យាយាមក្លាយជាសិស្សរបស់ទ្រង់ ។

**៣២ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ** ⏱
គ្រាមួយដ៏ច្បាស់លាស់ដែលបានផ្លាស់ប្ដូរជីវិតគាត់ ការដឹងថាគាត់បានក្លាយជាអ្នកផ្សព្វផ្សាយសាសនាតាំងពីយូរណាស់មកហើយ ដំណើរមួយដែលនាំឲ្យគាត់មកកាន់ព្រះវិហារ សុន្ទរកថាមួយដែលបានពង្រឹងទីបន្ទាល់របស់គាត់ ។

**៣៦ អ្វីដែលយើងជឿ ៖**
យើងជឿលើការបានល្អឥតខ្ចោះ—នៅក្នុងព្រះគ្រីស្ទ ⏱

**៣៨ គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង ៖**
ជីងចក់ ចង្រិត និងពេលវេលាជាមួយកូន ⏱
*ដោយ ណានស៊ី ថូម៉ាស*

**៤០ ការបង្រៀនយុវវ័យ និងកុមារតូចៗ ៖**
ពេលឪពុក ឬម្ដាយ ឬទាំងឪពុក និងម្ដាយពុំចូលរួមសាសនាចក្រ ⏱
*ដោយ ខាមែល នូវែល*


⏱ អំណានខ្លីៗ



**នៅលើក្របមុខ**
*ដោះលែង*
ដោយ ជេនីឌី ជេច ។

# កថាកណ្ឌ


យុវមជ្ឈិមវ័យ
## ៤២
**ពេលវេលាដើម្បីមានកូន** ចំនួនកូន និងរបៀបដោះស្រាយពេល **អ្វីៗកើតឡើងពុំដូចការគ្រោងទុក្ខ** គឺជាសំណួរមួយចំនួនដែលអ្នកអាចមានពេលអ្នក **ដាក់ផែនការសម្រាប់គ្រួសាររបស់អ្នក ។** សូមអានពីបទពិសោធន៍ផ្ទាល់ខ្លួន នៅក្នុងវគ្គពួកយុវមជ្ឈិមវ័យផ្សេងៗក្នុងខែនេះ ។



យុវវ័យ
## ៥១
រៀនដើម្បី **ដាក់គោលដៅប្រាកដប្រជា ស្វែងរកភាពសុខសាន្ត** តាមរយៈ ផែនការនៃសេចក្ដីសង្គ្រោះ ហើយឈប់ **ទទួលការរំខានពីឧបករណ៍អេឡិចត្រូនិច** នៅក្នុងអត្ថបទខែនេះ ។







កុមារ
រៀនរបៀប **រាប់អានមិត្តភក្ដិថ្មី** និងជួយមិត្តភក្ដិចាស់ ។ រៀនបន្ថែមទៀតអំពី **ព្រះវិញ្ញាណបរិសុទ្ធ ។** ហើយមើលថា មានអ្វីបានកើតឡើងពេលអែលឌើរឃុក ធ្វើទស្សនកិច្ចនៅប្រទេសប្រេស៊ីល ។




## អត្ថបទដែលមានលក្ខណៈសម្រាប់តែឌីជីថលប៉ុណ្ណោះ



### ទីបំផុតបានទៅដល់ព្រះវិហារបរិសុទ្ធ

*ដោយ រ៉ាម៉ូណា ម៉ូរីស*

យុវមជ្ឈិមវ័យម្នាក់មកពីបាបាដូស ចែកចាយរឿងរបស់គាត់អំពីការរៀបចំខ្លួន ហើយទីបំផុតអាចទៅព្រះវិហារបរិសុទ្ធបាន ។



រូបភាពមកពី GETTY IMAGES

### តើអ្នកកំពុងរៀនអ្វីថ្មីៗរៀងរាល់ថ្ងៃមែនទេ ?

*ដោយសេវាកម្មភាពខ្លួនទីពឹងខ្លួន*

ការរៀនអ្វីថ្មីៗមានប្រយោជន៍របស់វា រួមទាំងការការពារជំងឺស្វិតកោសិកាខួរក្បាល និងការធ្វើឲ្យសុខភាពខាងផ្លូវចិត្តល្អប្រសើរឡើង ។

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.lds.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- មើលមាតិកាមានតែឌីជីថលប៉ុណ្ណោះ ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្ដល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្តាប់អត្ថបទដែលអ្នកចូលចិត្ត ។

## សូមទាក់ទងមកយើងខ្ញុំ

សូមអ៊ីម៉ែលសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ldschurch.org ។

សូមបញ្ជូនរឿងដែលជំរុញឲ្យមានសេចក្ដីជំនឿទាំងឡាយរបស់អ្នកទៅអ៊ីម៉ែល liahona.lds.org ឬផ្ញើសំបុត្រទៅកាន់ ៖
*Liahona,* flr. 23
50 E. North Temple Street
Salt Lake City, UT 84150-0023, USA

**ខែ មិថុនា ឆ្នាំ ២០១៩ វ៉ុល ១៨ លេខ ៣**
**លីអាហូណា ១៨៦០៦ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់, ជើរិត ដបុលយូ ហ្គង, អូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** រ៉ាន់ឌី ឌី ហ្វាំង

**អ្នកប្រឹក្សា ៖** ប្រាយអែន ខេ អាស្តុន, រ៉ានដល ខេ បិនណែត, ប៊ែកឃី ក្រាវិន, ស្សារ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រាន់កូ, ដូណាល់ អិល ហលស្ត្រម, ឡារី អេស ខាឈើរ, អ៊ីរិក ដបុយូ កូពីឆ្កេ, លីន ជី រ៉ូប៊ីន

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** កាមីឡា ខាស្ត្រីលលុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ឌែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ៊ីតុន, ហ្គាប៉ែត អេច ហ្គាហ្វ, ឡារី ហ្វូលើរ សូសា, ចន រ៉ាយអិន ជិនសិន, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ឺដុក, សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនយូហ៊្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាកខែល វូដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដសិន

**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន

**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនឌ្លី, ស៊ី ឃីមបឺល បុត, ថូម៉ាស ឆាល, ចូស្វ៊ា ដេននីស ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្គីន, ស្កត អិម ម៉ូយ, អ៊ីមីលី ផៀកូ ប៉មីងតុន, ម៉ាក ដ័បុលយូ រ៉ូប៊ីសុន, ប្រាត ផៀរ, យេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍

**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វែន អាឌៀ, ជូលី ប៊ីដេត, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដ័បុលយូ ហ្គីជី, ជីននី ជេ នីលសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ជី លើវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែត នៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែល ទៅកាន់ liahona@ldschurch.org ឬ តាម សំបុត្រទៅកាន់ *Liahona,* Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150–0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© 2019 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** June 2019 Vol. 18 No. 3. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.50 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

**POSTMASTER:** Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



« ការហៅរបស់ឪពុកគឺជាការហៅអស់កល្ប
ហើយសារៈសំខាន់របស់វាគឺលើសពីពេលវេលាទៅទៀត » ។

*Teachings of Presidents of the Church: Ezra Taft Benson* ( ឆ្នាំ ២០១៤ ) ទំព័រ ១៩៤ ។

## ការបង្រៀនមួយចំនួនដែលជាទីពេញចិត្តរបស់យើងអំពីភាពជាឪពុក

ពេលអ្នកត្រូវការការលើកទឹកចិត្ត សូមមើលសារលិខិតមួយនៃសារលិខិតទាំងនេះ ៖

- លូកា ១៥:២០–២៤
- ឌី ថត គ្រីស្តូហ្វឺសិន « ឪពុក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ៩៣–៩៧ ។
- អិល ថម ភែរី « Fatherhood, an Eternal Calling » *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៦៩–៧២ ។
- « The Sacred Callings of Fathers and Mothers » ជំពូកទី ១៥ នៅក្នុង *Teachings of Presidents of the Church: Ezra Taft Benson* ។
- « Love at Home » ជំពូកទី ១៤ នៅក្នុង *Teachings of Presidents of the Church: Harold B. Lee* ( ឆ្នាំ ២០០០ ) ។

រូបថតយកពី GETTY IMAGES

# រ៉ូដ្រីហ្គោ ឃ្វីនតានីលឡា

*ទីក្រុង វ៉ាលប៉ារ៉ៃសូ ប្រទេសឈីលី*



*នៅពេលគ្រោះថ្នាក់ដោយការសាងសង់មួយបានបន្សល់ទុកឲ្យគាត់ពុំអាចដើរបាន រ៉ូដ្រីហ្គោ ឃ្វីនតានីលឡាពុំអាចធ្វើជាជាងផ្សារដែកតទៅទៀតទេ—ឬធ្វើកិច្ចការជាច្រើនផ្សេងទៀតបានឡើយ ។ ប៉ុន្តែគាត់បានសម្រេចចិត្តបន្តឆ្ពោះទៅមុខដោយសេចក្ដីជំនឿ ដោយទុកចិត្តលើផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់គាត់ និងគ្រួសារគាត់ ។*

**ឡេសលី នីលសុន ជាងថតរូប**

ពេលមានអ្វីពិតជាអាក្រក់កើតឡើងចំពោះយើង យើងអាចមានប្រតិកម្មពីរបៀប ។ យើងអាចខឹងសម្បារនឹងព្រះ ហើយចាកចេញពីព្រះវិហារ ដោយគ្មានអ្វីទៀតនឹងបន្តវាទេ ។ ឬយើងអាចលុតជង្គង់ចុះ អធិស្ឋាន ហើយបន្តរីកចម្រើន ។

ខ្ញុំពុំបាត់បង់សេចក្ដីជំនឿរបស់ខ្ញុំទេ ហើយខ្ញុំក៏ពុំបានសួរខ្លួនខ្ញុំថា « ហេតុអ្វីរឿងនេះកើតឡើងចំពោះខ្ញុំដែរ ? » ខ្ញុំបដិសេធមិនដើរផ្លូវនោះឡើយ ។

ពេលការសាកល្បងមួយកើតឡើងចំពោះយើង ខ្ញុំដឹងថា ព្រះវរបិតាគង់នៅស្ថានសួគ៌ប្រទានផ្លូវមួយឲ្យឆ្លងកាត់ការសាកល្បងនោះ ។ ពេលខ្ញុំបានធូរស្បើយមកវិញ ការមានព្រះវិញ្ញាណបរិសុទ្ធគឺជារឿងសំខាន់ ។ ខ្ញុំត្រូវតែគិតពីអ្វីមួយទៀតដើម្បីធ្វើជាមុខរបរ ដូច្នេះខ្ញុំបានអធិស្ឋានទូលសូមការណែនាំពីព្រះវិញ្ញាណ ។ ព្រះបានឆ្លើយតបនឹងខ្ញុំ ។

ចំពោះអស់អ្នកដែលបានរងទុក្ខដោយគ្រោះថ្នាក់ ឬព្រឹត្តិការណ៍ដែលធ្វើឲ្យជីវិតផ្លាស់ប្ដូរ ខ្ញុំចង់និយាយថា « អ្វីៗអាចមានការលំបាក ប៉ុន្តែសូមបន្តនៅក្នុងសាសនាចក្រ ។ សូមបន្តនៅជាប់នឹងដំណឹងល្អ ។ ជីវិតកាន់តែលំបាកឡើងប្រសិនបើគ្មានដំណឹងល្អនោះ ។ សូមខិតខំឲ្យអស់ពីសមត្ថភាពរបស់អ្នក ហើយព្រះវរបិតាសួគ៌នឹងធ្វើកិច្ចការដែលនៅសេសសល់ » ។



## ស្វែងរកបន្ថែមទៀត

សូមស្វែងយល់ពីរបៀបដែល លីយ៉ូណែត ហ្គោហ្វ្រី ម៉ុកហ្គេលេ មកពីអាហ្វ្រិកខាងត្បូង បានទុកចិត្តព្រះ ហើយបានបន្តឆ្ពោះទៅមុខទាំងពិការនៅគេហទំព័រ **lds.org/go/៦១៩៦** ។

សូមរៀនបន្ថែមទៀតអំពីធនធានពិការភាពរបស់សាសនាចក្រនៅគេហទំព័រ **lds.org/go/៩១៨៤** ។

អ្នកអាចស្វែងរកការបង្ហាញអំពីសេចក្ដីជំនឿបន្ថែមទៀតនៅគេហទំព័រ **lds.org/go/១៨** ។



## គោលការណ៍នៃការងារបម្រើ

# ការងារបម្រើគឺជាការមើលទៅមនុស្សដទៃ ដូចព្រះអង្គសង្គ្រោះទ្រង់ទត

ព្រះយេស៊ូវបានចំណាយពេលរបស់ទ្រង់ជាច្រើន គង់នៅជាមួយអស់អ្នកដែលត្រូវបានគេមើលឃើញថាមានភាពខុសពីគេ ទ្រង់បានទតឃើញសក្ដានុពលនៃនិស្ស័យជាព្រះរបស់ពួកគេ ។

នៅក្នុងកិច្ចខិតខំដើម្បីផ្ដល់ការងារបម្រើរបស់យើងដូចព្រះអង្គសង្គ្រោះ យើងអាចត្រូវបានសុំឲ្យផ្ដល់ការងារបម្រើដល់អ្នកដែលមានលក្ខណៈប្លែកពីយើង ។ ការណ៍នេះតំណាងឲ្យឱកាសមួយសម្រាប់ឲ្យយើងរៀន និងរីកចម្រើន។

វប្បធម៌ ការអប់រំ ពូជសាសន៍ សេដ្ឋកិច្ច អាយុ ឥរិយាបថពីអតីតកាល និងបច្ចុប្បន្នកាល ឬភាពខុសប្លែកផ្សេងទៀត អាចធ្វើឲ្យយើងងាយនឹងវិនិច្ឆ័យបុគ្គលម្នាក់ពីមុនយើងស្គាល់ពួកគេទៅទៀត ។ ការវិនិច្ឆ័យជាមុននេះគឺជាផ្នែកដ៏ធំនៃការរើសអើង ហើយព្រះអង្គសង្គ្រោះបានព្រមានទាស់នឹងការវិនិច្ឆ័យបែបនេះ ( សូមមើល សាំយូអែលទី ១ ១៦:៧; យ៉ូហាន ៧:២៤ ) ។

តើយើងអាចមើលរំលងភាពខុសគ្នាទាំងនោះ ហើយមើលទៅមនុស្សដទៃដូចព្រះអង្គសង្គ្រោះទ្រង់ទតបានដែរឬទេ ? តើយើងអាចរៀនស្រឡាញ់មនុស្សដទៃ ទោះបីពួកគេជានរណា ហើយទោះបីពួកគេអាចក្លាយជាអ្វីក៏ដោយដោយរបៀបណា ?



រូបភាពចេញពី *CHRIST AND THE RICH YOUNG RULER* ដោយ ហែនរិច ហូហ្វម៉ាន់

## ការមើល និងសេចក្តីស្រឡាញ់

ព្រះគម្ពីរប៊ីបប្រាប់រឿងមួយពីកម្លោះអ្នកមាន ដែលបានសួរពីរបៀបដើម្បីទទួលបានជីវិតអស់កល្បជានិច្ច ៖ « ព្រះយេស៊ូវទ្រង់ទតទៅគាត់ ដោយស្រឡាញ់ ហើយមានព្រះបន្ទូលថា អ្នកនៅខ្វះកិច្ចមួយទៀត គឺត្រូវទៅលក់របស់ទ្រព្យអ្នកទាំងប៉ុន្មានចែកទានឲ្យដល់ពួកអ្នកក្រទៅ នោះអ្នកនឹងបានទ្រព្យសម្បត្តិនៅលើស្ថានសួគ៌វិញ រួចឲ្យផ្ទុកឈើឆ្កាងមកតាមខ្ញុំចុះ » ( ម៉ាកុស ១០:២១ ) ។

ពេលអែលឌើរ អេស ម៉ាក ផាលម៉ា ក្នុងពួកចិតសិបនាក់បានសិក្សាខគម្ពីរនេះកាលពីប៉ុន្មានឆ្នាំកន្លងទៅ ផ្នែកថ្មីមួយនៃរឿងនេះបានធ្វើឲ្យលោកចាប់អារម្មណ៍ភ្លាមៗ ។

« ‹ *ព្រះយេស៊ូវទ្រង់ទតទៅគាត់ដោយស្រឡាញ់* › ។

នៅពេលខ្ញុំឮពាក្យទាំងនេះ រូបភាពដ៏ច្បាស់លាស់មួយបានផុសឡើងក្នុងចិត្តខ្ញុំអំពីព្រះអម្ចាស់ ឈប់គង់មួយសន្ទុះ ហើយ *ទតទៅ* កម្លោះម្នាក់នោះ ។ *ទតទៅ*—គឺជាការទតមើលឲ្យស៊ីជម្រៅ និងទតមើលធ្លុះដល់ព្រលឹងកម្លោះនោះ ដោយទទួលស្គាល់សេចក្តីល្អសប្បុរសរបស់គាត់ ព្រមទាំងសក្តានុពលរបស់គាត់ ក៏ដូចជាការញែកដឹងពីតម្រូវការដ៏ធំធេងរបស់គាត់ ។

បន្ទាប់មកពាក្យសាមញ្ញនេះ—ព្រះយេស៊ូវ *ស្រឡាញ់គាត់* ។ ទ្រង់មានក្តីស្រឡាញ់ និងសេចក្តីអាណិតមេត្តាដ៏ច្រើនលើសលុបដល់កម្លោះល្អម្នាក់នេះ ហើយ *ដោយសារ* សេចក្តីស្រឡាញ់ និង *ជាមួយ* នឹងសេចក្តីស្រឡាញ់នេះព្រះយេស៊ូវបានសុំឲ្យគាត់ធ្វើកិច្ចការកាន់តែច្រើនបន្ថែមទៀត ។ ខ្ញុំបានស្រមៃមើលថា តើកម្លោះម្នាក់នេះមានអារម្មណ៍បែបណា ចំពោះសេចក្តីស្រឡាញ់ដ៏ខ្លាំងបែបនេះដែលគាត់បានទទួល ខណៈដែលត្រូវបានសុំឲ្យធ្វើកិច្ចការដ៏សែនលំបាក ដូចជាការលក់ទ្រព្យសម្បត្តិដែលគាត់មានទាំងអស់ ហើយចែកវាដល់អ្នកក្រ ។ . . .

[ ខ្ញុំបានសួរខ្លួនឯងថា ] ‹ តើខ្ញុំអាចបំពេញសេចក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទក្នុងចិត្តខ្ញុំតាមរបៀបណា ដើម្បីឲ្យ [ មនុស្សដទៃ ] អាចទទួលអារម្មណ៍នៃក្តីស្រឡាញ់របស់ព្រះតាមរយៈខ្ញុំ ហើយមានបំណងផ្លាស់ប្តូរនោះ ? › តើខ្ញុំអាច *មើល* [ បុគ្គលម្នាក់ៗដែលនៅជុំវិញខ្ញុំ ] ដូចព្រះអម្ចាស់បានទតមើលកម្លោះអ្នកមាននោះយ៉ាងដូចម្តេច ដោយការមើលថា តើពួកគេជាមនុស្សបែបណា ហើយពួកគេអាចប្រែទៅជាបែបណា ជាជាងការគ្រាន់តែមើលថា តើពួកគេធ្វើ ឬមិនធ្វើអ្វីខ្លះ ? តើខ្ញុំអាចប្រែកាន់តែដូចជាព្រះអង្គសង្គ្រោះបានតាមរបៀបណា ? »[១]

### ការរៀនដើម្បីមើលទៅមនុស្សដទៃ

ការរៀនដើម្បីមើលទៅមនុស្សដទៃដូចព្រះអង្គសង្គ្រោះទ្រង់ទត នាំមកនូវរង្វាន់ដ៏ច្រើនលើសលុប ។ នេះគឺជារបៀបមួយចំនួនដែលអាចជួយ ពេលយើងធ្វើកិច្ចការឆ្ពោះទៅកាន់គោលដៅនេះ ។

## ស្គាល់ពួកគេឲ្យច្បាស់

សូមព្យាយាមរៀនស្គាល់មនុស្សឲ្យច្រើនលើសពីសំបកក្រៅរបស់ពួកគេ ។ ទទួលស្គាល់ថា ការបង្កើតទំនាក់ទំនងត្រូវចំណាយពេល និងកិច្ចខិតខំដោយស្មោះសរ ។ ( សូមមើលអត្ថបទគោលការណ៍នៃការងារបម្រើខែសីហាឆ្នាំ ២០១៨ « ការបង្កើតទំនាក់ទំនងប្រកបដោយអត្ថន័យ » សម្រាប់ជាជំនួយ ) ។

## ពិនិត្យមើលខ្លួនឯង

សូមយកចិត្តទុកដាក់លើការវិនិច្ឆ័យដែលអ្នកអាចធ្វើដោយចេតនា ឬអចេតនា ។ សូមកត់ចំណាំពីការស្មាននានា ដែលអ្នកកំពុងមានអំពីមនុស្សដទៃ ហើយព្យាយាមយល់ពីមូលហេតុដែលអ្នកមានអារម្មណ៍បែបនោះចំពោះពួកគេ ។

## កុំវិនិច្ឆ័យគេ

ទទួលស្គាល់ថា កាលៈទេសៈពុំកំណត់ពីតម្លៃរបស់បុគ្គលម្នាក់ណាឡើយ ។ ព្យាយាមយល់ពីស្ថានភាពរបស់ពួកគេ និងពិចារណាពីរបៀបដែលអ្នកចង់ឲ្យនរណាម្នាក់យល់ពីអ្នក ប្រសិនបើអ្នកស្ថិតនៅក្នុងកាលៈទេសៈដូចគ្នានោះ ។ ការញែកចេញនូវជម្រើស និងឥរិយាបថរបស់នរណាម្នាក់ពីតម្លៃក្នុងខ្លួន និងសក្ដានុពលនៃភាពជាព្រះរបស់ពួកគេ អាចជួយយើងឲ្យមើលពួកគេដូចព្រះអង្គសង្គ្រោះទ្រង់ទត ។

## អធិស្ឋានដើម្បីស្រឡាញ់ពួកគេ

សូមអធិស្ឋានសម្រាប់ពួកគេជានិច្ចតាមឈ្មោះ និងអធិស្ឋានទូលសូមការអត់ធ្មត់ដើម្បីអភិវឌ្ឍមិត្តភាពដ៏ពិតប្រាកដមួយ ។ សូមក្រឡេកមើលការបម្រើរបស់អ្នកប្រកបដោយការអធិស្ឋាន ។ តើមានចន្លោះប្រហោងរវាងអ្វីដែលអ្នកកំពុងធ្វើ និងអ្វីដែលពួកគេពិតជាត្រូវការដែរឬទេ ?



ព្រះយេស៊ូវបានចំណាយពេលវេលារបស់ទ្រង់ជាមួយមនុស្សគ្រប់ប្រភេទ ៖ អ្នកមាន អ្នកក្រ អ្នកគ្រប់គ្រង និងមនុស្សសាមញ្ញ ។ ជារឿយៗ ទ្រង់គឺជាជនរងគ្រោះនៃការវិនិច្ឆ័យខុសពីមនុស្សដទៃ ពេលពួកគេមើលទៅទ្រង់ និងរូបរាងក្រីក្រ ឬកាលៈទេសៈមិនសំខាន់របស់ទ្រង់ ។ « ហើយកាលយើងបានមើលទ្រង់ នោះក៏គ្មានភាពលំអណា ដែលឲ្យយើងរីករាយចិត្តដែរ ។ . . . ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល » ( អេសាយ ៥៣:២–៣ ) ។

### ការអញ្ជើញឲ្យអនុវត្ត

តើអ្នកត្រូវមើលនរណាខ្លះក្នុងរបៀបផ្សេងពីមុន ? តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីផ្លាស់ប្ដូររបៀបដែលអ្នកមើលទៅពួកគេ ?

រូបភាពដកស្រង់ពី *ស្ត្រីដែលមានបាប* ដោយ ជេ ខឹក រីឆាដ

**សូមចែកចាយបទពិសោធន៍របស់អ្នក**
សូមផ្ញើមកកាន់យើងនូវបទពិសោធន៍របស់អ្នក នៅពេលអ្នកបានផ្ដល់ការងារបម្រើដល់មនុស្សដទៃ ឬទទួលបានការងារបម្រើ ។ សូមចូលទៅ liahona.lds.org ហើយចុចលើ « Submit an Article or Feedback » ។



## ទស្សនវិស័យដូចជាព្រះគ្រីស្ទ

បងស្រីម្នាក់ចែកចាយរឿងនេះអំពីការរៀនមើលអ្នកជិតខាងម្នាក់ដោយកែវភ្នែកដូចជាព្រះគ្រីស្ទ ៖

« ជូលៀ ( ឈ្មោះត្រូវបានផ្លាស់ប្ដូរ ) បានរស់នៅក្បែរខ្ញុំ ហើយហាក់ដូចជាគ្មានមិត្តភក្ដិណាទេ ។ គាត់មើលទៅដូចជាអន់ចិត្ត និងមានកំហឹងជានិច្ច ។ ទោះជាយ៉ាងនោះក្ដី ខ្ញុំបានសម្រេចចិត្តធ្វើជាមិត្តនឹងគាត់ ។ ពុំមែនគ្រាន់តែជាមិត្តភក្ដិធម្មតានោះទេ ប៉ុន្តែជាមិត្តដ៏ពិតម្នាក់ ។ ខ្ញុំបាននិយាយទៅកាន់គាត់ ពេលណាខ្ញុំបានឃើញគាត់ ហើយខ្ញុំបានបង្ហាញចំណាប់អារម្មណ៍លើអ្វីដែលគាត់កំពុងធ្វើ ។ ដោយសន្សឹមៗ ខ្ញុំបានបង្កើតមិត្តភាពដ៏ស្និតរមួតមួយជាមួយគាត់ ដែលធ្វើឲ្យចិត្តខ្ញុំមានអំណរ ។

នៅថ្ងៃមួយ ខ្ញុំបានសម្រេចចិត្តទៅសួរសុខទុក្ខជូលៀ ហើយសួរគាត់អំពីការសម្រេចចិត្តគាត់មិនចូលសាសនាចក្រ ។

ខ្ញុំបានដឹងថា គាត់គ្មានគ្រួសារ ឬសាច់ញាតិនៅក្បែរគាត់ឡើយ ។ បងប្អូនបង្កើតតែម្នាក់គត់របស់គាត់គឺប្អូនប្រុសរបស់គាត់រស់នៅឆ្ងាយណាស់ ប្អូនប្រុសគាត់ទាក់ទងមកគាត់មួយឆ្នាំតែម្ដងគត់តាមរយៈទូរសព្ទ ។ ពេលខ្ញុំស្ដាប់ការនិយាយពីភាពល្វីងជូរចត់ កំហឹង និងភាពស្មុគស្មាញអំពីគ្រួសារគាត់ និងសាសនាចក្រ នោះអារម្មណ៍នៃក្ដីអាណិតអាសូរដែលពុំអាចបដិសេធបាន និងសេចក្ដីស្រឡាញ់ចំពោះបងស្រីនេះបានស្ថិតមកលើខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំទទួលអារម្មណ៍ឈឺចាប់ និងភាពស្មុគស្មាញរបស់គាត់ ។ ខ្ញុំបានដឹងពីជីវិតដ៏ឯកោរបស់គាត់ ។ ខ្ញុំបានឮឃ្លាមួយពីក្រោយខ្ញុំថា ៖ ‹ យើងក៏ស្រឡាញ់គាត់ដែរ ។ ចូរស្រឡាញ់ និងគោរពគាត់ › ។

« ខ្ញុំបានអង្គុយ ហើយស្ដាប់រហូតដល់គាត់គ្មានអ្វីនិយាយទៀត ។ ខ្ញុំមានអារម្មណ៍នៃសេចក្ដីស្រឡាញ់ និងក្ដីអាណិតអាសូរដល់គាត់ ។ នេះគឺជាបងស្រីម្នាក់ដែលពុំធ្លាប់ដឹងថា តើអារម្មណ៍ដែលមានគេស្រឡាញ់នោះមានសភាពបែបណាឡើយ ។ រំពេចនោះ ខ្ញុំបានយល់ពីគាត់កាន់តែខ្លាំងឡើង ។ ខ្ញុំថ្លែងអំណរគុណគាត់ដែលបានអនុញ្ញាតឲ្យខ្ញុំទៅសួរសុខទុក្ខគាត់ ហើយខ្ញុំបានលាគាត់ដោយឱបគាត់ និងមានសេចក្ដីស្រឡាញ់ ព្រមទាំងគោរពគាត់ ។ គាត់នឹងពុំដឹងថា គាត់បានរំជួលចិត្តខ្ញុំប៉ុណ្ណាទេជាមួយនឹងការសួរសុខទុក្ខនោះ ។ ព្រះវរបិតាសួគ៌បានបើកភ្នែកខ្ញុំ ហើយបានបង្រៀនខ្ញុំថា ខ្ញុំមានសមត្ថភាពដើម្បីស្រឡាញ់ជាមួយនឹងការអាណិតអាសូរដែលបានកើនឡើង ។ ខ្ញុំបានប្ដេជ្ញាក្នុងចិត្តខ្ញុំថា ពុំគ្រាន់តែធ្វើជាមិត្តនឹងគាត់នោះទេ ខ្ញុំនឹងធ្វើជាគ្រួសាររបស់គាត់ផងដែរ » ។

វាគឺជារឿងពិសិដ្ឋមួយដើម្បីត្រូវបានអញ្ជើញឲ្យធ្វើជាផ្នែកមួយក្នុងជីវិតរបស់មនុស្សដទៃទៀត ។ ជាមួយនឹងការអធិស្ឋាន ការអត់ធ្មត់ និងជំនួយពីព្រះវិញ្ញាណ នោះយើងអាចរៀនធ្វើកិច្ចការនោះជាមួយនឹងទស្សនវិស័យកាន់តែដូចព្រះគ្រីស្ទ ។ ■

**កំណត់ចំណាំ**

១. អេស ម៉ាក ផាលមើរ « Then Jesus Beholding Him Loved Him » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១១៥ ។

**ស្វែងរកបន្ថែម**
រៀនបន្ថែមទៀតអំពីការស្វាគមន៍កាន់តែច្រើនឡើង ៖

- សូមអាន « យើងអាចធ្វើបានប្រសើរ ៖ ការស្វាគមន៍មនុស្សដទៃចូលមកក្នុងក្រុម » នៅក្នុង *លីអាហូណា* ខែ កញ្ញា ឆ្នាំ ២០១៧ ។
- មើលថ្នាក់ដឹកនាំសាសចក្រពន្យល់អំពីគោលការណ៍ទាំងនេះនៅគេហទំព័រ **lds.org/go/៦១៩១១ ។**







ដោយ អែលឌើរ នែល
អិល អាន់ឌើរសិន
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

# ការងារបម្រើ តាមមធ្យោបាយមួយ កាន់តែបរិសុទ្ធ

ខ្ញុំសូមសន្យាថា ពេលអ្នកស្រឡាញ់ព្រះដោយអស់ពីចិត្តអ្នក ហើយអធិស្ឋានទូលសូមធ្វើជាឧបករណ៍នៅក្នុងព្រះហស្តទ្រង់ នោះព្រះអម្ចាស់នឹងដាក់បុត្រាបុត្រីជាក់លាក់របស់ទ្រង់នៅលើផ្លូវរបស់អ្នក ។

សៀវភៅដែលមានចំណងជើងថា *The Narcissism Epidemic* ចាប់ផ្តើមដោយសរសេរនូវឧទាហរណ៍ពីការមិនពិតនៃវប្បធម៌សម័យទំនើបរបស់អាមេរិក ៖

« នៅក្នុងកម្មវិធីជីវិតពិតតាមទូរទស្សន៍មួយ ក្មេងស្រីម្នាក់គ្រោងធ្វើពិធីជប់លៀងខួបកំណើតគម្រប់ខួប ១៦ ឆ្នាំរបស់នាង ចង់ឲ្យបិទផ្លូវធំមួយ ដើម្បីឲ្យក្រុមដើរព្យុះហយាត្រាអាចដើរនាំមុខការមកដល់ដ៏ធំរបស់នាងនៅលើកម្រាលព្រំពណ៌ក្រហមមួយ ។ សៀវភៅមួយមានចំណងជើងថា *My Beautiful Mommy* ពន្យល់ពីការវះកាត់កែសម្ផស្សដល់កុមារតូចៗ ដែលម្តាយរបស់ពួកគេកំពុងទទួលការវះកាត់ដែលកំពុងពេញនិយម ‹ *Mommy Makeover* › ។ ឥឡូវនេះ គេអាចជួលអ្នកប្រមាញ់រូបថតក្លែងក្លាយ ដើម្បីធ្វើតាមរូបថតរបស់អ្នក ពេលអ្នកដើរលេងនៅពេលយប់—អ្នកថែមទាំងអាចយកគម្របទស្សនាវដ្តីក្លែងក្លាយរបស់ជនល្បីឈ្មោះដែលមានលក្ខណៈពិសេសនៃរូបថតទាំងនោះមកផ្ទះផងដែរ ។ ដោយមិនមែនជាការលេងសើច នោះចម្រៀងល្បីមួយថ្លែងថា ‹ ខ្ញុំជឿថា ពិភពលោកគួរតែវិលជុំវិញខ្ញុំ ! › . . . ក្មេងៗស្លៀកពាក់ខោអាវចាក់ដែលមានពាក្យ ‹ កំពូលម៉ូដ › . . . ហើយជញ្ជក់ក្បាលដោះជ័រ ‹ Bling › ( គ្រឿងអលង្ការ ) ខណៈដែលឪពុកម្តាយរបស់ពួកគេអានកំណាព្យចុងជូនថ្នាក់ទារកដ្ឋានទំនើបមកពី *This Little Piggy Went to Prada ( កូនជ្រូកតូចនេះបានទៅផ្សារ Prada)* » ។[១]

ក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ យើងបដិសេធជាខ្លាំងទៅនឹងគំនិតដែលថា ជីវិតរបស់យើងគឺធ្វើអ្វីៗទាំងអស់សម្រាប់តែខ្លួនយើង ។ ផ្ទុយទៅវិញ យើងធ្វើតាមព្រះអង្គសង្គ្រោះដែលមានបន្ទូលថា ៖

« អ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបម្រើដល់អ្នករាល់គ្នាវិញ

ហើយអ្នកណាក្នុងពួកអ្នកដែលចង់បានជាលេខមួយ អ្នកនោះត្រូវធ្វើជាបាវដល់អ្នករាល់គ្នាវិញដែរ ៖

. . . កូនមនុស្សបានមក មិនមែនឲ្យគេបម្រើលោកទេ គឺនឹងបម្រើគេវិញ ហើយនិងឲ្យជីវិតខ្លួន ទុកជាថ្លៃលោះមនុស្សជាច្រើនផង » ( ម៉ាថាយ ២០:២៦–២៨ ) ។



យើងផ្តល់តម្លៃដល់បន្ទូលរបស់ទ្រង់ ៖

« ឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ » ( យ៉ូហាន ១៣:៣៤ សូមមើលផងដែរ យ៉ូហាន ១៥:១២ ) ។

ចូរឲ្យចំណីដល់កូនចៀមខ្ញុំសីផង ។ . . . ចូរឲ្យចំណីដល់ចៀមខ្ញុំសីផង » ( យ៉ូហាន ២១:១៥, ១៦ ) ។

« កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចម្រើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង » ( លូកា ២២:៣២ ) ។

« ជួយអ្នកទន់ខ្សោយ លើកដៃដែលរោយ ហើយចម្រើនកម្លាំងដល់ក្បាលជង្គង់ដែលញ័រផង » ( គោលលទ្ធិ និង សេចក្តីសញ្ញា ៨១:៥ ) ។

នេះគឺជាឧទាហរណ៍មួយអំពីប្រភេទនៃការងារបម្រើដូចជាព្រះគ្រីស្ទ ដែលកើតឡើងក្នុងចំណោមសមាជិកសាសនាចក្ររបស់ព្រះអម្ចាស់ ។ ថ្មីៗនេះ និស្សិតសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ម្នាក់បានសរសេរថា ៖

« ខ្ញុំបានហែលឆ្លងកាត់នូវគ្រាដ៏លំបាកបំផុត ។ ថ្ងៃមួយ ខ្ញុំពិតជាស្មុគស្មាញខ្លាំងណាស់ ហើយខ្ញុំស្ទើរតែយំ ។ ខ្ញុំបានទូលអង្វរ ហើយអធិស្ឋានសូមកម្លាំងដើម្បីបន្តទៅមុខទៀត ។ នៅគ្រានោះ មិត្តរួមថ្នាក់របស់ខ្ញុំបានផ្ញើសារមួយដែលបង្ហាញពីសេចក្តីស្រឡាញ់របស់នាងចំពោះខ្ញុំ ។ គាត់បានចែកចាយខគម្ពីរមួយ ហើយថ្លែងទីបន្ទាល់ ។ វាបានធ្វើឲ្យខ្ញុំមានកម្លាំង និងការលួងលោមចិត្ត ព្រមទាំងមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងនៅគ្រានៃភាពអស់សង្ឃឹមនោះ » ។

ខ្ញុំសូមចែកចាយគំនិតមួយចំនួនដែលខ្ញុំសង្ឃឹមថា នឹងពង្រឹងដល់របៀបដ៏អស្ចារ្យ ដែលអ្នកផ្តល់ការងារបម្រើដល់គ្នាទៅវិញទៅមករួចទៅហើយនោះ ។ ចំណុចទីមួយរបស់ខ្ញុំគឺ ៖ ចូរចងចាំពីបទបញ្ញត្តិទីមួយ ពីមុនអ្នកអនុវត្តបទបញ្ញត្តិទីពីរ ។ យុវជនម្នាក់បានមកឯព្រះអង្គសង្គ្រោះ ហើយទូលសួរទ្រង់ថា ៖

« លោកគ្រូក្នុងបណ្តាក្រឹត្យវិន័យ តើបញ្ញត្តិណាដែលយ៉ាងសំខាន់បំផុត ?

នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។

នេះជាបញ្ញត្តយ៉ាងសំខាន់ទីមួយ ។

ហើយបញ្ញត្តទីពីរក៏បែបដូចគ្នាគឺថា ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ( ម៉ាថាយ ២២:៣៦–៣៩ ) ។

សមត្ថភាពរបស់អ្នកដើម្បីនាំយកវិធីកាន់តែបរិសុទ្ធនេះទៅដល់អ្នកជិតខាងជាទីស្រឡាញ់របស់អ្នក ដើម្បីមើលថែ និងផ្តល់ការងារបម្រើដល់មនុស្សដទៃ គឺផ្អែកយ៉ាងខ្លាំងទៅលើរបៀបដែលអ្នករក្សាបញ្ញត្តិទីមួយនោះឯង ។

## ការងារបម្រើមួយបែបទៀត

មានអំណោយទានដ៏ពិសេស និងមកពីព្រះស្តីពីការងារបម្រើ ដែលអាចកើតមកពីបុគ្គលម្នាក់ដែលស្រឡាញ់ព្រះដោយអស់ពីចិត្តរបស់គាត់ ជាអ្នកដែលមានលំនឹងមានការយល់ល្អពីជីវិត មានភាពខ្ជាប់ខ្ជួន និងនឹងននៅក្នុងសេចក្តីជំនឿរបស់គាត់លើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញ ( សូមមើល អេភេសូរ ៣:១៧; កូល៉ុស ១:២៣; នីហ្វៃទី ១ ២:១០; ម៉ូសាយ ៥:១៥; អាលម៉ា ១:២៥; នីហ្វៃទី ៣ ៦:១៤ ) និងអស់អ្នកដែលគោរពបទបញ្ញត្តិដោយឥតល្អៀង ។

ខ្ញុំសូមផ្តល់ដល់បងប្អូននូវបរិបទដែលបងប្អូនដឹងរួចហើយ ។ នៅទូទាំងពិភពលោក មនុស្សជំនាន់ក្រោយកំពុងបាត់បង់សេចក្តីជំនឿរបស់ពួកគេ ហើយជាពិសេសគឺជំនឿលើសាសនាជាក់លាក់ ។ កាលខ្ញុំរៀនចប់ពីសាកលវិទ្យាល័យ ប៊ី.វ៉ាយ.យូ. ក្នុងឆ្នាំ ១៩៧៥ ចំនួនយុវមជ្ឈិមវ័យ ( អាយុ ១៨ ដល់ ២៤ ឆ្នាំ ) ដែលបានដាក់បញ្ចូលឲ្យរៀនអំពីសាសនាមានជិតដល់ ៩០ ភាគរយ ។ ឥឡូវនេះវាមាននៅត្រឹមតែ ៦៦ ភាគរយប៉ុណ្ណោះ ។ « យុវមជ្ឈិមវ័យមួយភាគបីទាំងស្រុងពុំចូលរួមរៀននឹងសាសនាដែលបានរៀបចំឡើងណាមួយឡើយ » ។[២]

ក្នុងឆ្នាំ ២០០១ អ្នកប្រាជ្ញសាសនាឈ្មោះ រ៉ូបឺត ស៊ី ហ្វូលើរ បាននិពន្ធសៀវភៅមួយក្បាលមានចំណងជើងថា *Spiritual, But Not Religious* ។[៣] ទំនោរឆ្ពោះទៅរកភាពខាងវិញ្ញាណផ្ទាល់ខ្លួនខាងក្រៅអង្គការសាសនាជាផ្លូវការអាចជារឿងពិតកាលពី ២០ ឆ្នាំមុន ប៉ុន្តែវាពុំសូវពិតទេនៅពេលបច្ចុប្បន្ននេះ ។ យុវមជ្ឈិមវ័យនៅក្នុងសហរដ្ឋអាមេរិកសព្វថ្ងៃអធិស្ឋានមិនសូវញឹកញាប់ មិនសូវជឿលើព្រះ មិនសូវជឿលើព្រះគម្ពីរប៊ីប ហើយមិនសូវជឿលើបទបញ្ញត្តិឡើយ ។[៤] វាជារឿងល្ងង់ខ្លៅដើម្បីជឿថា ទំនោរនៃពិភពលោកពុំអាចជះឥទ្ធិពលលើយើងទាំងអស់គ្នាបានឡើយ—សូម្បីតែពួករើសតាំងក្តី ។

រូបថតពី GETTY IMAGES

ការមើលថែមនុស្សដទៃ ទាំងផ្លូវកាយ និងផ្លូវចិត្ត តម្រូវឲ្យមានចិត្តដែលមិនអាត្មានិយម និងមានការយល់ចិត្ត ។ ការមើលថែនេះជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ ។ វាត្រូវបានធ្វើឡើងទាំងក្នុង និងក្រៅសាសនាចក្រដោយពួកមនុស្សល្អ ទាំងអ្នកមានជំនឿ និងអ្នកគ្មានជំនឿ ។ មានមនុស្សមានសន្ដានចិត្តល្អប្រពៃជាច្រើននៅលើពិភពលោក ហើយយើងអាចរៀនពីពួកគេ ។

ប៉ុន្តែ ជាពិសេសចំពោះសមាជិកដែលជាអ្នកប្រែចិត្តជឿនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាការងារបម្រើមួយបែបទៀត ។ ក្នុងនាមជាសិស្សរបស់ព្រះអង្គសង្គ្រោះ យើងមានឱកាសផ្ដល់ការងារបម្រើតាមរបៀបមួយ ដែលជួយយើងរក្សាសេចក្ដីជំនឿរបស់មិត្តម្នាក់មិនឲ្យជំពប់ដួល ដែលរំឭកមិត្តរួមបន្ទប់តាមរបៀបមួយថា ការអានព្រះគម្ពីរមរមនរៀងរាល់ថ្ងៃពិតជានាំមកនូវអព្ភូតហេតុ ហើយដែលបង្ហាញសមាជិកវួដថា បទដ្ឋានរបស់សាសនាចក្រគឺពុំមែនគ្រាន់តែជាច្បាប់នោះទេ ប៉ុន្តែជារបៀបមួយដើម្បីរក្សាយើងឲ្យខិតជិតព្រះ ហើយនាំសុភមង្គលមកដល់យើង ។

មនុស្សម្នាក់ដែលមានចិត្តល្អអាចជួយមនុស្សម្នាក់ប៉ះកង់ឡាន នាំមិត្តរួមថ្នាក់ទៅជួបវេជ្ជបណ្ឌិត ទទួលទានអាហារថ្ងៃត្រង់ជាមួយនឹងមនុស្សម្នាក់ដែលសោកសៅ ឬញញឹម ហើយនិយាយពាក្យសួស្ដីដែលធ្វើឲ្យគាត់មានភាពរីករាយ ។ ប៉ុន្តែអ្នកដែលធ្វើតាមបទបញ្ញត្តិទីមួយនឹងបន្ថែមដោយឯកឯងទៅលើទង្វើនៃការបម្រើសំខាន់ទាំងនេះ ដោយលើកទឹកចិត្តអ្នកដែលកំពុងរក្សាបទបញ្ញត្តិបានល្អ ហើយចែកចាយការទូន្មានឆ្លាតវៃ ដើម្បីពង្រឹងសេចក្ដីជំនឿរបស់នរណាម្នាក់ ដែលកំពុងធ្លាក់ ឬអ្នកដែលត្រូវការជំនួយដើម្បីត្រឡប់មកដើរលើផ្លូវដែលធ្លាប់បានដើររួចមកហើយ ។

ខ្ញុំសូមអញ្ជើញអ្នកឲ្យពង្រឹងដល់កិច្ចខិតខំរបស់អ្នក ដើម្បីផ្ដល់ការងារបម្រើខាងវិញ្ញាណដល់គ្នាទៅវិញទៅមក ។ ដើម្បីផ្ដល់ការងារបម្រើខាងវិញ្ញាណ វាអាចចាប់ផ្ដើមជាមួយការដុតនំឃុកឃី ឬលេងកីឡាវាយកូនបាល់ ។ ប៉ុន្តែនៅទីបំផុត របៀបកាន់តែបរិសុទ្ធនៃការងារបម្រើនេះ តម្រូវឲ្យអ្នកបើកដួងចិត្ត និងជំនឿរបស់អ្នក ដោយក្លាហានក្នុងការលើកទឹកចិត្តឲ្យមានការរីកចម្រើនវិជ្ជមានមួយ ដែលអ្នកកំពុងឃើញនៅក្នុងមិត្តម្នាក់ និងការបង្ហាញកង្វល់អំពីអ្វីដែលអ្នកឃើញ ហើយទទួលអារម្មណ៍ថា មិនត្រូវនឹងភាពជាសិស្ស ។



ចូរយើងកុំធ្វើជាមនុស្សដែលមានភាពសុចរិតតែខ្លួនឯងឡើយ ប៉ុន្តែចូរយើងមានចិត្តក្លាហានខាងវិញ្ញាណក្នុងការផ្ដល់ការងារបម្រើតាមមធ្យោបាយមួយកាន់តែបរិសុទ្ធ ជាពិសេសតាមរយៈការពង្រឹងសេចក្ដីជំនឿរបស់មនុស្សដទៃ ។ ដើម្បីបំផុសគំនិតដល់អ្នក សូមពិចារណាពីស្ថានភាពដែលអាចកើតមាននេះ ៖

- អ្នកសង្កេតឃើញថា មិត្តរបស់អ្នកម្នាក់ចំណាយពេលច្រើនលើការលេងវីដេអូហ្គេមតាមទូរសព្ទ ប៉ុន្តែកម្រចូលរួមនិយាយគ្នាទាក់ទងនឹងប្រធានបទដំណឹងល្អណាស់ ។
- អ្នកដឹងថា សមាជិកវួដម្នាក់អាចមានបញ្ហាជាមួយនឹងការណ៍អាសគ្រាម ។
- មិត្តរបស់អ្នកចំណាយពេលយ៉ាងច្រើនដើម្បីថតរូប និងបង្ហោះរូបថតរបស់ពួកគេ ដែលជំរុញទៅរកការស្លៀកពាក់មិនសមរម្យ ។
- អ្នកសង្កេតឃើញថា មានបុគ្គលម្នាក់ដែលហាក់ដូចជាធ្លាប់ចូលចិត្តនិយាយអំពីព្រះគម្ពីរមរមនណាស់ តែឥឡូវនេះមិនដែលនិយាយពីវាសោះ ។
- អ្នកសង្កេតឃើញថា សមាជិកក្នុងគ្រួសារម្នាក់ហាក់ដូចជាចូលចិត្តទៅព្រះវិហារបរិសុទ្ធ តែឥឡូវនេះមិនទៅព្រះវិហារបរិសុទ្ធសោះ ។
- អ្នកសង្កេតឃើញថា មិត្តម្នាក់ហាក់ដូចជាធ្លាប់និយាយដោយសេចក្ដីជំនឿអំពីការទូន្មានរបស់ព្យាការី តែឥឡូវនេះបែរជានិយាយរិះគន់ព្យាការីទៅវិញ ។
- អ្នកស្គាល់អ្នកត្រឡប់ពីបេសកកម្មម្នាក់ដែលស្លៀកពាក់មិនសមរម្យដែលឆ្លុះបញ្ចាំងពីសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ ។
- អ្នកសង្កេតឃើញថា សមាជិកវួដម្នាក់ដោះសារដើម្បីទៅកន្លែងផ្សេងៗនៅថ្ងៃអាទិត្យ ជាជាងទៅព្រះវិហារ ។
- អ្នកដឹងថា មិត្តម្នាក់បានចាប់ផ្ដើមមិនទៀងត្រង់ក្នុងរឿងតូចតាច ។
- អ្នកស្គាល់មនុស្សម្នាក់ដែលមានភាពសប្បាយរីករាយបន្ទាប់ពីត្រឡប់មកពីបេសកកម្មវិញ ប៉ុន្តែឥឡូវនេះភាពរីករាយ

នោះវាបានរសាយបាត់ទៅ ។

- អ្នកមានមិត្តភក្តិម្នាក់ដែលយកកិច្ចការពិសិដ្ឋៗមកនិយាយលេងសើច ។
- អ្នកមានមិត្តម្នាក់ដែលបាក់ទឹកចិត្តដោយសារការណាត់ដើរលេងជាគូរ ហើយបានគិតថា « ព្រះពុំស្រឡាញ់ខ្ញុំទេ » ។
- អ្នកឃើញសេចក្ដីជំនឿរបស់មិត្តម្នាក់ទទួលរងឥទ្ធិពល ដោយសារការបាត់បង់នូវភាពស័ក្តិសម ហើយត្រូវតែប្រែចិត្ត ។

តើអ្នកអាចស្រមៃមើលឃើញពីស្ថានភាពទាំងនេះ ឬស្ថានភាពផ្សេងទៀតដូចនេះដែរឬទេ ? តើមានស្ថានភាពផ្សេងទៀតផុសក្នុងគំនិតរបស់អ្នកដែរឬទេ ? សាវកប៉ុលបានមានប្រសាសន៍ថា « យើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្ដីងងឹតនៅលោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដែរ » ( អេភេសូរ ៦:១២ ) ។ តម្រូវការដ៏អស្ចារ្យបំផុតមួយនៅទូទាំងពិភពលោកគឺ ត្រូវមានសេចក្ដីជំនឿកាន់តែច្រើនឡើងលើព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ និងការមានឆន្ទៈដើម្បីធ្វើតាមបទបញ្ញត្តិឲ្យកាន់តែប្រសើរឡើង ។

## ការងារបម្រើដល់បុគ្គលម្នាក់ៗ

ប្រសិនបើយើងធ្វើតាមលំនាំរបស់ព្រះអង្គសង្គ្រោះ នោះការងារបម្រើយើងភាគច្រើននឹងធ្វើឡើងចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ចំពោះស្ត្រីសាសន៍សាម៉ារីនៅឯអណ្ដូងទឹក ព្រះអង្គសង្គ្រោះបានបន្ទូលថា ៖

« អស់អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀត ៖

តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ ។ . . .

ស្ត្រីនោះក៏ទូលទ្រង់ថា លោកម្ចាស់អើយ សូមឲ្យទឹកនោះមកខ្ញុំផង ដើម្បីកុំឲ្យខ្ញុំស្រេក ។ . . .

[ បន្ទាប់មក ស្ត្រីនោះទូលថា ] ខ្ញុំដឹងហើយថា [ ព្រះ ] មែស៊ី ដែលហៅជាព្រះគ្រីស្ទ ទ្រង់នឹងយាងមក កាលណាមកហើយ នោះទ្រង់នឹងប្រាប់ឲ្យយើងខ្ញុំដឹងគ្រប់ទាំងអស់ ។

ព្រះយេស៊ូវមានព្រះបន្ទូលថា នោះគឺខ្ញុំនេះហើយ ដែលនិយាយនឹងនាង » ( សូមមើល យ៉ូហាន ៤:១៣–១៥, ២៥–២៦ ) ។

សូម្បីតែនៅក្នុងការប្រកាសអំពីភាពជាព្រះរបស់ទ្រង់ ព្រះយេស៊ូវបានប្រទានការងារបម្រើដល់បុគ្គលម្នាក់ៗ ។

ពុំដូចជាការដូរសំបកពោះវៀនកង់យានយន្តឡើយ ការផ្ដល់ការងារបម្រើតែម្ដង កម្រនឹងអាចព្យាបាលបញ្ហាខាងវិញ្ញាណបានណាស់ ។ វាត្រូវចំណាយពេលច្រើន ត្រូវនិយាយគ្នា និងបទពិសោធន៍លើកទឹកចិត្តនានា ដែលនឹងជួយស្ដាបនាសេចក្ដីជំនឿឡើងវិញ ។ វាកើតឡើងដោយសន្សឹមៗ ពុំមែនម្ដងទាំងអស់នោះទេ ។ អ្នកត្រូវផ្ដល់ការងារបម្រើម្ដងហើយម្ដងទៀត ពេលអ្នកជួយនរណាម្នាក់ឲ្យត្រឡប់មករកព្រះវិញ ហើយពឹងផ្អែកលើព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ម្ដងទៀត ។



ដើម្បីផ្ដល់ការងារបម្រើតាមរបៀបរបស់ព្រះអម្ចាស់ យើងត្រូវការជំនួយពីព្រះវិញ្ញាណបរិសុទ្ធ ។ ប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ប្រកបដោយអនុភាពស្ដីពីប្រធានបទនេះ អំឡុងពេលសន្និសីទទូទៅក្នុងខែមេសា ឆ្នាំ ២០១៨ ៖ « នៅពេលខាងមុខ វានឹងមិនអាចរស់រានខាងវិញ្ញាណបានឡើយ បើគ្មានព្រះចេស្ដាណែនាំ ដឹកនាំ និងលួងលោមចិត្តជាប់ជានិច្ចមកពីព្រះវិញ្ញាណបរិសុទ្ធនោះ » ។[៥]

ប្រធានណិលសុនបានបន្ថែមទៀតថា « ខ្ញុំសុំជំរុញចិត្តអ្នកឲ្យទៅហួសពីសមត្ថភាពខាងវិញ្ញាណបច្ចុប្បន្នរបស់អ្នកដើម្បីទទួលវិវរណៈផ្ទាល់ខ្លួន » ។[៦] លោកបានទូន្មានយើងឲ្យអធិស្ឋាន ស្ដាប់ កត់ត្រាគំនិតរបស់យើង ហើយធ្វើសកម្មភាព ។

តើយើងអាចអនុវត្តការណ៍នេះ នៅក្នុងមធ្យោបាយមួយកាន់តែបរិសុទ្ធដែរឬទេ ? ចូរយើងអធិស្ឋាន ស្ដាប់ កត់ត្រាគំនិតរបស់យើង ហើយធ្វើសកម្មភាពទាក់ទងនឹងអស់អ្នកដែលអ្នកអាចផ្ដល់ការងារបម្រើបាន ។

អធិស្ឋានទូលសូមឱកាសដើម្បីស្ដាបនាសេចក្ដីជំនឿនៅក្នុងមនុស្សដទៃ ។ មនុស្សដែលអ្នកជួយទាំងអស់នឹងពុំមែនជាមនុស្សដែលអ្នកស្គាល់នោះទេ ។ កាលព្រះយេស៊ូវបានផ្ដល់ការងារបម្រើដល់ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន នោះទ្រង់កំពុងតែធ្វើដំណើរយាងទៅទីក្រុងនោះប៉ុណ្ណោះ ។ ប៉ុន្តែ ទ្រង់បានឃើញនាង ក៏មានសេចក្ដីអាណិតអាសូរដល់នាង ហើយបានប្រោសកូនប្រុសនាងពីស្លាប់ឲ្យរស់វិញ ។ ការងារបម្រើរបស់ទ្រង់បានផ្លាស់ប្ដូរជីវិតនាង ( សូមមើល លូកា ៧:១១–១៥ ) ។

សូមអធិស្ឋានទូលសូមថា ឱកាសផ្ដល់ការងារបម្រើនឹងកើតឡើងដល់អ្នក សូម

ស្ដាប់ សូមកត់ត្រាគំនិតរបស់អ្នក ហើយបន្ទាប់មកត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើសកម្មភាព ពេលមានមនុស្សត្រូវបានដាក់មកលើផ្លូវរបស់អ្នក ។

ខ្ញុំមានការរំជួលចិត្តជានិច្ចដោយការអំពាវនាវរបស់អ្នកសរសេរទំនុកតម្កើងនេះ ៖ « សូមទតទៅខាងស្ដាំមើល . . . ដ្បិតគ្មានអ្នកណាស្គាល់ទូលបង្គំសោះ គ្រប់ទាំងទីពឹងបានបាត់ពីទូលបង្គំចេញហើយ ឥតមានអ្នកណា [ ទាំងបុរស និងស្ត្រី ] រវល់នឹងព្រលឹងទូលបង្គំឡើយ » ( ទំនុកតម្កើង ១៤២:៤ ) ។ ចូរជួយដល់អស់អ្នកដែលមានអារម្មណ៍បែបនេះ ។

## សូមទុកពេលឲ្យព្រះវិញ្ញាណ

ដើម្បីមានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ យើងត្រូវរៀបចំគំនិត និងដួងចិត្តរបស់យើង ។ នៅក្នុងជំនាន់របស់យើង យើងត្រូវមានវិន័យ និងភាពម្ចាស់ការលើខ្លួនឯង នៅក្នុងរបៀបដែលយើងប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យារបស់យើង ។ នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *Irresistible* អ័ដាម អាល់ធើរ បាននិយាយអំពីឥរិយាបថនៃការញៀនបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយសង្គម ។ គាត់បានស្រង់ពាក្យសម្ដីរបស់ ហ្គ្រេហ្គ ហុចមុត វិស្វករម្នាក់ដែលបង្កើត Instagram បានថ្លែងថា « មាន hashtag ផ្សេងមួយទៀតដើម្បីចុចមើលជានិច្ច ។ បន្ទាប់មក hashtag នោះដូចជាមានជីវិតរស់នៅ ដូចជាសរីរៈមួយ ហើយមនុស្សអាចគិតមមៃ » ។[៧]

លោក អាលធើរ បានបន្ថែមថា ៖ « Instagram ក៏ដូចជាកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមជាច្រើនផ្សេងទៀតដែរ គឺវាគ្មានទីបញ្ចប់ទេ ។ Facebook បញ្ចូលព័ត៌មានមិនចេះចប់ Netflix បន្តទៅរឿងវគ្គបន្ទាប់ទៀតជាស៊េរីដោយស្វ័យប្រវត្តិ Tinder ជំរុញឲ្យអ្នកប្រើប្រាស់បន្តចុចចុះឡើង ដើម្បីស្វែងរកជម្រើសកាន់តែប្រសើរ ។ . . . យោងតាម ទ្រីស្តាន ហារីស ‹ អ្នកប្រាជ្ញផ្នែករចនាប្លង់ › បញ្ហានោះពុំមែនមនុស្សខ្វះឆន្ទៈនោះទេ វាគឺថា ‹ មានមនុស្សមួយពាន់នាក់ដែលនៅផ្នែកម្ខាងទៀតនៃអេក្រង់នោះ មានមុខងារដើម្បីធ្វើឲ្យច្បាប់ផ្ទាល់ខ្លួនដែលអ្នកមាននោះបរាជ័យ › » ។[៨]

លោកអាលធើរបានបន្តទៀតថា ៖ « ការចូលចិត្តមួយនៅលើ Facebook និង Instagram ធ្វើឲ្យបុគ្គលនោះ [ មានអារម្មណ៍ល្អ ] ដូចទៅនឹងការផ្ដល់រង្វាន់នៃការបញ្ចប់បេសកកម្ម World of Warcraft ដែរ ឬការឃើញថា សារមួយនៅក្នុងកម្មវិធី Tweet របស់អ្នកមានអ្នកប្រើប្រាស់ Tweet រាប់រយនាក់បានចែកចាយសារនោះ ។ មនុស្សដែលបង្កើត និងធ្វើឲ្យបច្ចេកវិទ្យា ហ្គេម និងទំនាក់ទំនងបានប្រសើរឡើងគឺពូកែខាងផ្នែកដែលពួកគេធ្វើ ។ ពួកគេធ្វើការសាកល្បងជាមួយអ្នកប្រើប្រាស់រាប់លាននាក់ ដើម្បីដឹងថា តើកិច្ចការណាមួយដែលផ្លាស់ប្ដូរ និងមិនផ្លាស់ប្ដូរ—តើពណ៌ផ្ទៃខាងក្រោយ ម៉ូដអក្សរ និងសំឡេងណាមួយដែលធ្វើឲ្យមានអ្នកអានច្រើន និងបន្ថយភាពស្មុគស្មាញ ។ ពេលបទពិសោធន៍មួយកើតឡើង វាហួសពីការអត់ទ្រាំបាន មានប្រសិទ្ធភាពខ្លាំងជាងបទពិសោធន៍ដែលមានពីមុន ។ ក្នុងឆ្នាំ ២០០៤ Facebook គឺជាកម្សាន្តមួយ តែ [ សព្វថ្ងៃនេះ ] វាជាការញៀនហើយ » ។[៩]

ដើម្បីឲ្យព្រះវិញ្ញាណគង់នៅក្នុងយើង យើងត្រូវមានពេលវេលា និងទុកកន្លែងសម្រាប់ទ្រង់ ។ ចូររៀនទុកទូរសព្ទរបស់អ្នកមួយអន្លើ ។ ចូរដាក់កាលវិភាគដើម្បីប្រើបច្ចេកវិទ្យារបស់អ្នក ។

អំឡុងពេលសន្និសីទទូទៅក្នុងខែមេសាឆ្នាំ ២០១៨ ប្រធាន អិម. រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ៖ « មានមនុស្សជាច្រើនបណ្ដោយឲ្យខ្លួនពួកគេចំណាយពេលយ៉ាងច្រើនលើអ៊ិនធើណែតជាមួយឧបករណ៍ចល័តរបស់ពួកគេ—ជាអេក្រង់ដែលបំភ្លឺមុខពួកគេទាំងយប់ទាំងថ្ងៃ និងការដាក់កាសស្ដាប់នៅក្នុងត្រចៀកដែលរារាំងពួកគេមិនឲ្យឮសំឡេងតូចរហៀងរបស់ព្រះវិញ្ញាណ ។ បើយើងគ្មានពេលចេញឆ្ងាយពីឧបករណ៍ទាំងនោះទេ យើងអាចនឹងខកខាននូវឱកាសស្ដាប់ព្រះសូរសៀងរបស់ទ្រង់ដែលមានបន្ទូលថា ‹ ចូរបង្អង់សិន ហើយឲ្យបានដឹងថា យើងជាព្រះ › [ ទំនុកតម្កើង ៤៦:១០ ] ។ ឥឡូវនេះ ការទាញយកប្រយោជន៍ពីភាពជឿនលឿននៃបច្ចេកវិទ្យាដែលបំផុសគំនិតមកពីព្រះអម្ចាស់គឺមិនមែនជារឿងខុសឆ្គងទេ ប៉ុន្តែយើងត្រូវតែវៃឆ្លាតនៅក្នុងការប្រើប្រាស់វា » ។[១០]

## ពង្រឹងគ្នាទៅវិញទៅមក

អំឡុងពេលខ្ញុំបញ្ចប់ការសិក្សានៅ ប៊ី.វ៉ាយ.យូ. ក្រៅពីខាធីកិរិយារបស់ខ្ញុំ ដែលជាអ្នកមានឥទ្ធិពលអស់កល្បជានិច្ចដែលពុំអាចវាស់វែងបាន នោះមានមិត្តភក្ដិរួមបន្ទប់ពីរនាក់—ម្នាក់ជាមិត្ត



មុនបេសកកម្ម និងម្នាក់ទៀតជាមិត្តបន្ទាប់ពីបេសកកម្ម—បានសម្រួចសម្រាំងគ្រឹះខាងវិញ្ញាណរបស់ខ្ញុំយ៉ាងខ្លាំង ។ ម្នាក់ឈ្មោះ រៀដ រ៉ូប៊ីនសុន ឥឡូវនេះគឺជាសាស្ត្រាចារ្យនៅ ប៊ី.វ៉ាយ.យូ. នៅក្នុងផ្នែកទំនាក់ទំនងមនុស្ស ។ ខ្ញុំបានជួបគាត់ពេលបម្រើបេសកកម្ម ហើយក្រោយមកយើងបានក្លាយជាមិត្តភក្តិរួមបន្ទប់ជាមួយគ្នា ។ ការធ្វើតាមបទបញ្ញត្តិដ៏ឥតល្អៀងរបស់រៀដ សេចក្តីស្រឡាញ់របស់គាត់ចំពោះព្យាការី និងទីបន្ទាល់ដ៏រឹងមាំរបស់គាត់អំពីព្រះអង្គសង្គ្រោះ បានពង្រឹងខ្ញុំ និងអស់អ្នកដែលនៅជុំវិញគាត់ ។ ហើយគាត់បានបន្តធ្វើជាគំរូដល់ខ្ញុំអស់រយៈពេល ៤៥ ឆ្នាំកន្លងទៅនេះ ។

មិត្តភក្តិរួមបន្ទប់ម្នាក់ទៀតដែលខ្ញុំបាននិយាយនោះគឺ ធើររេ បើដ ដែលឥឡូវនេះរស់នៅទីក្រុង សេន ចច រដ្ឋ យូថាហ៍ ស.រ.អា. ។ ខ្ញុំបានជួបធើររេ ពេលយើងរៀននៅវិទ្យាល័យជាមួយគ្នានៅ ប៉ូកាតេឡូ រដ្ឋ អៃដាហូ ស.រ.អា ។ ទោះបីយើងលេងកីឡាវាយកូនបាល់ជាមួយគ្នាក្តី មិត្តភាពរបស់យើងបានកើតឡើង ពេលខ្ញុំបានសង្កេតមើលពីភាពចាស់ទុំខាងវិញ្ញាណរបស់គាត់ ។ គាត់បានចែកចាយការយល់ខាងវិញ្ញាណរបស់គាត់ដោយបើកចំហរនូវអ្វីដែលគាត់មាន និងគោលការណ៍នានានៃជីវិតដែលគាត់បានអាន និងបានរៀន ។ ខ្ញុំមានក្តីរំភើបដែលបានឮរឿងទាំងនេះពីក្មេងអាយុ ១៧ ឆ្នាំម្នាក់ ។ យើងបានសម្រេចចិត្តស្នាក់នៅបន្ទប់ជាមួយគ្នានៅ ប៊ី.វ៉ាយ.យូ. ។

កាលនៅជំនាន់នោះ យើងគ្មានកុំព្យូទ័រទេ ប៉ុន្តែយើងមានម៉ាស៊ីនវាយអង្គុលីលេខ ។ ធើររេបានយកខគម្ពីរដែលមានអត្ថន័យចំពោះគាត់ និងពាក្យដកស្រង់ដែលបណ្តុះឲ្យមានអត្តចរិតល្អវាយអង្គុលីលេខវា ហើយដាក់វានៅក្នុងប្រអប់តូចមួយ ដើម្បីគាត់អាចមើលវាបានញឹកញាប់ ។ វាជារឿងធម្មតាសម្រាប់គាត់ ដើម្បីមានខគម្ពីរ និងពាក្យសម្តីដកស្រង់ច្រើនជាងមួយពាន់ ដែលភាគច្រើនគាត់បានទន្ទេញវាចាំ ។ ទោះបីខ្ញុំនៅធ្វើការក្តី—សម្អាតបណ្ណាល័យរៀងរាល់ព្រឹកពីម៉ោង ៤ ដល់ម៉ោង ៧ ព្រឹក—ហើយត្រូវទៅរៀនជាច្រើនម៉ោងក្តី នោះខ្ញុំបានចាប់ផ្តើមធ្វើតាមធើររេដោយបង្កើតប្រអប់ឯកសារសម្រាប់ខ្លួនខ្ញុំផងដែរ ។

នេះគឺជាពាក្យដកស្រង់មួយដែលខ្ញុំនៅតែចាំទោះបីវាស្ទើរតែជិត ៥០ កន្លងទៅក្តី ៖

*គំនិតគឺជាមេអំណាចដែលចាក់ពុម្ព និងនាំឲ្យធ្វើកិច្ចការ ។*
*ហើយមនុស្សគឺជាគំនិត ហើយគាត់តែងតែយក*
*ឧបករណ៍នៃគំនិត ហើយសម្រួចសម្រាំងអ្វីដែលគាត់ចង់បាន*
*នាំមកនូវក្តីរីករាយមួយពាន់ រឿងអាក្រក់មួយពាន់ ៖—*
*គាត់គិតដោយសម្ងាត់ ហើយវាបានកើតឡើង ៖*
*បរិស្ថាននៅជុំវិញគាត់គឺគ្រាន់តែជាការឆ្លុះបញ្ចាំងពីអ្វីដែលគាត់គិតប៉ុណ្ណោះ ។*[១១]

ប្រាកដណាស់ ខ្ញុំក៏នៅចាំពីខគម្ពីរដ៏មានអនុភាពដូចខគម្ពីរមួយនេះផងដែរ ៖

« ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ ៖

ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ »
( យ៉ូហាន ១១:២៥–២៦ ) ។

ធើររេបានជួយខ្ញុំឲ្យដាក់ពាក្យនៃព្រះគម្ពីរ និងពាក្យសម្តីនៃប្រាជ្ញាវាងវៃនៅក្នុងចិត្តខ្ញុំ កាលខ្ញុំជានិស្សិតឆ្នាំទីមួយនៅ ប៊ី.វ៉ាយ.យូ. ដែលមានឥទ្ធិពលពេញមួយជីវិតខ្ញុំ ។ ខ្ញុំមានអំណរគុណចំពោះ រៀដ រ៉ូប៊ីសុន និង ធើររេ បើដ សម្រាប់ការមើលថែខ្ញុំខាងវិញ្ញាណនៅគ្រាមួយដ៏សំខាន់ ។

នេះគឺជាកំណាព្យមួយចំនួនដែលបាននិពន្ធដោយអ្នកជិតខាងខ្ញុំឈ្មោះ ថូម៉ាស អិល ខេ ៖

*សូមអរគុណព្រះដល់អស់អ្នកដែលផ្តល់ភាពធូរស្បើយ*
*សម្រាប់អស់អ្នកដែលខ្វាយខ្វល់ពិតប្រាកដ*
*អ្នកដែលឱបមនុស្សទន់ខ្សោយ*
*ហើយទូលអង្វរសម្រាប់ពួកគេនៅក្នុងការអធិស្ឋាន*
*សូមអរគុណព្រះដល់អស់អ្នកដែលយល់ចិត្ត*
*និងអ្នកដែលស្តាប់ពាក្យយើង*
*អ្នកដែលចេះអង្កេត ឬអ្នកមានទំនាក់ទំនងទន់ភ្លន់*
*មានន័យលើសពីអ្វីៗទាំងអស់លើពិភពលោកនេះ*





*សូមអរគុណព្រះដល់អស់អ្នកដែលលើកដៃដែលរោយ*
*និងចម្រើនកម្លាំងដល់ជង្គង់ដែលញ័រ*
*អ្នកដែលទៅចុះឡើងស្តារព្រលឹងមនុស្សឡើងវិញ*
*នៅក្នុងការបម្រើមួយដ៏ស្ងាត់ស្ងៀម ។*[១២]

មិត្តភក្តិ និងពួកសិស្សជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំសូមធ្វើជាសាក្សីយ៉ាងមុតមាំដល់អ្នកថា ខ្ញុំដឹងថាព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ។ ទ្រង់បានមានព្រះជន្មរស់ឡើងវិញ ។ ទ្រង់ដឹកនាំកិច្ចការដ៏បរិសុទ្ធរបស់ទ្រង់ ។ ប្រធានណិលសុនគឺជាព្យាការីរបស់ទ្រង់ដែលបានរើសតាំងឡើងនៅលើផែនដីនេះ ។ ពេលវេលារបស់យើងនៅលើផែនដីនេះគឺមានសារៈសំខាន់អស់កល្ប ។

ខ្ញុំសូមសន្យាថា ពេលអ្នកស្រឡាញ់ព្រះដោយអស់ពីចិត្តអ្នក អធិស្ឋានទូលសូមធ្វើជាឧបករណ៍នៅក្នុងព្រះហស្តទ្រង់ ផ្តល់ការងារបម្រើដល់បុគ្គលម្នាក់ៗ ស្តាបនាសមត្ថភាពរបស់អ្នកដើម្បីទទួលវិវរណៈ ហើយទុកចិត្តលើព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់នឹងដាក់បុត្រាបុត្រីជាក់លាក់របស់ទ្រង់នៅលើផ្លូវរបស់អ្នក ហើយអ្នកនឹងក្លាយជាពួកទេវតាដែលផ្តល់ការងារបម្រើរបស់ពួកគេ ដោយផ្តល់ពរដល់ជីវិតពួកគេអស់កល្បជានិច្ច ។ អ្នកនឹងផ្តល់ការងារបម្រើតាមមធ្យោបាយមួយកាន់តែបរិសុទ្ធ ។

ខ្ញុំអធិស្ឋានថា នេះគឺជារឿងសំខាន់មួយចំពោះអ្នក ពេលអ្នកបន្តដើរនៅលើផ្លូវដ៏សំខាន់នៃជីវិតរមែងស្លាប់របស់យើង ។ ខ្ញុំសូមផ្តល់ជាសាក្សីយ៉ាងមុតមាំ និងម៉ឺងម៉ាត់អំពីព្រះអង្គសង្គ្រោះ និងតម្លៃអស់កល្បជានិច្ចរបស់អ្នកចំពោះទ្រង់ ហើយទ្រង់នឹងយាងមកម្តងទៀត ហើយនឹងឱបយើងក្នុងនាមយើងជាបុត្រាបុត្រីរបស់ទ្រង់ និងជាសិស្សរបស់ទ្រង់ ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « A Holier Approach to Ministering » ដែលបានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ។*

**កំណត់ចំណាំ**


១. Jean M. Twenge និង W. Keith Campbell *The Narcissism Epidemic: Living in the Age of Entitlement* ( ឆ្នាំ ២០០៩ ) ទំព័រ ១ ។
២. Jean M. Twenge *iGen: Why Today's Super-Connected Kids Are Growing Up Less Rebellious, More Tolerant, Less Happy—and Completely Unprepared for Adulthood* ( ឆ្នាំ ២០១៧ ) ទំព័រ ១២១ សូមមើលរូបភាព ៥.១ ទំព័រ ១២១ ផងដែរ ។
៣. សូមមើល Robert C. Fuller *Spiritual, But Not Religious: Understanding Unchurched America* ( ឆ្នាំ ២០០១ ) ។
៤. សូមមើល Jean M. Twenge *iGen* ទំព័រ ១១៩–១៤២ ។
៥. រ័សុល អិម ណិលសុន « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៦ ។
៦. រ័សុល អិម ណិលសុន « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » ទំព័រ ៩៥ ។
៧. Greg Hochmuth នៅក្នុង Adam Alter *Irresistible: The Rise of Addictive Technology and the Business of Keeping Us Hooked* ( ឆ្នាំ ២០១៧ ) ទំព័រ ៣ សូមមើលផងដែរ Greg Hochmuth នៅក្នុង Natasha Singer « Can't Put Down Your Device? That's by Design » *The New York Times* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៥ គេហទំព័រ nytimes.com ។
៨. Adam Alter *Irresistible* ទំព័រ ៣ សូមមើលផងដែរ Tristan Harris នៅក្នុង Natasha Singer *« Can't Put Down Your Device? That's by Design »* ។
៩. Adam Alter *Irresistible* ទំព័រ ៥ ។
១០. អិម រ័សុល បាឡឺដ « អំណោយទានដ៏មានតម្លៃមកពីព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០ ។
១១. James Allen *As a Man Thinketh* ( ឆ្នាំ ១៩០២ ) frontispiece ។
១២. Thomas L. Kay *« Saints »* នៅក្នុង *The Road I've Taken* ( ឆ្នាំ ២០១៦ ) ទំព័រ ១៦ សូមមើលផងដែរ *« Saints »* តន្ត្រីដោយ Rachel Bastian *New Era* ខែ កញ្ញា ឆ្នាំ ១៩៩៩ ទំព័រ ៥១ ។



# ការជួយមនុស្សដទៃឲ្យទទួល ការព្យាបាលរបស់ព្រះអម្ចាស់

**ដោយ មេរីលី ប្រោន ឃូយ៉ាក**

នៅថ្ងៃអាទិត្យមួយខ្ញុំបានអានខគម្ពីរ « ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា នេះហើយជាដំណឹងល្អរបស់យើង ហើយអ្នករាល់គ្នាស្គាល់ការណ៍ទាំងឡាយ ដែលអ្នករាល់គ្នាត្រូវធ្វើនៅក្នុងសាសនាចក្ររបស់យើង *ដ្បិតកិច្ចការទាំងឡាយដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នករាល់គ្នាត្រូវធ្វើយ៉ាងនោះដែរ* » ( នីហ្វៃទី ៣ ២៧:២១ ការគូសបញ្ជាក់បានបន្ថែម ) ។

ខ្ញុំបានគិតតែឯងថា « តើកិច្ចការរបស់ព្រះគ្រីស្ទនៅលើផែនដីនេះមានអ្វីខ្លះ ? » ខ្ញុំបានគិតពីកិច្ចការសំខាន់ពីរ ៖ ការបម្រើ និងការព្យាបាល ។ ការបម្រើខ្ញុំអាចធ្វើបាន ប៉ុន្តែចុះការព្យាបាលវិញនោះ ? ប្រាកដណាស់ ខ្ញុំគ្មាន

សមត្ថភាពដើម្បីព្យាបាលមនុស្សដទៃ—ឬសូម្បីតែខ្លួនខ្ញុំឡើយ ?

ថ្មីៗនេះ ខ្ញុំកំពុងនៅទទួលការជាសះស្បើយពីការវះកាត់មួយ ដែលបានកើតឡើងដោយសារប្រតិកម្មអាលែកស៊ីធ្ងន់ធ្ងរ ។ រំភេចនោះ ខ្ញុំបានគិតអំពីមនុស្សដែលបានជួយខ្ញុំនៅក្នុងដំណើរការនៃការព្យាបាលរបស់ខ្ញុំ ហើយពួកគេមានច្រើននាក់ណាស់ ។ ប្រសិនបើពួកគេអាចជួយខ្ញុំឲ្យជាសះស្បើយបាន តើខ្ញុំពុំអាចធ្វើការណ៍នេះចំពោះមនុស្សដទៃទេឬ ?

> យើងអនុវត្តជំនាញនៃអង្គព្យាបាល ពេលយើងជួយនាំពរជ័យនៃការព្យាបាលរបស់ព្រះអម្ចាស់ ដល់អស់អ្នកដែលរងទុក្ខខាងរាងកាយ ផ្លូវចិត្ត និងជំងឺខាងវិញ្ញាណ ។

យើងម្នាក់ៗអាចរៀនពីជំនាញនៃអង្គព្យាបាលបាន ។[១] យើងមានមនុស្សជាច្រើនដែលរងទុក្ខដោយជំងឺខាងរូបកាយ សតិអារម្មណ៍ និងខាងវិញ្ញាណ ជាអ្នកដែលនឹងមានពរដោយសារជំនួយរបស់យើង ។

## ការសួរសុខទុក្ខអ្នកឈឺ

ម៉ូសាយ ៤:២៦ បានចែងថា « យើងចង់ឲ្យអ្នករាល់គ្នា ចែករំលែកនូវទ្រព្យរបស់ខ្លួន ដល់ អ្នកទាល់ក្រ មនុស្សម្នាក់ៗស្របតាមអ្វីដែលគេមាន ដូចជាឲ្យ អាហារដល់អ្នកអត់ឃ្លាន ឲ្យសំលៀកបំពាក់ដល់អ្នកអាក្រាត ទៅមើលអ្នកឈឺ ហើយជួយគាំទ្រដល់គេ ទាំងខាងវិញ្ញាណ និងខាងសាច់ឈាម ស្របទៅតាមសេចក្ដីត្រូវការរបស់គេ » ។

ការមានជំងឺ—ទោះខាងរូបកាយ ផ្លូវចិត្ត ឬខាងវិញ្ញាណក្ដី—អាចធ្វើឲ្យយើងមានអារម្មណ៍ឯកោ ។ មនុស្សចំណាយពេលជាច្រើនម៉ោងតែឯងនៅលើគ្រែដេក ឬនៅមន្ទីរពេទ្យ ដោយព្យាយាមទទួលការព្យាបាល ហើយវាងាយនឹងធ្វើឲ្យវិញ្ញាណរបស់ពួកគេទន់ខ្សោយ ។ ពេលមានក្ដីព្រួយបានកើនឡើង ការសួរសុខទុក្ខពីមិត្តភក្ដិដែលមានចិត្តខ្វាយខ្វល់ ឬពីសមាជិកគ្រួសារម្នាក់អាចនាំពន្លឺមកក្នុងជីវិតយើង ។

*របៀប* ដែលយើងសួរសុខទុក្ខអ្នកជំងឺក៏អាចជារឿងសំខាន់ផងដែរ ។ ស្ត្រីមួយចំនួនបានឆ្លើយតបនឹងសំណួររបស់ខ្ញុំ ដែលបានសួរអំពីរបៀបដែលមនុស្សដទៃបានជួយពួកគេឲ្យឆ្លងកាត់ដំណើរការនៃជាសះស្បើយ ។ ជូឌីមកពីរដ្ឋអារីហ្សូណា ស.រ.អា. បានថ្លែងថា « ការស្ដាប់ . . . [ គឺ ] ជាជំនួយមួយដ៏អស្ចារ្យនៅក្នុងគ្រាលំបាក ។ គឺការស្ដាប់ *ពុំមែន* ការវិនិច្ឆ័យនោះទេ » ។ ការស្ដាប់ដោយអត់ធ្មត់ ដោយស្មោះសរ និងដោយក្ដីស្រឡាញ់គឺជាការជួយជ្រោមជ្រែងដ៏មានតម្លៃ ដល់អស់អ្នកដែលកំពុងព្យាយាមឲ្យបានជាសះស្បើយ ។

លីដាមកពីរដ្ឋកាលីហ្វ័រញ៉ា ស.រ.អា. បានចែកចាយរបៀបដែលការសួរសុខទុក្ខរបស់មិត្តម្នាក់បានជួយគាត់ ៖ « ខ្ញុំចាំមនុស្សពិសេសទាំងនោះនៅក្នុងជីវិតខ្ញុំ—ជាពិសេសអស់អ្នកដែលពិតជាបានស្ដាប់ ហើយបានបង្ហាញឲ្យឃើញការទូន្មានដ៏ផ្អែមល្ហែមពីព្រះវិញ្ញាណ ។ បន្ទាប់ពីក្លាយជាស្ត្រីមេម៉ាយនៅវ័យ ៣០ ឆ្នាំ ដោយមានកូនប្រាំនាក់មក ខ្ញុំមានអារម្មណ៍ថា សេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទមានកាន់តែខ្លាំងឡើង ដោយសារមិត្តដ៏ល្អរបស់ខ្ញុំម្នាក់ឈ្មោះ ខារ៉ែន ។ គាត់ដឹងពីតម្រូវការខ្ញុំ ហើយគាត់ស្ដាប់ខ្ញុំជានិច្ច ។ ខ្ញុំពុំធ្លាប់មានអារម្មណ៍ឯកោឡើយ ពេលគាត់រំឭកខ្ញុំជាប់ជានិច្ចអំពីចំណងដ៏ល្អប្រពៃដែលខ្ញុំមាន ក្នុងនាមជាបុត្រីរបស់ព្រះ » ។

ជាពិសេសបងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើអាចធ្វើជំនាញនៃអង្គព្យាបាលនេះបាន ។ វាមានសារៈសំខាន់ ដើម្បីដឹងពីតម្រូវការរបស់អស់អ្នកដែលរងទុក្ខ ។ ជួនកាល ទៅសួរសុខទុក្ខខ្លីមួយដ៏សមរម្យ ដោយសារពួកគេនឿយហត់ ។ ជួនកាលពួកគេឯកោ ហើយអផ្សុក ដូច្នេះការទៅសួរទុក្ខរយៈពេលយូរនឹងបំពេញតម្រូវការរបស់ពួកគេ ។ វាក៏សំខាន់ផងដែរ ដើម្បីដឹងពីបុគ្គលិកលក្ខណៈរបស់ពួកគេ ។ អ្នកខ្លះចូលចិត្តភាពឯកជន និងភាពស្ងប់ស្ងាត់ ឯអ្នកផ្សេងទៀតចង់បានទំនាក់ទំនង និងការជួយជ្រោមជ្រែងច្រើន ។ ដំបូងយើងគួរកំណត់ពីតម្រូវការពួកគេសិន បន្ទាប់មកឈោងទៅជួយពួកគេតាមតម្រូវការនោះ ។

## ទទួលបន្ទុកគ្នាទៅវិញទៅមក

អាលម៉ាបានពិពណ៌នាយ៉ាងស្ទាត់ជំនាញ អំពីការតាំងចិត្តយើងដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ពេលលោកបានសួរពួកអ្នកជឿនៅក្នុងព្រះគម្ពីរមរមនប្រសិនបើពួកគេចង់ « ចូលរួមក្នុងក្រោលនៃព្រះ ហើយដើម្បីឲ្យបានហៅថា ជារាស្ត្ររបស់ទ្រង់ ហើយ [ យល់ ] ព្រមទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឲ្យបន្ទុកនោះបានស្រាល » ( ម៉ូសាយ ១៨:៨ ) ។



## យើងគឺជាព្រះហស្ដរបស់ព្រះអម្ចាស់

« ព្រះគ្រីស្ទជ្រាបពីរបៀបផ្ដល់ការងារបម្រើដល់មនុស្សដទៃបានយ៉ាងប្រពៃ ។ ពេលព្រះអង្គសង្គ្រោះឈោងព្រះហស្ដរបស់ទ្រង់ ជាលទ្ធផលអស់អ្នកដែលទ្រង់បានពាល់នឹងត្រូវបានលើកស្ទួយឡើង ហើយប្រែជាមនុស្សប្រសើរឡើង រឹងមាំឡើង និងល្អប្រសើរឡើង ។

« ប្រសិនបើយើងគឺជាព្រះហស្ដរបស់ទ្រង់ តើយើងមិនគួរធ្វើដូចគ្នាទេឬ ? »

អែលឌើរ ឌៀថើរ អេស្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « You Are My Hands » *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៧០ ។

យើងម្នាក់ៗរែកបន្ទុកច្រើនប្រភេទ ។ បន្ទុកទាំងនោះភាគច្រើនមានការលំបាកដើម្បីដោះស្រាយ ពេលយើងមានជំងឺ ឬមានជំងឺខាងផ្លូវចិត្ត ឬការលំបាកខាងវិញ្ញាណ ។ ជំនាញមួយនៃអង្គព្យាបាល គឺជួយរែកបន្ទុករបស់មនុស្សដទៃពេលពួកគេរងទុក្ខ ។

ស្យាណាន់មកពីរដ្ឋ យូថាហ៍ ស.រ.អា. បានចែកចាយរបៀបដែលអ្នកជិតខាងរបស់គាត់បានជួយគាត់ ៖ « នៅថ្ងៃដែលយើងបានកប់សពកូនប្រុសរបស់យើង យើងបានត្រឡប់មកពីទីកប់សពវិញ ដោយឃើញអ្នកជិតខាងយើងបានមកជួបជុំគ្នានៅប៉ុន្មានម៉ោងនោះ ដើម្បីរៀបចំទីធ្លារបស់យើងឲ្យបានស្រស់បំព្រងឡើងវិញទាំងស្រុង ខណៈយើងនៅពិធីបុណ្យសពកូនប្រុសខ្ញុំ ។ ពួកគេបានដាំគុម្ពឈើ ដើមឈើ និងផ្កា ហើយថែមទាំងដាំស្មៅថ្មីដ៏ស្រស់ស្អាតទៀតផង ។ នៅក្នុងក្ដីទុក្ខព្រួយដែលពុំអាចពិពណ៌នាបានរបស់យើង ការបង្ហាញសេចក្ដីស្រឡាញ់ និងការជួយជ្រោមជ្រែងដ៏ចេះគិតគូររបស់ពួកគេ បានចាប់ផ្ដើមដំណើរការនៃការព្យាបាលសម្រាប់យើង ។ យើងត្រូវបានរំឭកថាសេចក្ដីស្រឡាញ់ និងជីវិតគឺជាភាពអស់កល្បរៀងរាល់ឆ្នាំ ពេលទីធ្លាផ្ទះដ៏ស្រស់ស្អាតរបស់យើងបានត្រឡប់មករស់រានមានជីវិតវិញ ។ [ វាពិតជា ] បទពិសោធន៍មួយពិសិដ្ឋ និងជានិមិត្តរូបដែលយើងនឹងពុំភ្លេចវាទេ » ។

ពេលខ្ញុំត្រូវបានធ្វើរោគវិនិច្ឆ័យថា មានជំងឺមហារីកសុដន់ ខ្ញុំកំពុងបម្រើជាប្រធានសមាគមសង្គ្រោះ និងកំពុងធ្វើការសម្រាប់ការបោះឆ្នោតឡើងវិញនៅក្នុងក្រុមប្រឹក្សានៅទីក្រុងរបស់យើង ។ ស្វាមីខ្ញុំបានបាត់បង់ការងារ ហើយយើងបានជួបនឹងការសាកល្បងធ្ងន់ធ្ងរជាច្រើនទៀត អំឡុងគ្រានោះ ។ ទីប្រឹក្សារបស់ខ្ញុំបានសម្រេចចិត្តធ្វើតាមឃ្លា « រែកបន្ទុកគ្នាទៅវិញទៅមក » ដោយស្មោះសរ ហើយបានជួយរំលែកបន្ទុកដែលខ្ញុំកំពុងរែក ។ ប៊ីស្សពរបស់ខ្ញុំបានយកការទទួលខុសត្រូវមួយចំនួនរបស់ខ្ញុំ ។ ស្វាមីខ្ញុំបានយកកាតព្វកិច្ចជាច្រើនក្នុងការចម្អិនម្ហូប និងធ្វើការងារផ្ទះ ។ ខ្ញុំពិតជាបានឃើញដោយរាបសាថា បន្ទុករបស់ខ្ញុំពុំត្រូវបានដកយកចេញនោះទេ ប៉ុន្តែមានមនុស្សជាច្រើនបានជួយរែកបន្ទុកនោះ ជាអ្នកដែលបានអនុវត្តជំនាញនៃអង្គព្យាបាល ។

### ការលួងលោម

អាលម៉ាក៏បានបង្រៀនថា អ្នកដើរតាមព្រះគ្រីស្ទ « ព្រមទួញយំជាមួយនឹងអ្នកណាដែលទួញយំ មែនហើយ ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកម្សាន្តទុក » ( ម៉ូសាយ ១៨:៩ ) ។

ការផ្ដល់ការលួងលោមរួមមាន ក្ដីអាណិតអាសូរ សន្ដានចិត្តល្អ ចេះគិតគូរ ខ្វាយខ្វល់ ស្រឡាញ់ និងមានចិត្តសប្បុរស ។ វាជាការបង្ហាញក្ដីស្រឡាញ់ដល់អ្នកដែលឈឺ ឬរងទុក្ខដោយដៃនៃសេចក្ដីស្រឡាញ់ ដើម្បីជួយពួកគេប្រឈមមុខនឹងការរងទុក្ខរបស់ពួកគេ ។

ឡោន ( ឈ្មោះត្រូវបានផ្លាស់ប្ដូរ ) បានប្រឈមមុខនឹងការលំបាកខាងវិញ្ញាណ និងខាងសីលធម៌ ហើយបានសញ្ជឹងគិតពីបទពិសោធន៍របស់គាត់ជាមួយមនុស្សដទៃដែលបានលួងលោមគាត់ ៖ « ពួកគេបានមើលខ្ញុំហួសពីអ្វីដែលជាខ្ញុំក្នុងពេលបច្ចុប្បន្ននេះ ហើយបានឃើញពីសក្ដានុពលដែលបានសន្យារបស់ខ្ញុំ សក្ដានុពលដែលអាចក្លាយជាមនុស្សម្នាក់ដែលប្រសើរជាង ឆ្លាតជាង មានសន្ដានចិត្តល្អជាង ។ ខ្ញុំបានក្រឡេកមើលខ្លួនខ្ញុំកាលពីមុន ហើយជួនកាល មានអារម្មណ៍មិនល្អដោយមានភាពអាម៉ាស់បន្តិចបន្តួចពីភាពល្ងង់ខ្លៅរបស់ខ្ញុំ—ការខ្មាសអៀនបន្តិចបន្តួចចំពោះរបៀបនៃការរំលង និងអំពើបាបរបស់ខ្ញុំ ។ ប៉ុន្តែថ្នាំនៃការព្យាបាលដូចជា ព្រះគុណ សេចក្ដីមេត្តាករុណា ការអភ័យទោស និងសេចក្ដីស្រឡាញ់ តែងតែកើតឡើងបន្ទាប់ពីការឈឺចាប់នៃភាពអាម៉ាស់ និងការខ្មាសអៀន ។ ពេលខ្ញុំឃើញមានមនុស្សនៅជុំវិញខ្ញុំបង្ហាញអ្វីៗទាំងនោះដល់ខ្ញុំ នោះការឈឺចាប់នោះបានរសាត់ចេញទៅ ។ ហើយខ្ញុំឃើញពួកគេកំពុងជួយខ្ញុំឲ្យបានជាសះស្បើយ ។ ប្រហែលវាត្រឹមត្រូវជាងដើម្បីនិយាយថា ពួកគេបានបង្កើតបរិយាកាសសុវត្ថិភាពមួយនៅជុំវិញខ្ញុំ—ប្រហែលវាជាសសៃស្វត្រនៃព្រះគុណ—ដែលនៅក្នុងព្រះអង្គសង្គ្រោះជាអង្គព្យាបាលដ៏កំពូលអាចព្យាបាលខ្ញុំបាន ។ ផ្លាស់ប្ដូរខ្ញុំ ។ ផ្លាស់ប្ដូរចិត្តខ្ញុំ » ។

> « ពួកគេបានបង្កើតបរិយាកាសសុវត្ថិភាពមួយនៅជុំវិញខ្ញុំ ដែលព្រះអង្គសង្គ្រោះជាអង្គព្យាបាលដ៏កំពូលអាចព្យាបាលខ្ញុំបាន » ។

ផ្នែកសំខាន់មួយនៃការលួងលោមអ្នកឈឺគឺ បង្វែរពួកគេទៅរកអង្គព្យាបាលដ៏កំពូល ។ សាព្រីណាមកពីរដ្ឋយូថាហ៍បាននិយាយថា « គ្មានការព្យាបាលណាប្រសើរជាងនរណាម្នាក់ដែលជួយអ្នកឲ្យដឹងពីតម្រូវការ ឬត្រឡប់ទៅកាន់ព្រះវិញឡើយ ។ វាអាចជាការរំឭកអំពីអ្វីដែលអ្នកដឹងរួចហើយ—



ថាអ្នកកំពុងតែព្យាយាមខ្លាំងឡើងជាងដែលអ្នកត្រូវធ្វើ ធ្វើអ្វីៗតែម្នាក់ឯង ហើយពុំពឹងផ្អែកពិតប្រាកដលើព្រះ » ។

ការលួងលោមអ្នកឈឺ និងការជួយពួកគេឲ្យមានភាពវិជ្ជមាន តម្រូវឲ្យមានការស្ដាប់ព្រះវិញ្ញាណ ។ នៅក្នុងគ្រាមួយនៃជីវិតខ្ញុំ ខ្ញុំពុំបានដេកលក់ស្កប់ស្កល់អស់រយៈពេលជាច្រើនខែជាទូទៅខ្ញុំដេកបានតែពីរបីម៉ោងប៉ុណ្ណោះរៀងរាល់យប់ ដោយការដេកពុំស្កប់ ។ ខ្ញុំមានជំងឺថប់បារម្ភ និងនឿយហត់ធ្ងន់ធ្ងរ ហើយខ្ញុំបានជួបនឹងវេជ្ជបណ្ឌិតជាច្រើនរូប ប៉ុន្តែវាគ្មានប្រយោជន៍អ្វីឡើយ ។ ទីបំផុត មិត្តភក្ដិម្នាក់របស់ខ្ញុំបានណែនាំខ្ញុំឲ្យជួបវេជ្ជបណ្ឌិលពួកបរិសុទ្ធថ្ងៃចុងក្រោយដែលវេជ្ជបណ្ឌិតរូបនោះបានធ្វើរោគវិនិច្ឆ័យត្រឹមត្រូវមួយដល់ខ្ញុំ ។ ប៉ុន្តែអ្វីដែលគាត់បាននិយាយបន្ទាប់នោះគួរឲ្យភ្ញាក់ផ្អើល ៖ « មើរីលីរឿងដ៏សំខាន់បំផុតមួយដែលអ្នកត្រូវធ្វើនោះគឺបង្វែរការថប់បារម្ភរបស់អ្នកទៅកាន់ព្រះ » ។ បន្ទាប់មកគាត់បានលើកទឹកចិត្តខ្ញុំឲ្យពិចារណារៀងរាល់ថ្ងៃអស់មួយរយៈពេលខ្លីស្ដីពី « ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក » ។

ខ្ញុំបានព្យាយាមពិចារណាពីរបីដងដោយគ្មានជោគជ័យ ប៉ុន្តែខ្ញុំត្រូវការការព្យាបាលជាខ្លាំង ។ នៅថ្ងៃបន្ទាប់មក ខ្ញុំបានពិចារណាដោយស្ងាត់ស្ងៀមអំពីពាក្យដ៏មានអនុភាព « យើងសូមថ្វាយនូវទីបន្ទាល់របស់យើង អំពីសគុណភាពនៃការបូជាដ៏មហិមារបស់ទ្រង់ដែលធួននឹងបាប » ។[២] ខ្ញុំមានអារម្មណ៍រំជួលចិត្ត ពេលខ្ញុំបានចាប់ផ្ដើមពិចារណាអំពីទីបន្ទាល់របស់អង្គព្យាបាលដ៏កំពូល ហើយបានដឹងថា ខ្ញុំបានរកឃើញការលួងលោម និងភាពសុខសាន្តក្នុងព្រលឹងខ្ញុំ ។

## ការយកចិត្តទុកដាក់

ពេលយើងសិក្សាព្រះគម្ពីរដើម្បីធ្វើតាមព្រះយេស៊ូវនៅក្នុងកិច្ចការនៃការព្យាបាលរបស់ទ្រង់ នោះយើងអានអំពីព្រះយេស៊ូវធ្វើកិច្ចការមួយម្ដងហើយម្ដងទៀត ៖ ទ្រង់បានយកព្រះទ័យទុកដាក់ដល់មនុស្សដែលនៅជុំវិញទ្រង់ ។

ព្រះគ្រីស្ទសង្កេតមើលមនុស្ស ។ ទ្រង់មានបន្ទូលជាមួយស្ត្រីសាសន៍សាម៉ារី ទោះបីមានការហាមឃាត់ខាងវប្បធម៌ក្ដី ។ ទ្រង់ចំណាយពេលដើម្បីប្រសិទ្ធពរកុមារ ។ ទ្រង់បានសោយអាហារជាមួយអ្នកយកពន្ធនិងមនុស្សមានបាប ព្រមទាំងបានផ្ដល់ការងារបម្រើដល់មនុស្សឃ្លង់និងមនុស្សដែលគេនិរទេសចោល ។ ទ្រង់បានយកព្រះទ័យទុកដាក់ដល់បុគ្គលម្នាក់ៗ ។

ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទដោយព្យាយាមរៀនពីជំនាញនៃការព្យាបាលរបស់ទ្រង់ យើងអាចចាប់ផ្ដើមមើលទៅមនុស្សដោយព្រះនេត្ររបស់ព្រះគ្រីស្ទ ។ យើងអាចចំណាយពេលនិយាយសួស្ដីញញឹម ហើយសួរសុខទុក្ខពួកគេ ។ យើងពុំអាចដឹងឡើយថា ឱសថព្យាបាលដែលយើងបានខិតខំធ្វើអាចមានដល់មនុស្សជុំវិញខ្លួនយើងជាបុគ្គលដែលឯកោ បាក់ទឹកចិត្ត ឈឺ ទន់ខ្សោយ ឬរងទុក្ខ ។ សូម្បីតែទង្វើនៃសេចក្ដីស្រឡាញ់សាមញ្ញៗអាចមានឥទ្ធិពលដ៏មានអានុភាពមួយ ។

ពេលយើងធ្វើកិច្ចការរបស់ព្រះគ្រីស្ទ ហើយចូលរួមនៅក្នុងការព្យាបាលមនុស្សដទៃ នោះពរជ័យមហិមានឹងកើតមានឡើង ។ ដូចព្រះគ្រីស្ទបានមានបន្ទូលថា « ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ » ( ម៉ាថាយ ២៥:៤០ ) ។ ចំពោះទ្រង់ដែលបានព្យាបាលពួកយើងម្នាក់ៗ ចំពោះទ្រង់ដែលបានឱបយើងនៅក្នុងព្រះហស្តដ៏ពេញដោយក្ដីស្រឡាញ់ ជាច្រើនគ្រាជាងយើងដឹង ចំពោះទ្រង់ដែលបានផ្ដល់ដង្វាយធួនរបស់ទ្រង់ដែល ជាឱសថនៃព្យាបាល នោះយើងអាចថ្វាយកិច្ចខិតខំបន្តិចបន្តួចរបស់យើង ដើម្បីជួយព្យាបាលបងប្អូនប្រុសស្រីរបស់យើង ។ នេះគឺជាជំនាញនៃអង្គព្យាបាលពិតប្រាកដ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

១. សូមមើល « ខ្ញុំនឹងដើរតាមព្រះអង្គ » *ទំនុកតម្កើង* លេខ ១៣៥ ។
២. « ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ខាងក្នុងគម្របខាងមុខ ។

# ផ្កា និង ស្ថេរភាពផ្នែកហិរញ្ញវត្ថុ

ដោយ ម៉ៃឆែល វ៉ល

ព្រះអម្ចាស់បានបង្កើនលទ្ធភាពខ្ញុំ បានពង្រីកសមត្ថភាពខ្ញុំ ហើយបានធ្វើឲ្យខ្ញុំក្លាយជាមនុស្សប្រសើរឡើងជាងខ្ញុំអាចធ្វើដោយខ្លួនខ្ញុំផ្ទាល់ ។

ភាពពិតមួយដែលខ្ញុំពុំបានរៀនចប់ពីមហាវិទ្យាល័យបានរំខានចិត្តខ្ញុំណាស់ ។ ខ្ញុំបានដឹងថា ប្រសិនបើមានអ្វីមួយបានកើតឡើងចំពោះស្វាមីខ្ញុំ នោះខ្ញុំពុំបានត្រៀមហិរញ្ញវត្ថុដើម្បីផ្គត់ផ្គង់គ្រួសារយើងឡើយ ។

បន្ទាប់មក រឿងពុំបានរំពឹងមួយបានកើតឡើង ។ ខ្ញុំបានទទួលទូរសព្ទមួយដែលធ្វើឲ្យខ្ញុំរន្ធត់ និងផ្លាស់ប្ដូរជីវិតខ្ញុំ ។

ស្វាមីខ្ញុំដែលមានគ្រោះថ្នាក់បានស្រែកតាមទូរសព្ទថា « សូមទូរសព្ទទៅ ៩១១ ! ។ បងកំពុងជាប់នៅក្រោមត្រាក់ទ័រ ! »

ខ្ញុំបានទូរសព្ទសូមជំនួយ ហើយបន្ទាប់មក ខ្ញុំបានទៅកាន់ដីដែលស្វាមីខ្ញុំកំពុងកាប់ផ្ការនោះយ៉ាងលឿន ដោយធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់តាមផ្លូវចាក់គ្រួសទៅកាន់ដីរបស់យើងនៅ ភា រីច រដ្ឋអាឡាស្កា ស.រ.អា. ។ ប៊ែរីនៅរស់ទេ ប៉ុន្តែគាត់កំពុងជាប់នៅក្រោមម៉ាស៊ីនត្រាក់ទ័រដែលបានក្រឡាប់នោះ ។

ដោយប្រើឧបករណ៍សង្គ្រោះដោយកម្លាំងទឹក នោះក្រុមសង្គ្រោះបន្ទាន់បានលើកត្រាក់ទ័រចេញ ហើយទាញប៊ែរីចេញពីវា ។ ជើងរបស់គាត់បានប្រឡាក់ប្រេងម៉ាស៊ូតជោគ មើលទៅដូចជាបាក់ច្រើនកន្លែង ។ គាត់ត្រូវបានគេយកទៅមជ្ឈមណ្ឌលផ្នែករងរបួស ជាកន្លែងដែលគាត់បានទទួលការប្រសិទ្ធពរបព្វជិតភាព ពីមុនគេថតកាំរស្មីអ៊ិចលើជើងគាត់ ។



យើងមានការភ្ញាក់ផ្អើលថា គ្មានឆ្អឹងមួយណាបាក់ឡើយ ប៉ុន្តែជើងផ្នែកខាងក្រោយម្ខាងរបស់ប៉ៃរីបានរលាកប្រេងម៉ាស៊ូតធ្ងន់ធ្ងរ ។ របួសដោយការប៉ះទង្គិចរបស់គាត់ក៏បានធ្វើឲ្យតម្រងនោមរបស់គាត់ខូចផងដែរ ។ គាត់អាចឈានដល់ការបាត់បង់ជីវិត ។

បន្ទាប់ពីប៉ៃរីបានស្នាក់នៅមន្ទីរពេទ្យទាំងឈឺចាប់អស់រយៈពេលប្រាំថ្ងៃមក កម្រិតសារធាតុពុលក្នុងឈាមគាត់បានចាប់ផ្តើមធ្លាក់ចុះ ។ ការផ្លាស់ប្ដូរសម្លៀកបំពាក់ ការផ្សាំស្បែក ការវះកាត់ជាច្រើនដងនិងការព្យាបាលដោយប្រើអុកស៊ីសែនបានធ្វើឡើងអស់រយៈពេលជាច្រើនខែបន្ទាប់មកទៀត ។ ពេលគាត់បានស្រួលខ្លួនល្មមហើយ ប៉ៃរីបានត្រឡប់មកធ្វើការងារផ្នែកលក់របស់គាត់នៅផ្ទះវិញ ។

## « គ្មាននរណាជ្រើសរើសខ្ញុំឲ្យធ្វើការឡើយ »

បទពិសោធន៍នេះគឺជាការផ្លាស់ប្ដូរដ៏ធំ ។ ពេលខ្ញុំបានចំណាយពេលពីរបីឆ្នាំបន្ទាប់ ដោយពិចារណារពីអ្វីដែលខ្ញុំអាចធ្វើ ប្រសិនបើខ្ញុំបាត់បង់ប៉ៃរី នោះខ្ញុំបានស្ម័គ្រចិត្តធ្វើការ បានចូលរួមសិក្ខាសាលា ហើយដាក់ពាក្យធ្វើការក្រៅម៉ោងជាច្រើនកន្លែង ។ ប៉ុន្តែខ្ញុំគ្មានជំនាញអ្វីឡើយ ហើយគ្មាននរណាបានជ្រើសរើសខ្ញុំឡើយ ។

យើងប្រកបរបរចិញ្ចឹមជីវិតដោយធ្វើកសិកម្មដោយមានដីសម្រាប់ចិញ្ចឹមសត្វមួយចំនួន ដូច្នេះខ្ញុំបានចាប់ផ្តើមស្រាវជ្រាវផ្នែកកសិកម្មទុកជារបរចិញ្ចឹមជីវិត ។ ថ្ងៃមួយមានគំនិតមួយបានផុសឡើងក្នុងចិត្តខ្ញុំអំពី ៖ ផ្កា ។ បន្ទាប់ពីស្រាវជ្រាវអំពីការដាំផ្កា នោះខ្ញុំបានសម្រេចចិត្តសាកល្បងដាំវា ។ ខ្ញុំបានទៅសន្និសីទមួយដើម្បីជួបអ្នកដាំផ្កា ហើយបានរៀបចំផ្លាស់ប្ដូរពីដីចិញ្ចឹមសត្វទៅជាដីដាំផ្កាវិញ ។ បន្ទាប់មក នៅខែវិច្ឆិកា ឆ្នាំ ២០១៦ ខ្ញុំបានចុះឈ្មោះចូលរៀនថ្នាក់សេវាកម្មភាពខ្លួនទីពឹងខ្លួនស្ដីពីរបៀបចាប់ផ្តើម និងពង្រីកអាជីវកម្មផ្ទាល់ខ្លួនរបស់ខ្ញុំ ។

## ហាងផ្កាផ្ទាល់ខ្លួនរបស់យើង

វគ្គសិក្សារយៈពេល ១២ សប្ដាហ៍គឺជាអ្វីដែលខ្ញុំត្រូវការពិតប្រាកដ ។ ខ្ញុំមានផែនការអាជីវកម្មគ្រឹះ ហើយមានគំនិតអស្ចារ្យជាច្រើន ប៉ុន្តែខ្ញុំខ្វះការរៀបចំ ។ គំនិតនានាបានផុសឡើងនៅក្នុងថ្នាក់នោះ ដែលខ្ញុំពុំធ្លាប់ពិចារណាពីមុនមក ។ ខ្ញុំបានអនុវត្តតាមគំនិតនីមួយៗទាំងនោះ ។ ពេលខ្ញុំបានធ្វើការនៅឆ្នាំដំបូងក្នុងការដាំដុះ និងលក់ផ្កា យោបល់និងគោលការណ៍ដែលខ្ញុំបានរៀននៅក្នុងថ្នាក់បានដំណើរការ ។

- ខ្ញុំរកបានប្រាក់កម្ចីអាជីវកម្មមួយដែលមានការប្រាក់ទាប ។
- ខ្ញុំបានពង្រីកទីផ្សាររបស់ខ្ញុំ ដើម្បីរួមបញ្ចូលទាំងទីផ្សារកសិករ និងហាងលក់ផ្កា ។
- ខ្ញុំបានកក់ព្រឹត្តិការណ៍មួយចំនួននៅកសិដ្ឋានរបស់យើង ទុកជាការពង្រីកសេវាកម្មរបស់ខ្ញុំ ។

នៅចុងឆ្នាំ ២០១៧ បន្ទាប់ពីឆ្នាំដំបូងនៃការដាំផ្ការបស់ខ្ញុំ ខ្ញុំបានដឹងថា ការលក់ទៅឲ្យហាងលក់ផ្កាត្រូវចំណាយពេលច្រើនណាស់ ។ ខ្ញុំមានការងឿងឆ្ងល់ថា « ចុះបើខ្ញុំបើកហាងផ្ទាល់ខ្លួនវិញនោះ ? » ហាងផ្កាក្នុងមូលដ្ឋានបានបិទទ្វារ ហើយអគារនោះបានប្រែជាមិនគួរឲ្យចាប់អារម្មណ៍ ។ ដូច្នេះស្វាមីខ្ញុំ និងខ្ញុំបានទិញវា ជួសជុលវាឡើងវិញ ហើយបើកហាងផ្កាមួយ ដែលមានលក់រូបគំនូរ និងវត្ថុច្នៃប្រឌិតក្នុងស្រុកផ្សេងៗផងដែរ ។ បន្ថែមពីលើនោះទៀត ខ្ញុំបានបើកអាជីវកម្មកន្លែងជួលដាំរុក្ខជាតិ និងការតុបតែងរុក្ខជាតិក្នុងគេហដ្ឋានផងដែរ ។

ខ្ញុំលក់ផ្ការបស់ខ្ញុំនៅហាងរបស់យើង និងនៅតាមហាងកាហ្វេ ហាងលក់គ្រឿងតែងកាយ និងនៅតូបមួយក្នុងអាកាសយានដ្ឋានក្នុងមូលដ្ឋាន ។ ខ្ញុំបានទទួលអ្វីដែលខ្ញុំត្រូវការរៀងរាល់ថ្ងៃ ។

## ព្រះអម្ចាស់មានព្រះទ័យគិតគូរ

ខ្ញុំមានទីបន្ទាល់មួយថា ព្រះអម្ចាស់មានព្រះទ័យគិតគូរនឹងអាជីវកម្មរបស់ខ្ញុំ ។ ទ្រង់បានជួយខ្ញុំបង្កើតស្ថេរភាពផ្នែកហិរញ្ញវត្ថុសម្រាប់ខ្លួនខ្ញុំ *និង* ការងារក្រៅម៉ោងសម្រាប់ស្ត្រីមួយចំនួនដែលចង់ធ្វើការតាមម៉ោងដែលអាចបត់បែនបាន និងសម្រាប់និស្សិតធ្វើការរហូតដល់ពួកគេរៀនចប់ ។ កូនស្រីម្នាក់របស់ពួកយើងគ្រប់គ្រងកសិដ្ឋានផ្កា ហើយកូនប្រុសពីរនាក់របស់យើងធ្វើការច្រើននៅកសិដ្ឋាន រួមទាំងជួយសាងសង់ផ្ទះបៃតងផងដែរ ។ ប៉ៃរីជួយការងារនៅពេលល្ងាច និងនៅចុងសប្ដាហ៍ ដោយលើកឥវ៉ាន់ធ្ងន់ៗ ។

យើងទាំងអស់គ្នាជួយជ្រោមជ្រែងគ្នា ហើយធ្វើការរួមគ្នា ។ វាបានផ្ដល់ពរជ័យដល់មនុស្សគ្រប់គ្នាដែលចូលរួមនឹងការងារនេះ ។ ខ្ញុំមានភាពមមាញឹក ប៉ុន្តែនៅតែមានពេលសម្រាប់គ្រួសារខ្ញុំ ការហៅទាំងឡាយក្នុងសាសនាចក្រ កាតព្វកិច្ចនៃការងារបម្រើ និងការងារស្ម័គ្រចិត្ត ។

ការធ្វើការតាំងពីគ្រាដែលខ្ញុំដាំគ្រាប់ពូជ ឬដាំមើមនោះ រហូតដល់ពេលដែលខ្ញុំបង្ហាញផ្កាមួយដល់អតិថិជនម្នាក់ ដែលផ្ដល់ស្មារតីនៃសមិទ្ធផលដ៏អស្ចារ្យមួយដល់ខ្ញុំ ។ ខ្ញុំពុំសង្ស័យឡើយថា ព្រះអម្ចាស់បានបង្កើនលទ្ធភាពខ្ញុំ បានពង្រីកសមត្ថភាពខ្ញុំ ហើយបានធ្វើឲ្យខ្ញុំក្លាយជាមនុស្សប្រសើរឡើងជាងខ្ញុំអាចប្រែក្លាយដោយខ្លួនខ្ញុំផ្ទាល់ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋអាឡាស្កា ស.រ.អា. ។*

# ម៉ាថា និង ម៉ារា

ដោយ កាមីលេ ហ្វ្រុក អូស្លុន
សាស្ត្រាចារ្យព្រះគម្ពីរបុរាណដែលចូលនិវត្តន៍ សាកលវិទ្យាល័យព្រិកហាំ យ៉ង់

*វាជាការចាំបាច់ដើម្បីទទួលស្គាល់ និងធ្វើតាមព្រះគ្រីស្ទដោយអស់ពីចិត្ត និងគំនិតរបស់យើង មិនថាយើងជ្រើសរើសរបៀបណាដើម្បីបម្រើនោះឡើយ ។*

នៅគ្រាមួយ ពេលមនុស្សជាច្រើននៅទីក្រុងយេរូសាឡិមបានបង្ហាញការភាន់ច្រឡំអំពីអត្តសញ្ញាណរបស់ព្រះអង្គសង្គ្រោះ នោះព្រះយេស៊ូវបានបង្រៀនថា « បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ » ( យ៉ូហាន ៧:១៧ ) ។ ប្រសិនបើយើងរៀនឲ្យស៊ីជម្រៅហួសពីគោលលទ្ធិនៃការរៀនសូត្រ និងរៀនថា តើព្រះយេស៊ូវគ្រីស្ទជានរណា ហើយប្រែក្លាយជាសិស្សរបស់ទ្រង់ នោះយើងត្រូវអនុវត្តសេចក្តីជំនឿយើងសិន ។ ដំណើររឿងរបស់ម៉ាថា និងម៉ារាបង្ហាញថា មានរបៀបច្រើនជាងមួយ ដើម្បីបម្រើព្រះអង្គសង្គ្រោះនៅក្នុងជីវិតយើងផ្ទាល់ ។

មិនយូរប៉ុន្មានបន្ទាប់ពីទេសនកថានេះ ព្រះយេស៊ូវ និងពួកសិស្សមួយចំនួនរបស់ទ្រង់បានទៅផ្ទះរបស់ម៉ាថានៅភូមិបេថានី ដើម្បីបង្រៀនដំណឹងល្អ ។ ម៉ាថាបានយកការទទួលខុសត្រូវចម្បងមួយ សម្រាប់ការឆ្លើយតបក្នុងនាមជាម្ចាស់ផ្ទះដ៏សប្បុរស ប្រហែលជាការផ្តល់អាហារ និងជម្រកដល់ភ្ញៀវរបស់នាង ខណៈដែលប្អូនស្រីរបស់គាត់ម៉ារាអង្គុយនៅក្បែរព្រះយេស៊ូវ ហើយស្តាប់ទ្រង់មានបន្ទូល ។ ( សូមមើល លូកា ១០:៣៨–៤២ ) ។ វិធីសាស្ត្រខុសគ្នារបស់បងប្អូនស្រីទាំងពីរដើម្បីបម្រើព្រះអម្ចាស់ បង្រៀនយើងឲ្យគោរព និងផ្តល់កិត្តិយសដល់អស់អ្នកដែលបង្ហាញភាពជាសិស្សតាមរបៀបផ្សេងៗគ្នា ។ ការបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងរឿងនេះ ក៏បង្ហាញពីទស្សនវិស័យដែលស្ត្រីមានសេរីភាព ដើម្បីជ្រើសរើសរបៀបដើម្បីបម្រើ និងរបៀបបង្ហាញភាពជាសិស្ស ដូចជាពួកបុរសអាចជ្រើសរើសផងដែរ ។

## ការបម្រើតាមរយៈការផ្តល់ឲ្យ

រំពេចនោះ ពីមុនលូកាណែនាំម៉ាថា និងម៉ារា លោកកត់ត្រារឿងប្រៀបប្រដូចអំពីសាសន៍សាម៉ារីល្អម្នាក់ ។ នៅក្នុងរឿងនេះ ព្រះអង្គសង្គ្រោះបានបង្រៀនយើងឲ្យបង្ហាញសេចក្តីមេត្តាករុណាដល់មនុស្សដទៃ ដូចជាផ្តល់អាហារ ផ្តល់ទីជម្រក និងមើលថែដល់មនុស្សគ្រប់រូបដែលខ្វះខាត ( សូមមើល លូកា ១០:៣០–៣៧ ) ។ ការព្យាយាមរបស់ម៉ាថានៅក្នុង « ការរវល់ជាច្រើន » ( លូកា ១០:៤០ ) បង្ហាញពីការទទួលយករបស់នាង និងការបកស្រាយនៃគោលការណ៍នេះថា នាងអនុវត្តសេចក្តីជំនឿរបស់ខ្លួន ។

ការបង្ហាញអំពីការបង្រៀនថា ទ្រង់ជាអង្គដ៏អស្ចារ្យបំផុតប្រទានការងារបម្រើដល់មនុស្សដទៃ ( សូមមើល ម៉ាថាយ ២០:២៦–២៨; លូកា ២២:២៦–២៧ ) ព្រះយេស៊ូវបានចំណាយពេលវេលានៃព្រះជន្មទ្រង់ក្នុងការបម្រើ ។ ម៉ាថាបានឆ្លើយតបជាមួយនឹងបំណងប្រាថ្នារបស់នាងដើម្បីបម្រើទ្រង់ ។ ដំណើររឿងរបស់ម៉ាថា និងម៉ារាបង្ហាញពីស្ត្រីពីរនាក់ដែលធ្វើជាគំរូនៃសេចក្តីជំនឿ និងភាពជាសិស្សពិតប្រាកដតាមរយៈការបម្រើ និងការរៀនសូត្រ ។ ដូចជាម៉ាថាដែលបានបង្ហាញសេចក្តីស្រឡាញ់របស់នាងចំពោះព្រះគ្រីស្ទតាមរយៈការបម្រើដែរ នោះយើងអាចផ្តល់ការបម្រើដល់អស់អ្នកដែលនៅជុំវិញយើងដែលផ្តោតទៅលើសេចក្តីស្រឡាញ់របស់យើងចំពោះព្រះអង្គសង្គ្រោះយើង និងឆន្ទៈយើងដើម្បីរៀន និងធ្វើតាមដំណឹងល្អរបស់ទ្រង់ ។

ពេលយើងបម្រើ នោះយើងត្រូវចងចាំថា មានរបៀបផ្សេងទៀតដើម្បីបម្រើ ហើយយើងពុំវិនិច្ឆ័យអស់អ្នកដែលចូលរួមក្នុងរបៀបទាំងនោះឡើយ ។ ពេលម៉ាថា « មានការរវល់ » ( លូកា ១០:៤០ ) ប្រតិកម្មរបស់គាត់បានបង្ហាញពីជម្លោះ និងការគំរាមកំហែងដល់តរិយាបថគួរសមនៃការមកលេងរបស់ព្រះអង្គសង្គ្រោះ ។

ទោះបីជាអាចទទួលភ្ញៀវ និងមានការទទួលខុសត្រូវក្តី ម៉ាថាក៏មានភាពមមាញឹក និងដក់ចិត្តនឹងភាពរវល់របស់គាត់ផងដែរ ។ គាត់បានត្អូញត្អែរទៅកាន់ព្រះយេស៊ូវថា « ព្រះអម្ចាស់អើយ តើទ្រង់មិនគិតឃើញថា ប្អូនខ្ញុំម្ចាស់ វាទុកខ្ញុំម្ចាស់ឲ្យខ្វល់ខ្វាយបម្រើតែម្នាក់ឯងទេឬអី សូមទ្រង់ប្រាប់ឲ្យវាមកជួយខ្ញុំម្ចាស់ផង » ( លូកា ១០:៤០ ) ។ ការជំទាស់របស់នាងថ្លែងបញ្ជាក់ពីការយល់ដឹងរបស់នាងថា នាងកំពុងបម្រើតែម្នាក់ឯង ។ នាងមើលពុំឃើញពីរបៀបនៃការបម្រើផ្សេងៗ ដែលមនុស្សដទៃបានធ្វើឡើង



*ម៉ារាបានអង្គុយស្តាប់ព្រះបន្ទូល* ដោយ វ៉លធើ រ៉ាន



រូបភាពលម្អិតពី *ព្រះគ្រីស្ទនៅក្នុងផ្ទះរបស់ម៉ារា និងម៉ាថា* ដោយ វ៉លធើ រ៉ាន

*យើងអាចយកគំរូរបស់ម៉ាថា និងម៉ារាមកក្នុងជីវិតយើង ហើយទូលសូមការណែនាំ ដើម្បីបម្រើតាមរបៀបល្អបំផុត ។*

នៅគ្រានោះទេ រួមទាំងម៉ារា និងព្រះអង្គសង្គ្រោះផ្ទាល់ ។ ម៉ាថាបានបង្ហាញគោលការណ៍នៃការផ្តល់ឲ្យ ប៉ុន្តែដោយឥរិយាបថដែលរំខានដល់ព្រះវិញ្ញាណ ។ នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង យើងក៏អាចបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះមនុស្សដទៃ តាមរយៈទង្វើរបស់យើង *និង* ឥរិយាបថរបស់យើងផងដែរ ។

## ការបម្រើតាមរយៈការទទួល

ដោយសំឡេងនៃការជាស់តឿន ព្រះយេស៊ូវបានទទួលស្គាល់កិច្ចខិតខំរបស់ម៉ាថាដើម្បីបម្រើ និងភាពស្មុគស្មាញរបស់នាង ៖ « ម៉ាថា ៗអើយ នាងព្រួយចិត្តខំប្រឹងរៀបចំធ្វើអីច្រើនម្ល៉េះ » ( លូកា ១០:៤១ ) ។ បន្ទូលរបស់ព្រះអង្គសង្គ្រោះពុំមែនដើម្បីបង្អាក់របៀបដែលម៉ាថាបានជ្រើស ដើម្បីបង្ហាញការទទួលភ្ញៀវនោះទេ ប៉ុន្តែដើម្បីទទួលស្គាល់សិទ្ធិដែលម៉ារាត្រូវបម្រើតាមរយៈការស្តាប់ និងការរៀន ។ ទង្វើរបស់ម៉ារាបង្ហាញយើងពីអ្វីដែលចាំបាច់សម្រាប់មនុស្សទាំងអស់ណា ដែលមានបំណងធ្វើតាមទ្រង់ដោយឯករាជ្យស្តីពីលក្ខណៈនៃការបម្រើតាមការជ្រើសរើស ។

ម៉ារាបានអនុញ្ញាតឲ្យព្រះអង្គសង្គ្រោះបម្រើនាងតាមរយៈការទទួលបន្ទូលទ្រង់ ។ គំរូរបស់នាងបង្ហាញថា យើងអាចបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអង្គសង្គ្រោះ តាមរយៈការអង្គុយនៅក្បែរទ្រង់ដើម្បីរៀន និងរីកចម្រើនខាងវិញ្ញាណ ។

## សេចក្តីតែមួយទេ ដែលសម្រាប់ត្រូវការ

ចម្លើយចំពោះទំនាស់របស់ម៉ាថាត្រូវបានទទួលស្គាល់ថាជា « សេចក្តីតែមួយទេ ដែលសម្រាប់ត្រូវការ » ( លូកា ១០:៤២ ) ។ អំណាចដ៏អស្ចារ្យនៃភាពសាមញ្ញត្រូវបានបង្ហាញ ប៉ុន្តែ *ភាពសាមញ្ញ* អាចមានន័យផ្សេងពីគ្នាចំពោះយើងម្នាក់ៗ ។ បទដ្ឋាននៃ « តម្រូវការ » គឺរកពុំឃើញនៅក្រៅខ្លួនយើងឡើយ ប៉ុន្តែរកបាននៅក្នុងការជំរុញចិត្តរបស់យើងវិញ ។ អ្វីដែលសំខាន់គឺការទទួលស្គាល់ និងការធ្វើតាមព្រះគ្រីស្ទដោយអស់ពីចិត្ត និងគំនិតរបស់យើង មិនថាយើងជ្រើសរើសរបៀបណាដើម្បីបម្រើនោះឡើយ ។

វាអាចថា ការបម្រើតាម « របៀបរបស់ម៉ាថា » អាចជារបៀបដ៏ល្អបំផុតនៅក្នុងគ្រាមួយចំនួន ខណៈដែលគ្រាដទៃទៀតហាក់ដូចជាផ្តល់យោបល់ ថាជា « ចម្លើយតបរបស់ម៉ារា »—ឬសូម្បីតែរបៀបណាមួយដែលមិនត្រូវនឹងស្ថានភាពទាំងពីរនេះក្តី ។ យើងអាចយកគំរូរបស់ម៉ាថា និងម៉ារាមកក្នុងជីវិតយើង ហើយទូលសូមការណែនាំ ដើម្បីបម្រើតាមរបៀបល្អបំផុត ។

ចូរយើងក្រឡេកមើលឥរិយាបថរបស់យើងខណៈបម្រើនៅក្នុងរបៀបដែលយើងជ្រើសរើសដោយខ្លួនយើងផ្ទាល់ ដោយចងចាំថា ភាពជឿជាក់ពិតប្រាកដរបស់យើងដើម្បីធ្វើតាមទ្រង់គឺជារឿងសំខាន់បំផុត ។ ចូរឲ្យឃើញថា យើងនៅក្បែរនឹងព្រះអង្គសង្គ្រោះជានិច្ច ។ ■



**ដោយប៊ីស្សព**
**ឌីន អិម ដេវីស**
ទីប្រឹក្សាទីមួយក្នុងគណៈ
ប៊ីស្សពជាអធិបតី

# ភាពជាសិស្ស ដែលបានដឹកនាំដោយព្រះ

ប្រសិនបើអ្នកនឹងព្យាយាមប្រែក្លាយជាសិស្សពិតរបស់ព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង នោះព្រះអម្ចាស់ជាព្រះនៃស្ថានសួគ៌នឹងដឹកនាំផ្លូវរបស់អ្នក ។

ខ្ញុំចង់លើកឡើងពីសំណួរពីរដែលខ្ញុំផ្ទាល់ចង់បានចម្លើយកាលពីខ្ញុំនៅក្មេង ។ ទីមួយ ប្រសិនបើអ្នកប្ដូជាជីវិតអ្នកចំពោះការបម្រើរបស់ព្រះ តើទ្រង់នឹងដឹកនាំផ្លូវអ្នក ហើយប្រើអ្នកសម្រាប់គោលបំណងសុចរិតរបស់ទ្រង់ដែរឬទេ ? ទីពីរ ប្រសិនបើអ្នកជ្រើសរើសធ្វើតាមព្រះអង្គសង្គ្រោះ ហើយដើរនៅលើផ្លូវនៃភាពជាសិស្ស តើព្រះអម្ចាស់នឹងមើលថែអ្នក ដឹកនាំអ្នក ប្រទានពរដល់អ្នក ហើយបំពេញឲ្យអ្នកនូវវិញ្ញាណនៃអំណរ និងការបំពេញដូចដែលទ្រង់ប្រើអ្នកសម្រាប់គោលបំណងរបស់ទ្រង់ដែរឬទេ ?

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ប្រសិនបើបងប្អូនថ្វាយដួងចិត្តរបស់បងប្អូនចំពោះព្រះអង្គសង្គ្រោះ ហើយព្យាយាមដើរដោយសេចក្ដីជំនឿ និងការអាណិតអាសូរនៅលើផ្លូវដែលទ្រង់បានត្រាស់បង្គាប់ នោះខ្ញុំដឹងថា ព្រះអម្ចាស់នឹងប្រើបងប្អូនតាមរបៀបមួយដែលបងប្អូនពុំអាចនឹកស្រមៃដល់ក្នុងពេលនេះ ។

បងប្អូននិយាយថា « ប៉ុន្តែខ្ញុំពុំមែនជាមនុស្សពិសេសអ្វីទេ » ។ ខ្ញុំជាមនុស្សមធ្យមក្នុងគ្រប់កិច្ចការទាំងអស់ ។ ខ្ញុំពុំមែនជាមនុស្សឆ្លាត មានវោហាសព្ទ ស្លៀកពាក់ស្អាត ឬមានឥរិយាបថប្រពៃឡើយ ។ តើព្រះអាចប្រើខ្ញុំយ៉ាងដូចម្ដេច ? »

ចាប់តាំងពីគ្រាដំបូងមក ព្រះវរបិតាសួគ៌យើងបានឈោងទៅជួយអស់អ្នកដែលជាមនុស្សមធ្យម ហើយប្រើពួកគេសម្រាប់គោលបំណងទ្រង់ ។ សាវកប៉ុលបានសរសេរទៅកាន់បងប្អូនសព្វថ្ងៃនេះ ដូចលោកបានសរសេរទៅកាន់ពួកកូរិនថូសពីបុរាណដែរ ៖

« ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកម្សោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស

ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយ៍នេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ ៖

ប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួន នៅចំពោះព្រះឡើយ » ( កូរិនថូសទី ១ ១:២៧–២៩ ) ។

នៅពេលដល់គ្រាសម្រាប់ព្រះអង្គសង្គ្រោះស្ដារសាសនាចក្ររបស់ទ្រង់លើផែនដីឡើងវិញ ហេតុអ្វីអ្នកស្មានថា ទ្រង់បានជ្រើសរើសក្មេងប្រុសម្នាក់ដែលមានការអប់រំតិចតួចនោះ ?

ហេតុអ្វីអ្នកគិតថា ព្រះបានប្រាប់គេឌានដែលជាកសិករ ឲ្យបន្តបញ្ជូនកងទ័ពទៅផ្ទះវិញ រហូតដល់លោកមានទ័ពតែ ៣០០ នាក់ដើម្បីច្បាំងនឹងសត្រូវដ៏ច្រើននោះ ? ( សូមមើល ពួកចៅហ្វាយ ៧:១–២៥ ) ។

ហេតុអ្វីអ្នកស្មានថា ព្រះអង្គសង្គ្រោះយើងបានជ្រើសរើសអ្នកនេសាទត្រី ឲ្យធ្វើជាប្រធានសាវករបស់ទ្រង់ ហើយដឹកនាំសាសនាចក្របន្ទាប់ពីទ្រង់បានយាងទៅវិញ ? ( សូមមើល ម៉ាថាយ ១៦:១៨ ) ។

ទីមួយ ដោយសារ « ព្រះទ្រង់មិនទតចំពោះសេចក្ដី ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ » (សាំយូអែល ទី១ ១៦:៧ ) ។

ទីពីរ ដោយសារព្រះអាចយកដីឥដ្ឋដ៏រាបទាបបំផុត ហើយបង្កើតស្នាដៃឯកមកពី



រូបភាពដោយ ខេវី យ៉ង



ដីឥដ្ឋនោះ ។ ប្រាកដណាស់ « ប្រសិនបើជាព្រះកាន់ខាងយើង តើអ្នកណាអាចទាស់នឹងយើងបាន ? » ( រ៉ូម ៨:៣១ ) ។

ទីបី ព្រះជ្រើសរើសមនុស្សទន់ខ្សោយ ដើម្បីកុំឲ្យបុគ្គលណាម្នាក់មានអំនួត ហើយនិយាយថា « ខ្ញុំបានធ្វើកិច្ចការនេះដោយសមត្ថភាពខ្ញុំផ្ទាល់ » ។

ពេលពេត្រុសដែលជាអ្នកនេសាទត្រីដ៏រាបទាបម្នាក់យកមនុស្សមានជំនឿមួយក្រុមតូច ហើយក្រោយមកបានឃ្វាលពួកគេទៅក្នុងសាសនាចក្រដ៏មានមហិទ្ធិឫទ្ធិ នោះមនុស្សបានថ្លែងឡើង ហើយថ្វាយអំណរគុណដល់ព្រះ ។

ពេលក្រុមមនុស្ស ៣០០ នាក់នោះបានច្បាំងឈ្នះកងទ័ពរាប់ពាន់នាក់ នោះប្រជាជនកោតសរសើរចំពោះព្រះ ។

ពេលក្មេងប្រុសកាប់គាស់ដីចាកចេញពីការភ្ជួររាស់ដី ហើយបកប្រែអត្ថបទដ៏បំផុសគំនិត និងផ្លាស់ប្ដូរជីវិតតាំងពីព្រះគម្ពីរប៊ីប នោះមនុស្សពុំសរសើរដល់បញ្ញារបស់មនុស្សនោះទេ ប៉ុន្តែសរសើរដល់ព្រះចេស្ដានៃព្រះវិញ ។

ព្រះវរបិតាសួគ៌ពុំត្រូវការឲ្យអ្នកជាមនុស្សខ្លាំង មានប្រាជ្ញា ឬពូកែនិយាយនោះទេ ។ ទ្រង់ត្រូវការអ្នកឲ្យផ្ដល់ចិត្តតម្រង់ទៅឯទ្រង់ ហើយព្យាយាមគោរពទ្រង់ តាមរយៈការបម្រើទ្រង់ និងឈោងទៅជួយអស់អ្នកដែលនៅជុំវិញអ្នកដោយក្ដីអាណិតអាសូរ ។

## ការងារបម្រើនៃព្រះវិញ្ញាណបរិសុទ្ធ

ចំណុចទីពីរដែលខ្ញុំចង់ឲ្យអ្នកយល់ច្បាស់នោះគឺថា ប្រសិនបើអ្នកនឹងធ្វើតាមព្រះក្នុងសេចក្ដីពិត និងកម្លាំង នោះទ្រង់នឹងប្រទានពរដល់អ្នកតាមរបៀបដែលអ្នកពុំអាចយល់បាន ។

នៅឆ្នាំ ២០០៦ ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី ( ១៩១០–២០០៨ ) និងគណៈប្រធានទីមួយបានកំណត់ថា គួរតែមានការពិចារណាអំពីព្រះវិហារបរិសុទ្ធសម្រាប់ទីក្រុង សាន់ សាល់វ៉ាឌ័រ ប្រទេស អែល សាល់វ៉ាឌ័រ ។ យើងបានទៅមើលដីមួយចំនួន រួមទាំងប្លុកអគារពេញទីក្រុងនោះ ដែលមានទីតាំងនៅក្នុងផ្នែកចំណាស់នៃទីក្រុងនោះ ។ ពេលយើងបើកឡានចេញពីដីមួយទៅដីមួយទៀត គ្មានអ្វីមួយដែលទំនងថាត្រូវឡើយ ។

ទីបំផុតយើងបានជិះកាត់តំបន់អភិវឌ្ឍមួយនៅផ្នែកខាងលិចនៃទីក្រុងនោះ ។ ខ្ញុំទទួលអារម្មណ៍អ្វីមួយនៅតំបន់នោះ ហើយខ្ញុំបានដើរជុំវិញប្លុកអគារមួយចំនួននោះ ។ ដីមួយកន្លែងដែលមានរបងព័ទ្ធជុំវិញគឺគួរឲ្យចាប់អារម្មណ៍ណាស់ ។ ខ្ញុំបានទាក់ទងទៅម្ចាស់ដីនោះ ហើយបានដឹងថា ដីនោះគេពុំលក់ទេ ដូច្នេះខ្ញុំបានទៅផ្ទះវិញ ។

ប៉ុន្តែព្យាការីបានមានប្រសាសន៍ថា ព្រះវិហារបរិសុទ្ធមួយត្រូវតែសាងសង់ឡើងនៅក្នុងប្រទេស សាន់ សាល់វ៉ាឌ័រ ដូច្នេះខ្ញុំបានត្រឡប់ទៅមើលដីផ្សេងទៀត ។ ជាថ្មីម្ដងទៀត ខ្ញុំបានឃើញថា ខ្ញុំចាប់អារម្មណ៍នឹងដីដែលមានរបងព័ទ្ធជុំវិញនោះ ហើយខ្ញុំបានទាក់ទងទៅម្ចាស់ដីនោះម្ដងទៀត ។ ពួកគេបានប្រាប់ជាថ្មីម្ដងទៀតថា ពួកគេពុំលក់ដីនោះទេ ។

ខ្ញុំបានត្រឡប់ទៅផ្ទះវិញម្ដងទៀត ប៉ុន្តែពុំអាចឈប់គិតពីអារម្មណ៍មួយថា ទីនោះគឺជាកន្លែងដែលត្រូវសាងសង់ព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានទាក់ទងក្រុមគ្រួសានោះភ្លាម ហើយសួរថា តើពួកគេអាចជួបជាមួយខ្ញុំបានដែរឬទេ ? ពួកគេបានយល់ព្រមជួបខ្ញុំ ។ ជាថ្មីម្ដងទៀត ខ្ញុំបានធ្វើដំណើរទៅ សាន់ សាល់វ៉ាឌ័រ ដោយមាន រ៉ូបឺត ហ្វុក ទៅជាមួយ គាត់គឺជាមិត្តខ្ញុំ ហើយជាបុគ្គលិកនៅក្នុងផ្នែកអចលនទ្រព្យរបស់

សាសនាចក្រ ។ នៅព្រឹកនោះ យើងបានលុតជង្គង់អធិស្ឋាននៅក្នុងបន្ទប់ខ្ញុំ ពីមុនយើងចាប់ផ្ដើមចេញដំណើរ ហើយទូលសូមជំនួយពីព្រះអម្ចាស់ ។

ពេលយើងបើកឡានតាមច្រកទ្វារចូលទៅក្នុងផ្ទះនោះ វាស្ទើរតែដូចជាការចូលទៅក្នុងសួនច្បារពិសិដ្ឋមួយ ។ មានដើមឈើ និងផ្កា និងសំឡេងអ៊ីអរមកពីអ្នកឈប់នៅខាងក្រៅនៅឯច្រកទ្វារចូល ។ លោក មីហ្គែល ដេញ៉ាស់ ប្អូនប្រុសគាត់ និងកូនប្រុសពីរនាក់ទៀតរបស់គាត់កំពុងរង់ចាំពួកយើង ។ ពួកគេបានស្វាគមន៍យើង ហើយនាំយើងចូលទៅក្នុងផ្ទះដូនតារបស់ពួកគេ—ជាផ្ទះមួយធំ និងទូលាយ ។

យើងបានប្រាប់ពួកគេថា ប្រធានសាសនាចក្ររបស់យើងបានចាត់យើងឲ្យមក ហើយលោកចង់ផ្ដល់ពរដល់ប្រទេសនេះ និងសមាជិកសាសនាចក្រ តាមរយៈការសាងសង់ព្រះវិហារបរិសុទ្ធមួយនៅទីនោះ ។ ខ្ញុំបានបង្ហាញរូបភាពព្រះវិហារបរិសុទ្ធផ្សេងទៀត ។ ខ្ញុំបាននិយាយថា យើងទទួលអារម្មណ៍ថា ដីរបស់ពួកគេជាផ្ទះនៃដូនតារបស់ពួកគេគឺជាកន្លែងមួយដែលត្រូវសាងសង់ព្រះវិហារបរិសុទ្ធ ។

វាមិនគួរឲ្យភ្ញាក់ផ្អើលឡើយ នៅពេលពួកគេបានបដិសេធយើងម្ដងទៀត ប៉ុន្តែយើងត្រូវតែព្យាយាម ។ ដូច្នោះហើយ យើងបានព្យាយាមគ្រប់មធ្យោបាយដើម្បីបញ្ចុះបញ្ចូលពួកគេស្ទើរតែជិតមួយម៉ោង ដូចជាការទិញបង់លុយទាំងដុល ការប្ដូរដី និងជម្រើសផ្សេងទៀតដែលយើងអាចគិតឃើញ ។ ប៉ុន្តែពួកគេម៉ឺងម៉ាត់នឹងការតាំងចិត្តរបស់ពួកគេ ហើយបដិសេធគ្រប់ការផ្ដល់ជូនរបស់យើង ។

យើងបានខំធ្វើអ្វីៗគ្រប់យ៉ាងតាមដែលយើងអាចធ្វើបាន ។ យើងបានរៀបចំខ្លួន ។ យើងបានខំធ្វើអស់ពីលទ្ធភាពដែលយើងចេះ ។ ប៉ុន្តែវាហាក់ដូចជាពុំគ្រប់គ្រាន់ឡើយ ។

ចិត្តខ្ញុំពោរពេញដោយការអធិស្ឋានមួយភ្លាមថា ៖ « ឱព្រះវរបិតាអើយ សូមជួយពួកទូលបង្គំឲ្យដឹងពីអ្វីដែលត្រូវនិយាយ ឬធ្វើផង » ។

នៅទីបំផុត វាបានបង្ហាញយ៉ាងច្បាស់ថា ដំណើររបស់យើងក្លាយជាឥតប្រយោជន៍ ។ វាបង្ហាញថា គ្មានអ្វីមួយបានផ្លាស់ប្ដូរចិត្តរបស់ពួកគេទេ ។ ប៉ុន្តែពេលយើងចាប់ផ្ដើមរៀបចំចាកចេញទៅហើយនោះ ស្រាប់តែមានអ្វីមួយបានកើតឡើង ។ ព្រះវិញ្ញាណព្រះអម្ចាស់បានយាងចូលមកក្នុងបន្ទប់នោះ ។ វាមានភាពស្ងៀមណាស់ ។ មនុស្សគ្រប់គ្នានៅក្នុងបន្ទប់បានទទួលអារម្មណ៍នោះ ។ វាគឺជាបទពិសោធន៍មួយខាងវិញ្ញាណដ៏មានឥទ្ធិពលបំផុតដែលខ្ញុំធ្លាប់មាន ។

មីហ្គែល ដេញ៉ាស់ ដែលពុំមែនជាសមាជិកសាសនាចក្របានចាប់ផ្ដើមយំ ។ លោកដេញ៉ាស់បានងាកទៅកាន់ប្អូនប្រុសរបស់គាត់ ហើយនិយាយថា « ប្រសិនបើយើងពុំអាចលក់ផ្ទះដូនតាយើងបានទេ តើយើងពុំអាចលក់ដីដ៏ល្អបំផុតនៅទល់មុខនេះដែលយើងមាននោះទេឬអី ?

ប្អូនប្រុសរបស់គាត់បានតបយល់ស្រប ។ បន្ទាប់មក យើងបាននិយាយគ្នាអំពីដីផ្សេងមួយទៀត ។ ពួកគេជាម្ចាស់ដីរាប់រយហិចតានៅឆ្លងទៅផ្លូវធំពីផ្ទះដូនតារបស់ពួកគេ ដែលចំណុចកណ្ដាលនៃដីនោះលេចឡើងបន្តិច ដូច្នេះគ្រប់ឡានដែលបើកបរតាមផ្លូវនោះអាចមើលឃើញព្រះវិហារបរិសុទ្ធ ។

នោះគឺជាដីដែលពួកគេបានផ្ដល់ជូនសម្រាប់សាងសង់ព្រះវិហារបរិសុទ្ធនៃព្រះអម្ចាស់ ។ វាពិតជាអព្ភូតហេតុមួយ ។ ចាប់តាំងពីគ្រានោះមក ពរជ័យនៃព្រះអម្ចាស់បានចូលមកក្នុងដំណើរការនោះ ។ នៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១១ ប្រធាន ហិនរី ប៊ី អាវរិង កាលនោះជាទីប្រឹក្សាមួយក្នុងគណៈប្រធានទីមួយ បានឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនេះសម្រាប់ការបម្រើរបស់ព្រះអម្ចាស់ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតដែលបន្ថែមសម្រស់ដល់ទូលនៅ សាន់ សាល់វ៉ាឌ័រ ពុំមែនជាលទ្ធផលនៃអ្វីដែលបងប្រុស ហ្វក ឬខ្ញុំបាននិយាយ ឬធ្វើឡើយ ។ ព្រះវិហារបរិសុទ្ធមាននៅទីនោះនាបច្ចុប្បន្ននេះ ដោយសារការងារបម្រើដ៏មានព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនៃព្រះដ៏មានមហិទ្ធិឫទ្ធិរបស់យើង ។

## ព្រះវរបិតាដ៏មានសេចក្ដីមេត្តាករុណារបស់យើង

ប្រសិនបើព្រះអម្ចាស់ខ្វល់ព្រះទ័យល្មម ដើម្បីបញ្ជូនព្រះវិញ្ញាណទ្រង់ ហើយអាចធ្វើឲ្យមានទីតាំងសម្រាប់ព្រះវិហារបរិសុទ្ធមួយ តើអ្នកពុំស្មានថា ទ្រង់នឹងបញ្ជូនព្រះវិញ្ញាណទ្រង់ ហើយរៀបចំចិត្តរបស់អ្នក និងដឹកនាំផ្លូវរបស់អ្នកទេឬអី ?

អ្នកមានតម្លៃខ្លាំងជាងដីមួយកន្លែងទៅទៀត ។ អ្នកគឺជាបុត្រជាទីស្រឡាញ់របស់ព្រះវរបិតាអស់កល្បរបស់អ្នក ។ អ្នកគឺជាពូជរបស់ព្រះនៃសាកលលោកនេះ !

តើអ្នកមិនគិតថា ទ្រង់គិតគូរពីអ្នកទេឬអី ? តើអ្នកមិនគិតថា ទ្រង់នឹងប្រើអ្នក និងប្រទានពរដល់អ្នកតាមរបៀបកាន់តែរុងរឿងជាងអ្វីដែលអ្នកអាចស្រមៃឃើញទេឬអី ?

ខគម្ពីរប្រាប់យើងថា ប្រសិនបើយើង « ពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត [ របស់យើង ] កុំឲ្យពឹងផ្អែកលើយោបល់ [ របស់យើង ] » ឡើយ ប្រសិនបើយើង « ទទួលស្គាល់ទ្រង់. . .នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រក [ របស់យើង ] » ( សុភាសិត ៣:៥–៦ ) ។

ស្ដេចបេនយ៉ាមីនបានសង្ខេបសារលិខិតយ៉ាងល្អឥតខ្ចោះ ដែលខ្ញុំចង់បន្សល់ទុកជាមួយអ្នក ។ ទ្រង់បានមានបន្ទូលថា ៖ « ខ្ញុំចង់ឲ្យអ្នករាល់គ្នាគិតពិចារណាអំពីស្ថានភាពដ៏មានពរ និងរីករាយនៃអស់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ ដ្បិតមើលចុះ ពួកគេបានពរគ្រប់យ៉ាង ទាំងខាងសាច់ឈាម និង ខាងវិញ្ញាណផង ហើយបើសិនជាពួកគេរក្សាការស្មោះត្រង់ដរាបដល់ចុងបំផុត នោះពួកគេនឹងត្រូវបានទទួលនៅស្ថានសួគ៌ ដើម្បីឲ្យពួកគេអាចរស់នៅជាមួយនឹងព្រះក្នុងស្ថានភាពសុភមង្គលដ៏មិនចេះចប់មិនចេះហើយ » ( ម៉ូសាយ ២:៤១ ) ។

ខ្ញុំសូមប្រកាសសរសើរតម្កើង និងធ្វើជាសាក្សីអំពីសេចក្ដីពិតនេះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ខ្ញុំបានឃើញពរជ័យដែលព្រះបានសន្យា បានបំពេញម្ដងហើយម្ដងទៀតនៅក្នុងជីវិតខ្ញុំផ្ទាល់ និងជីវិតមនុស្សដទៃជាច្រើនទៀត ។

ខ្ញុំសូមសន្យាថា ប្រសិនបើអ្នកនឹងផ្ចង់ចិត្តតម្រង់ទៅឯព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់អ្នក ប្រសិនបើអ្នកព្យាយាមរៀងរាល់ថ្ងៃ ដើម្បីស្រឡាញ់ និងធ្វើតាមព្រះយេស៊ូវគ្រីស្ទកាន់តែល្អឥតខ្ចោះឡើង ប្រសិនបើអ្នកនឹងសម្រាលបន្ទុក និងលើកស្ទួយដល់អ្នកដែលនៅជុំវិញអ្នកដែលកំពុងជួបការលំបាកដោយសេចក្ដីអាណិតអាសូរ និងដោយសប្បុរស ប្រសិនបើអ្នកនឹងព្យាយាមប្រែក្លាយជាសិស្សពិតរបស់ព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង នោះព្រះអម្ចាស់ជាព្រះនៃស្ថានសួគ៌នឹងដឹកនាំផ្លូវរបស់អ្នក ។ ទ្រង់នឹងប្រើអ្នកសម្រាប់គោលបំណងដ៏មហិមារបស់ទ្រង់ ។ ទ្រង់នឹងប្រទានពរអ្នកតាមរបៀបដែលអ្នកនឹងស្មានពុំដល់ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « God Will Use You, God Will Bless You » ដែលបានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ។*

# ផ្លាស់ប្ដូរដួងចិត្ត ផ្លាស់ប្ដូរមិត្ត

កាលខ្ញុំនៅវ័យជំទង់ ខ្ញុំមានចិត្តមិនស្ដាប់បង្គាប់ខ្លាំងណាស់ ហើយខ្ញុំបានធ្វើទង្វើនានាតាមរបៀបដែលផ្ទុយពីអ្វីដែលខ្ញុំត្រូវបានចិញ្ចឹម ។ ខ្ញុំបានចាប់ផ្ដើមផឹកគ្រឿងស្រវឹងពេលខ្ញុំអាយុ ១៣ ឆ្នាំ ហើយកាលរៀននៅវិទ្យាល័យ ខ្ញុំបានផឹកគ្រឿងស្រវឹងរៀងរាល់ចុងសប្ដាហ៍ ។

ខ្ញុំបានចូលរួមព្រះវិហារយូរ ៗម្ដង ដើម្បីកាត់បន្ថយការប្រឈមមុខជាមួយម្ដាយឪពុកខ្ញុំ ប៉ុន្តែខ្ញុំបានដេកនៅក្នុងម៉ោងប្រជុំសាក្រាម៉ង់ ហើយធ្វើដំណើរទៅឆ្នេរសមុទ្រពីមុនថ្នាក់សាលាថ្ងៃអាទិត្យចាប់ផ្ដើម ។ ខ្ញុំអាចនិយាយបានថា ឪពុកម្ដាយខ្ញុំពុំសប្បាយចិត្តនឹងឥរិយាបថរបស់ខ្ញុំឡើយ ។ ពួកគាត់គួរឲ្យសរសើរដោយសារ ពួកគេគោរពសិទ្ធិជ្រើសរើសរបស់ខ្ញុំខណៈបន្តលើកទឹកចិត្តខ្ញុំឲ្យរស់នៅតាមដំណឹងល្អ ។ ខ្ញុំនៅតែគ្មានបំណងបន្តសកម្មនៅក្នុងព្រះវិហារឡើយ ហើយខ្ញុំពិតជាពុំបានមើលឃើញពីការបម្រើបេសកកម្មនាពេលខាងមុខទេ ។

បន្ទាប់ពីបញ្ចប់វិទ្យាល័យ ខ្ញុំបានចូលរៀនសាកលវិទ្យាល័យសហគមន៍មួយ ហើយបានបន្តរបៀបមិនស្ដាប់បង្គាប់របស់ខ្ញុំ ។ ប៉ុន្តែនាអាធ្រាតយប់ជ្រៅមួយ ខ្ញុំចាំថា ខ្ញុំបានសម្រាកនៅលើសាឡុងដោយឆ្ងល់ពីអនាគតរបស់ខ្ញុំ ។ តើខ្ញុំគួររៀបអាពាហ៍ពិពាហ៍ជាមួយនារីបែបណា ? ប្រសិនបើខ្ញុំព្រងើយកន្តើយនឹងព្រះអម្ចាស់ តើខ្ញុំអាចរកផ្លូវត្រឡប់មកវិញដែរឬទេ ? ទោះបីការសម្រេចចិត្តនេះសំខាន់ក្ដី ខ្ញុំនៅតែគ្មានការជំរុញចិត្តដើម្បីផ្លាស់ប្ដូរឡើយ ។

មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានចូលរួមពិធីជប់លៀងនៅផ្ទះរបស់មិត្តខ្ញុំម្នាក់ ដែលមានស្រា និងការដុតភ្នក់ភ្លើង ។ បន្ទាប់ពីនិយាយលេងជាមួយមិត្តភក្ដិខ្ញុំមួយសន្ទុះមក ខ្ញុំបានចេញពីពួកគេមួយរយៈ ហើយបិទភ្នែករបស់ខ្ញុំ ។

ពេលខ្ញុំបើកភ្នែកវិញ ខ្ញុំបានមានគ្រាមួយដ៏ច្បាស់លាស់ ។ ខ្ញុំបានមើលមិត្តភក្ដិរបស់ខ្ញុំធ្វើទង្វើឆ្កួតលីលា ហើយខ្ញុំបានឃើញថា ខ្ញុំមិនមែនជាសមាជិកនៅក្នុងក្រុមនោះទៀតឡើយ ។ ខ្ញុំបានចាកចេញ ហើយបានសម្រេចចិត្តឈប់ផឹកស្រា និងទៅពិធីជប់លៀងផ្សេងទៀត ។ នោះមានន័យថា ខ្ញុំត្រូវផ្លាស់ប្ដូរក្រុមមិត្តរបស់ខ្ញុំ ដែលវាពុំមែនជារឿងងាយស្រួលឡើយ ។ ប៉ុន្តែខ្ញុំធ្វើបានមែន ។

ការសម្រេចចិត្តនោះបានផ្ដល់ពរដល់ជីវិតខ្ញុំ ។ ទីបំផុតខ្ញុំបានបម្រើបេសកកម្ម ហើយបានបំពេញការហៅបម្រើជាច្រើនរបស់ខ្ញុំ ។ រឿងសំខាន់បំផុតនោះ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្ត្រីដ៏អស្ចារ្យម្នាក់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ការណ៍នេះបានដឹកនាំទៅរកពរជ័យដ៏ជម្រើសបំផុតនៃជីវិតខ្ញុំ ។

ថ្មី ៗនេះ ខ្ញុំបានអានអំពីការសន្ទនារបស់អាលម៉ា និងពួកបុត្រាស្ដេចម៉ូសាយ ( សូមមើល ម៉ូសាយ ២៧ ) និងរបៀបដែលពួកគេទទួលបទពិសោធន៍នៃការផ្លាស់ប្ដូរចិត្តដ៏ធំ ( សូមមើល អាលម៉ា ៥:១២–១៤ ) បានកើតមានឡើងក្នុងផ្នែកមួយនៃការអធិស្ឋានដ៏ស្មោះត្រង់របស់អាលម៉ាជាឪពុក ។ បន្ទាប់មក ខ្ញុំបានគិតអំពីឪពុកម្ដាយខ្ញុំ ហើយបានដឹងថា បទពិសោធន៍ស្រគត់ស្រគំដែលខ្ញុំមាននៅឯពិធីជប់លៀងនោះ គឺជាលទ្ធផលផ្ទាល់នៃការអធិស្ឋានរបស់ពួកគាត់អស់រយៈពេលជាង ៣០ ឆ្នាំក្រោយមក ។

ឥឡូវនេះក្នុងនាមជាឪពុកដែលមានកូនពិបាក ខ្ញុំឃើញថា ខ្ញុំស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នាទៅនឹងអាលម៉ាជាឪពុក និងឪពុកម្ដាយខ្ញុំ ។ ប៉ុន្តែដោយការប្រដូចខគម្ពីរទៅនឹងខ្លួនខ្ញុំ នោះខ្ញុំមានសេចក្ដីជំនឿ និងសេចក្ដីសង្ឃឹមថា ថ្ងៃណាមួយកូនរបស់ខ្ញុំក៏នឹងទទួលបទពិសោធន៍នៃផ្លាស់ប្ដូរដួងចិត្តផងដែរ ។ ■

**ឈ្មោះត្រូវបានដកចេញ រដ្ឋកាលីហ្វ័រញ៉ា ស.រ.អ.**

*នៅឯពិធីជប់លៀងមួយ ខ្ញុំបានមើលមិត្តភក្ដិរបស់ខ្ញុំធ្វើទង្វើឆ្កួតលីលា ហើយខ្ញុំបានឃើញថា ខ្ញុំមិនមែនជាសមាជិកនៅក្នុងក្រុមនោះទៀតឡើយ ។*



គំនូរព្រាងដោយ ហ្គ្រេក ញូវប៊ូល

# ទីបំផុតក្ដីសុបិនរបស់ខ្ញុំក្នុងការធ្វើជាអ្នកផ្សព្វផ្សាយត្រូវបានបំពេញ

ខ្ញុំមានក្ដីសុបិនដើម្បីបម្រើបេសកកម្មពេញម៉ោងអស់ជាច្រើនឆ្នាំ ។ ប៉ុន្ដែពេលខ្ញុំទៅផ្ទះវិញបន្ទាប់ពីខ្ញុំរៀនចប់នៅសាកលវិទ្យាល័យ ខ្ញុំបានដឹងថា គ្រួសារខ្ញុំត្រូវការខ្ញុំខ្លាំងណាស់ ។ សុខភាពរបស់ឪពុកខ្ញុំទ្រុឌទ្រោម ហើយក្រុមគ្រួសារត្រូវការជំនួយផ្នែកហិរញ្ញវត្ថុខ្លាំងណាស់ ។ ក្នុងនាមជាកូនច្បងគេនៃគ្រួសារដែលមានកូនបួននាក់ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែនៅផ្ទះ ហើយជួយគ្រួសារ ។ ព្រះវរបិតាសួគ៌ប្រទានពរដល់ខ្ញុំឲ្យមានការងារសមរម្យមួយ ។ ទោះបីវាពុំបានចំណូលច្រើនក្ដី តែវាគ្រប់គ្រាន់សម្រាប់ការចំណាយរបស់ខ្ញុំ ។

ពេលណាដែលខ្ញុំត្រូវបានគេសួរអំពីការបម្រើបេសកកម្មពេញម៉ោង នោះខ្ញុំបានឆ្លើយថា ខ្ញុំនឹងទៅបម្រើ ។ ប៉ុន្ដែ គ្រប់ពេលដែលខ្ញុំនិយាយពាក្យនេះ ម្ដាយរបស់ខ្ញុំបានមើលមកខ្ញុំដោយក្ដីរំភើប លាយឡំនឹងក្ដីព្រួយនៅក្នុងក្រសែភ្នែកគាត់ ។ ខ្ញុំបានដឹងថា ប្រសិនបើខ្ញុំត្រូវបានសុំឲ្យទៅបម្រើបេសកកម្ម នោះគាត់នឹងនិយាយយល់ព្រម ហើយទុកការខ្វល់ខ្វាយអំពីការបាត់បង់ចំណូលក្នុងគ្រួសារដោយស្ងប់ស្ងាត់ក្នុងចិត្តគាត់ ។

ពីរបីឆ្នាំបានកន្លងផុតទៅ ហើយអ្នកកាន់បព្វជិតភាពស័ក្ដិសមម្នាក់បានសុំខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ខ្ញុំបានយល់ព្រម ហើយក្រោយមក យើងមានពរដែលមានកូនបីនាក់—ស្រីពីរនាក់ និងប្រុសម្នាក់ ។ អំណរដ៏ធំមហិមារបស់យើងគឺនៅពេលកូនប្រុសរបស់យើងបានចេញបម្រើបេសកកម្មរបស់គាត់ ។ វិញ្ញាណនៃការលួងលោម និងភាពសុខសាន្ដបានបំពេញក្នុងគេហដ្ឋានយើង ។ វាទំនងចំពោះខ្ញុំថា ផ្នែកមួយនៃបំណងប្រាថ្នារបស់ខ្ញុំចង់បម្រើបេសកកម្មត្រូវបានបំពេញ ។

ខ្ញុំមានចិត្តរំភើបជាខ្លាំង ពេលកូនស្រីច្បងរបស់ខ្ញុំបាននិយាយថា គាត់ក៏ចង់បម្រើបេសកកម្មផងដែរ ។ រៀងរាល់សប្ដាហ៍នៅក្នុងតំបន់បេសកកម្ម គាត់បានផ្ញើរឿងនានាអំពីកិច្ចការរបស់គាត់មកឲ្យខ្ញុំ ។ ទីបន្ទាល់របស់គាត់បានបំផុសគំនិតខ្ញុំ និងបំពេញចិត្តខ្ញុំនូវស្មារតីនៃការធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំបានអធិស្ឋានដើម្បីទទួលបានឱកាសបម្រើបេសកកម្មជារៀងរាល់ថ្ងៃ ។

ថ្ងៃមួយ ខ្ញុំទទួលការបំផុសគំនិតឲ្យសួរមិត្តម្នាក់តាមសារឯកជនមួយ នៅតាមបណ្ដាញផ្សព្វផ្សាយសង្គម ដោយសួរគាត់ថា តើគាត់ចាប់អារម្មណ៍ចង់ជួបអ្នកផ្សព្វផ្សាយសាសនាដែរឬទេ ? នាងបានឆ្លើយថា « ចាំសខ្ញុំចង់ជួប ! » ខ្ញុំបានបំពេញទម្រង់បែបបទផ្ដល់អ្នករៀនតាមអ៊ិនធើរណែតនៅគេហទំព័រ LDS.org ហើយមិនយូរប៉ុន្មានក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាបានចាប់ផ្ដើមបង្រៀនគាត់ ។ ក្នុងរយៈពេលបីខែ គាត់បានចូលជាសមាជិកសាសនាចក្រ ។ កូន ៗរបស់គាត់បានចូលជាសមាជិកសាសនាចក្រពីរបីខែក្រោយមក ។ ពេលព្រះវិញ្ញាណបានដឹកនាំខ្ញុំ នោះខ្ញុំបានអញ្ជើញមិត្តភក្ដិផ្សេងទៀតឲ្យស្ដាប់ពួកអ្នកផ្សព្វផ្សាយសាសនា ។ ពេលកូនស្រីរបស់ខ្ញុំត្រឡប់មកពីបេសកកម្មវិញ ខ្ញុំក៏មានអារម្មណ៍ថា ខ្ញុំបានបំពេញការបម្រើជាអ្នកផ្សព្វផ្សាយសាសនារយៈពេល ១៨ ខែផងដែរ ។

ព្រះវរបិតាសួគ៌បានជ្រាបដឹងពីបំណងប្រាថ្នានៃដួងចិត្តខ្ញុំ និងអ្វីដែលល្អបំផុតសម្រាប់គ្រួសារខ្ញុំ និងរូបខ្ញុំ ។ ខ្ញុំមានអំណរគុណដែលទ្រង់បានប្រទានដល់ខ្ញុំនូវបំណងប្រាថ្នាខ្ញុំ ដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនា ដែលវាបានដក់ក្នុងចិត្តខ្ញុំអស់ពេលជាយូរមកហើយ ។ ■

**ផេន ដានីយ៉ែល ដារ៉ូយ ទីក្រុងអុនតារីយ៉ូ ប្រទេសកាណាដា**




រចនារូបភាពដោយ ខាធី ដុកគ្រីល

*ការអានរឿងនានារបស់កូនស្រីខ្ញុំដែលនាងសរសេរមកពីបេសកកម្ម បានបំពេញចិត្តខ្ញុំនូវស្មារតីនៃការធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំបានអធិស្ឋានដើម្បីទទួលបានឱកាសផ្សព្វផ្សាយសាសនា ហើយបានទទួលការបំផុសគំនិតឲ្យផ្ញើសារទៅមិត្តភក្ដិរបស់ខ្ញុំ ។*



# ការធ្វើដំណើរទៅកាន់ព្រះវិហារបរិសុទ្ធរយៈពេល ៣០ ឆ្នាំរបស់យើង

*ពីមុនប្អូនប្រុសខ្ញុំចេញទៅប្រទេសស្វីស ព្រះវិញ្ញាណបានខ្សឹបប្រាប់ចិត្តខ្ញុំថា ការធ្វើដំណើរនេះនឹងនាំគាត់ឲ្យខិតកាន់តែជិតព្រះអង្គសង្គ្រោះ និងសាសនាចក្ររបស់ទ្រង់ ។*

ពីរបីខែបន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំមក ប្អូនប្រុសរបស់ខ្ញុំឈ្មោះអូស្វាលដូបានចូលជាសមាជិកព្រះវិហារមួយផ្សេងទៀត ហើយបានចូលរួមយ៉ាងសកម្មក្នុងក្រុមជំនុំនោះ ។ ប៉ុន្តែខ្ញុំចង់ឲ្យអូស្វាលដូដឹងពីអ្វីដែលខ្ញុំដឹងថាពិត ។ ជាពិសេសខ្ញុំចង់ឲ្យគាត់មានទំនាក់ទំនងជាមួយនឹងប្រសាសន៍របស់ពួកព្យាការី ។

រៀងរាល់ខែ ពេលខ្ញុំបានទទួលទស្សនាវដ្ដី *លីអាហូណា* ខ្ញុំបានចែកចាយវាជាមួយអូស្វាលដូ ។ ខ្ញុំបានផ្ដល់យោបល់ថា ប្រធានបទមួយចំនួននៅក្នុងទស្សនាវដ្ដីនេះអាចជួយគាត់ឲ្យរៀបចំខ្លួនសម្រាប់ការប្រជុំនៅក្នុងព្រះវិហាររបស់គាត់ ។ ខ្ញុំមានចិត្តរីករាយពេលគាត់បានទទួលយោបល់ខ្ញុំ ។ ប៉ុន្តែអស់ពេលជាច្រើនឆ្នាំកន្លងផុតទៅ ខ្ញុំកើតទុក្ខដែលឃើញថា ប្អូនប្រុសរបស់ខ្ញុំពុំទទួលយកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញទេ ។

នាព្រឹកមួយ អូស្វាលដូបានប្រាប់គ្រួសារយើងថា គាត់មានគម្រោងចេញពីផ្ទះយើងនៅអេក្វាឌ័រ ហើយធ្វើដំណើរទៅប្រទេសស្វីស ។ គាត់បានទទួលការប្រសិទ្ធពរមួយពីខ្ញុំនៅថ្ងៃដែលគាត់ធ្វើដំណើរនោះ ។ វាគឺជាគ្រាដ៏រំជួលចិត្តមួយសម្រាប់ខ្ញុំ ដោយសារព្រះវិញ្ញាណបានខ្សឹបប្រាប់ចិត្តខ្ញុំថា ការធ្វើដំណើរនេះនឹងនាំអូស្វាលដូឲ្យខិតកាន់តែជិតព្រះអង្គសង្គ្រោះ និងសាសនាចក្ររបស់ទ្រង់ ។

នៅក្នុងប្រទេសស្វីស អូស្វាលដូបានជួបពួកអ្នកផ្សព្វផ្សាយសាសនា ហើយទីបំផុតគាត់បានអញ្ជើញពួកគេឲ្យមកផ្ទះរបស់គាត់ ។ លុះយូរ ៗទៅគាត់បានបង្កើតទំនាក់ទំនងជិតស្និទ្ធមួយជាមួយពួកគេ ។ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា ប្រសិនបើពួកអ្នកផ្សព្វផ្សាយសាសនាលើកឡើងអំពីប្រធានបទបុណ្យជ្រមុជទឹកនោះគាត់នឹងពុំទទួលពួកគេទៀតឡើយ ។ សូមស្រមៃមើលពីភាពភ្ញាក់ផ្អើល និងអំណររបស់ខ្ញុំ ពេលខ្ញុំបានទទួលអ៊ីម៉ែលមួយពីគាត់ ប្រាប់ខ្ញុំថា គាត់បានទទួលបានបុណ្យជ្រមុជទឹកហើយ ។ ខ្ញុំចូលជាសមាជិកសាសនាចក្រក្នុងឆ្នាំ ១៩៨១ ។ អូស្វាលដូបានជ្រមុជទឹក ២០ ឆ្នាំក្រោយមកគឺនៅខែឧសភា ឆ្នាំ ២០០១ ។ គាត់បានទទួលពិធីពិសិដ្ឋផ្ទាល់ខ្លួននៅខែកក្កដា ឆ្នាំ ២០០២ ហើយគាត់បានផ្សារភ្ជាប់នឹងភរិយាគាត់នៅខែកុម្ភៈឆ្នាំ ២០០៣ ។

ពេលអូស្វាលដូបានត្រឡប់ទៅអេក្វាឌ័រវិញ គាត់បានថ្លែងទីបន្ទាល់របស់គាត់នៅក្នុងការប្រជុំសាក្រាម៉ង់មួយ ។ គាត់បាននិយាយទាំងទឹកភ្នែកថា « បងប្រុសខ្ញុំបានចែកចាយប្រសាសន៍របស់ពួកព្យាការីជាមួយខ្ញុំ ។ ប្រសាសន៍ទាំងនេះបានបំផុសគំនិតខ្ញុំ ពេលខ្ញុំបានរៀបចំខ្លួនសម្រាប់ការប្រជុំនៅក្នុងព្រះវិហារដែលខ្ញុំបានចូលរួមពីមុន ហើយមនុស្សជាច្រើនត្រូវបានស្អាងឡើងតាមរបៀបនេះ ។ ប្រសាសន៍របស់ពួកព្យាការីបានផ្លាស់ប្ដូរជីវិតខ្ញុំ ។ តាមរយៈប្រសាសន៍ទាំងនោះ ខ្ញុំបានដឹងថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទក្នុងភាពពេញលេញមាននៅលើផែនដីម្ដងទៀតជាមួយនឹងអំណាច ព្រមទាំងសិទ្ធិអំណាចផងដែរ ។

នៅខែកុម្ភៈ ឆ្នាំ ២០១១ អូស្វាលដូ និងខ្ញុំបានផ្សារភ្ជាប់ជាមួយឪពុកម្ដាយយើងនៅក្នុងព្រះវិហារបរិសុទ្ធ ហ្គូយ៉ាហ្គីល អេក្វាឌ័រ ។ ប្រសាសន៍របស់ពួកព្យាការីបានផ្ដល់ពរដល់គ្រួសារយើងអស់កល្បជានិច្ច ។ ■

**ហ្វ្រែនស៊ីស្កូ ដឃុលយូ ហៀរ៉ូ ទីក្រុងលីម៉ា ប្រទេសប៉េរូ**

គំនូរដោយ ដាន ប៊ើរ



# ទុក្ករបុគ្គល និងទីបន្ទាល់របស់ខ្ញុំ

ខ្ញុំចេះតែសង្ស័យពេលពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំអំពី យ៉ូសែប ស្ម៊ីធ និងព្រះគម្ពីរមរមន ។ ដំបូងខ្ញុំគិតថា យ៉ូសែប ស្ម៊ីធ ក៏ដូចជា « ពួកព្យាការី » ជាច្រើនទៀតផងដែរ ដែលបាននាំយកគម្ពីរក្លែងក្លាយមួយមកកាន់ពិភពលោក ដោយព្យាយាមដើម្បីក្លាយជាអ្នកមាន មនុស្សល្បីល្បាញ ឬជាវីរៈបុរស ។

ខ្ញុំគ្មានបំណងអានព្រះគម្ពីរមរមនទាល់តែសោះ ។ ប៉ុន្តែយូរ ៗទៅដោយសារមិត្តភាព និងភាពរីករាយរបស់ពួកអ្នកផ្សព្វផ្សាយសាសនាចំពោះដំណឹងល្អនោះបានធ្វើឲ្យការចង់ដឹងចង់យល់របស់ខ្ញុំពីសារលិខិតរបស់ពួកគេមានការកើនឡើង ។

ពេលខ្ញុំបានអានខគម្ពីរដែលពួកអ្នកផ្សព្វផ្សាយសាសនាបានឲ្យខ្ញុំអាននៅក្នុងព្រះគម្ពីរមរមន នោះខ្ញុំបានឃើញការអញ្ជើញរបស់មរ៉ូណៃ ឲ្យទូលសូមដល់ព្រះដោយស្មោះសរ ស្មោះអស់ពីចិត្ត និងមានសេចក្តីជំនឿលើព្រះគ្រីស្ទ ប្រសិនបើព្រះគម្ពីរមរមនពិត ( សូមមើល មរ៉ូណៃ ១០:៤–៥ ) ។ ខ្ញុំបានគិតថា « បើព្រះគម្ពីរនេះក្លែងក្លាយ តើនរណាហ៊ានអញ្ជើញយើងឲ្យសួរព្រះដោយស្មោះសរ និងស្មោះអស់ពីចិត្ត ប្រសិនបើគម្ពីរមរមនពិតឬអត់នោះ ? »

បន្ទាប់មក នៅថ្ងៃមួយពួកអ្នកផ្សព្វផ្សាយសាសនាបានពន្យល់ថា យ៉ូសែប ស្ម៊ីធ និងបងប្រុសរបស់គាត់ ហៃរ៉ុម ត្រូវបានធ្វើទុក្ករកម្មដោយសារតែទីបន្ទាល់របស់ពួកលោក ។ រំពេចនោះ គំនិតមួយបានផុសឡើងក្នុងចិត្តខ្ញុំថា ពួកលោកនឹងពុំបូជាជីវិតពួកលោកចំពោះរឿងដែលពួកលោកដឹងថាខុសឆ្គងនោះទេ ។ នៅគ្រានោះ អារម្មណ៍កក់ក្តៅមួយដូចជាភ្លើងឆេះខ្លួលខ្មាញ់បានសាយភាយពេញខ្លួនខ្ញុំ ។ វាជាទីបន្ទាល់អំពីព្រះវិញ្ញាណបរិសុទ្ធដែលបញ្ជាក់ដល់ចិត្តខ្ញុំថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីដ៏ពិត ។ ដោយសារទីបន្ទាល់នេះ ខ្ញុំបានទទួលបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ ។

ខ្ញុំត្រូវបានរំឭកអំពីបទពិសោធន៍នេះរយៈពេល ២៥ ឆ្នាំក្រោយមក ពេលខ្ញុំបានអានសុន្ទរកថាមួយរបស់អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នៅក្នុងសុន្ទរកថារបស់លោក អែលឌើរហូឡិនបានសួរប្រសិនបើ នៅក្នុងគ្រាដ៏សំខាន់នៃទុក្ករកម្មរបស់ពួកលោក យ៉ូសែប និង ហៃរ៉ុម បន្តប្រមាថនៅចំពោះព្រះ តាមរយៈការជួសជុលជីវិតរបស់ពួកលោក កិត្តិយសពួកលោក និងសេចក្តីសង្គ្រោះអស់កល្បរបស់ពួកលោកលើសៀវភៅមួយក្បាលដែលពួកលោកដឹងថាខុសឆ្គងឬ ។

« *ពួកលោកពុំធ្វើដូច្នោះទេ !* » អែលឌើរហូឡិនបានមានប្រសាសន៍ថា ៖ « ពួកលោកសុខចិត្តស្លាប់ជាជាងបដិសេធប្រភពមកពីព្រះ និងសេចក្តីពិតដ៏ពេញលេញអស់កល្បជានិច្ចនៃព្រះគម្ពីរមរមន » ។[១]

ប្រសាសន៍របស់អែលឌើរហូឡិនបានធ្វើឲ្យខ្ញុំយល់ច្រើន ហើយបានពង្រឹងទីបន្ទាល់ខ្ញុំបន្ថែមទៀតអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងអំណាចនៃព្រះគម្ពីរមរមន ។

ខ្ញុំមានអំណរគុណចំពោះព្យាការី យ៉ូសែប ស្ម៊ីធ ។ លោកបាននាំព្រះគម្ពីរមរមនចេញមក ហើយមានឆន្ទៈលះបង់ជីវិតលោកដើម្បីធ្វើជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈព្រះគម្ពីរមរមន ខ្ញុំបានដឹងច្បាស់ថា ព្រះមានព្រះជន្មរស់នៅ និងសេចក្តីស្រឡាញ់ដែលទ្រង់មានចំពោះខ្ញុំ ។ ■

**សាន់ហ៊ូ គីម មៀរ រដ្ឋម៉ារីលែន ស.រ.អា.**

**កំណត់ចំណាំ**

១. ជែហ្វ្រី អ័រ ហូឡិន« Safety for the Soul » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៨៩ ។

*ពេលខ្ញុំបានដឹងថា យ៉ូសែប ស្ម៊ីធ និងបងប្រុសរបស់លោកគឺហៃរ៉ុម ត្រូវបានគេធ្វើទុក្ករកម្ម នោះព្រះវិញ្ញាណបានបញ្ជាក់ខ្ញុំថា ពួកលោកនឹងពុំបូជាជីវិតពួកលោកចំពោះរឿងដែលពួកលោកដឹងថាខុសឆ្គងនោះទេ ។*



គំនូរដោយ ហ្គារី ស្មីធ

# យើងជឿលើការបានល្អឥតខ្ចោះ—នៅក្នុងព្រះគ្រីស្ទ

អំឡុងពេលទេសនាកថារបស់ទ្រង់នៅលើភ្នំ ព្រះយេស៊ូវបានប្រទានការត្រាស់បង្គាប់មួយដល់យើងឲ្យបានគ្រប់លក្ខណ៍ ( សូមមើល ម៉ាថាយ ៥:៤៨ ) ។ ប៉ុន្តែដោយសារយើងទាំងអស់គ្នាធ្វើកំហុស តើព្រះរំពឹងឲ្យយើងគោរពបទបញ្ញត្តិរបស់ទ្រង់តាមរបៀបណា ? តាមរយៈការទទួលបានការយល់ដឹងត្រឹមត្រូវអំពីការរំពឹងទុករបស់ព្រះសម្រាប់យើង នោះយើងអាចស្គាល់ច្បាស់ពីអ្វីដែលព្យាការីមរ៉ូណៃបានថ្លែង ពេលលោកបានមានប្រសាសន៍ថា យើងអាច « បានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ » ( សូមមើល មរ៉ូណៃ ១០:៣២–៣៣ ) ។

## តើការបានល្អឥតខ្ចោះមានន័យដូចម្ដេច ?

« ពាក្យក្រិកសម្រាប់ពាក្យ *ល្អឥតខ្ចោះ* អាចបកប្រែថា ‹ បានអភិវឌ្ឍពេញលេញ ហើយចប់សព្វគ្រប់ទាំងស្រុង › ( នៅក្នុង ម៉ាថាយ ៥:៤៨) ។ ព្រះអង្គសង្គ្រោះរបស់យើងសុំឲ្យយើងបានអភិវឌ្ឍពេញលេញ ហើយចប់សព្វគ្រប់ទាំងស្រុង—ដើម្បីឲ្យបានល្អឥតខ្ចោះនៅក្នុងគុណធម៌ និង លក្ខណៈដែលទ្រង់ និង ព្រះវរបិតាគង់នៅស្ថានសួគ៌បានបង្ហាញ » ។[១]

« ភាពល្អឥតខ្ចោះដែលព្រះអង្គសង្គ្រោះបានទតឃើញសម្រាប់យើង គឺមានច្រើនជាងគ្រាន់តែការមិនធ្វើខុសទៅទៀត ។ វាគឺជាការរំពឹងទុកដ៏អស់កល្បជានិច្ច ដូចបានបង្ហាញដោយព្រះអម្ចាស់នៅក្នុងការអធិស្ឋានអង្វរជំនួសដ៏អស្ចារ្យរបស់ទ្រង់ទៅកាន់ព្រះបិតាទ្រង់—ដើម្បីឲ្យយើងអាចបានល្អឥតខ្ចោះ ហើយអាចរស់នៅជាមួយពួកទ្រង់ក្នុងភាពអស់កល្បជានិច្ចនាពេលខាងមុខ » ។[២]

« រូបខ្ញុំផ្ទាល់ជឿថា ព្រះយេស៊ូវពុំមានព្រះរាជបំណងផ្ដល់ទេសនកថារបស់ទ្រង់អំពីប្រធានបទនេះ ដើម្បីស្ដីបន្ទោសយើងដោយសារភាពទន់ខ្សោយរបស់យើងនៅក្នុងជីវិតរមែងស្លាប់នេះនោះទេ ។ ទេ ខ្ញុំជឿថាទ្រង់មានព្រះរាជបំណងទុកវាជាកិត្តិយសចំពោះព្រះជាព្រះវរបិតា និងអ្វីដែលយើងអាចសម្រេចជាមួយទ្រង់នៅក្នុងភាពអស់កល្បជានិច្ច » ។[៣] ■

**កំណត់ចំណាំ**

១. ជេរីត ដបុលយូ ហ្គង « Becoming Perfect in Christ » *Liahona* ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៤៥ ។
២. រ័សុល អិម ណិលសុន « Perfection Pending » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៨៦ ។
៣. ជេហ្វ្រី អ័រ ហូឡិន « Be Ye Therefore Perfect—Eventually » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៤១ ។



« ការយល់ដឹងពីសេចក្ដីស្រឡាញ់ដ៏ធួនដែលព្រះអង្គសង្គ្រោះបានប្រទានដោយសេរី អាចធ្វើឲ្យយើងរួចផុតពីការរំពឹងទុកមិនត្រឹមត្រូវ ហើយមិនពិតប្រាកដ ដែលបានដាក់ដោយខ្លួនឯងស្ដីពីអត្ថន័យនៃពាក្យថាល្អឥតខ្ចោះ ។

អែលឌើរ ជេរីត ដបុលយូ ហ្គង ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Becoming Perfect in Christ » *Liahona* ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៤២ ។



*គង់នៅជាមួយខ្ញុំ* ដោយ ឌេល ភៀសុន

## អ្វីដែលព្រះវរបិតាសួគ៌ពិតជាចង់បាន

« ចូរលះបង់ចោលនូវអស់ទាំងអស់អំពើដ៏ឥតបរិសុទ្ធ ហើយស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និងអស់ពីកម្លាំងរបស់អ្នក » ( មរ៉ូណៃ ១០:៣២ ) ។

ជាមួយនឹងសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងប្រែចិត្តពេលយើងធ្វើខុស ។

រក្សាសេចក្តីសញ្ញា ឬការសន្យានានា ដែលយើងបានធ្វើជាមួយព្រះ ។

ប្រឹងឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីរក្សាព្រះបញ្ញត្តិពេញមួយជីវិតរបស់យើង ។

« ស៊ូនៅក្នុងសេចក្តីអត់ធន់ចុះ រហូតដល់អ្នករាល់គ្នាបាន ល្អឥតខ្ចោះ » ( គោលលទ្ធិ និង សេចក្តីសញ្ញា ៦៧:១៣ ) ។

## អ្វីដែលព្រះ*ពុំ*ពិតជាចង់បាន

បានល្អឥតខ្ចោះ *ក្នុងពេលនេះ !*

មានបន្ទុកដោយព្រោះតវិយាបថនៃភាពចង់បានល្អឥតខ្ចោះ ។

មិនប្រព្រឹត្តកំហុសទាល់តែសោះ ។

ធ្វើខ្លួនឲ្យមមាញឹកជាប់ជានិច្ច—ធ្វើការរហូតហើយគ្មានការកម្សាន្ត ។

ទិះតៀនខ្លួនឯងដោយសារខ្វះការរីកចម្រើន ។

ព្យាយាម « ខិតខំគ្រប់យ៉ាង » តាមរបៀបរបស់អ្នកដើម្បីទៅស្ថានសួគ៌ ។



# ជីងចក់ ចង្រិត និងពេលវេលាជាមួយកូន

ដោយ ណានសី ថូម៉ាស

*ខ្ញុំពុំធ្លាប់ស្រមៃថា ពពួកសត្វល្អូនមានឥទ្ធិពលយូរអង្វែងលើទំនាក់ទំនងរបស់ខ្ញុំជាមួយកូនប្រុសខ្ញុំសោះ ។*

ដាល្លីនកូនប្រុសខ្ញុំតែងតែចូលចិត្តសត្វល្អូន ។ ប៉ុន្តែខ្ញុំពុំដែលចូលចិត្តសត្វល្អូនទេ ។ គាត់បានទទួលការអនុញ្ញាតឲ្យមានសត្វល្អូនមួយនៅក្នុងលក្ខខណ្ឌថា សត្វអ្វីក៏ដោយដែលគាត់ជ្រើសរើសត្រូវតែមានទំហំល្មមទៅនឹងបំពង់ម៉ាស៊ីនបូមធូលី ដើម្បីកុំឲ្យវាចេញពីទ្រង់បាន ពេលកូនប្រុសខ្ញុំទៅរៀន ។ យើងបានគិតពីសត្វបីបួនក្បាល ចាប់តាំងពីកង្កែបរហូតដល់សត្វត្រកួត ពីមុនការសម្រេចចិត្តយកសត្វជីងចក់សម្បុរក្រឡេក្រឡាពណ៌ក្រម៉ៅពីរ មួយឈ្មោះហ្វូស្ស៊ និងមួយទៀតឈ្មោះដាយអែន ។

សត្វចិញ្ចឹមថ្មីរបស់ដាល្លីនបានចូលរួមជាមួយគ្រួសារយើង កាលដាល្លីនមានអាយុប្រាំពីរឆ្នាំ ។ អ្វីមួយដែលខ្ញុំមិនបានដឹងជាមុនក្នុងការធ្វើជាម្ចាស់សត្វជីងចក់នោះ គឺយើងត្រូវឲ្យសត្វចង្រិតទៅវាស៊ី—ចង្រិតរស់—ម្តងមួយសប្តាហ៍ ។ ដាល្លីន និងខ្ញុំបានធ្វើដំណើរទៅទិញ « ចង្រិតរស់ » អស់រយៈពេលជាច្រើនឆ្នាំ ។ វាពុំសូវស្រួលប៉ុន្មានទេ ជាទូទៅវាកើតឡើងរាងយប់ជ្រៅ ខណៈយើងព្យាយាមទៅឲ្យទាន់ម៉ោងពីមុនហាងសត្វចិញ្ចឹមនោះបិទទ្វារ ។

ដាយអែនរស់បានតែបីឆ្នាំប៉ុណ្ណោះ ប៉ុន្តែហ្វូស្ស៊រស់បានរយៈពេលជាច្រើនឆ្នាំ ទាំងមានសុខភាពល្អ និងរីករាយ ។ ដល់ចុងបញ្ចប់នៃថ្នាក់រៀននៅវិទ្យាល័យរបស់ដាល្លីន គាត់ត្រូវបានចាត់ឲ្យធ្វើបទបង្ហាញមួយសម្រាប់ថ្នាក់និយាយជាសាធារណៈរបស់គាត់ ។ គាត់បានសួរយោបល់ពីស្វាមីខ្ញុំ និងរូបខ្ញុំ ។ យើងបានផ្តល់យោបល់ថា គាត់ពិភាក្សាអំពីសត្វជីងចក់សម្បុរក្រឡេក្រឡានោះទៅ ដោយសារគាត់ដឹងច្រើនពីសត្វជីងចក់នោះ ហើយអាចយកហ្វូស្ស៊ទៅបង្ហាញពួកសិស្សបានឃើញផង ។ បន្ទាប់មក ដាល្លីនបានប្រាប់យើងថា ហ្វូស្ស៊បានងាប់ហើយ ។

« តើកូននិយាយមែនឬ ? តើវាងាប់តាំងពីពេលណា ? » ខ្ញុំបានសួរទាំងមិនជឿ ។

ដាល្លីនបានប្រាប់យើងថា ហ្វូស្ស៊បានងាប់សប្តាហ៍មុន ។

« វានៅក្នុងបន្ទប់កូន ប៉ុន្តែកុំព្រួយអី ។ វាពុំស្អុយទេ ។ កូនបានខ្ចប់វាទុកក្នុងថង់ពីរជាន់ » ។

បន្ទាប់ពីឃើញភាពភ្ញាក់ផ្អើលរបស់យើង ដាល្លីនបានពន្យល់ថា « កូនកំពុងធ្វើការពិសោធន៍មួយ—កូនចង់មើលវាផុយរលួយ » ។

ការពិសោធន៍របស់ដាល្លីនបង្ហាញលើសពីការគ្រាន់តែមើលពីការផុយរលួយរបស់ជីងចក់នោះទៅទៀត ។ គាត់បានពន្យាដំណើរការនោះដោយការដាក់ហ្វូស្ស៊នៅក្នុងទូរទឹកកករយៈពេលពីរសប្តាហ៍ ហើយក្រោយមកយកវាចេញទុកឲ្យរលាយទឹកកក ហើយឲ្យវាផុយរលួយបន្ថែមទៀត ។

មួយឆ្នាំក្រោយមក ពេលដាល្លីនកំពុងបម្រើបេសកកម្ម ខ្ញុំបានសម្អាតទូរទឹកកក ហើយបានឃើញហ្វូស្ស៊នៅតែនៅក្នុងថង់ពីរជាន់នៅផ្នែកខាងក្រោយទូរទឹកកកដដែល ។ ដោយសារខ្ញុំកំពុងរៀបចំឥវ៉ាន់ផ្ញើទៅដាល្លីន នោះខ្ញុំបានគិតថា វានឹងកំប្លែងណាស់ប្រសិនបើខ្ញុំផ្ញើសត្វជីងចក់ពិសោធន៍តូចនេះទៅគាត់ ។ ខ្ញុំបានដាក់ហ្វូស្ស៊នៅក្នុងប្រអប់ដោយប្រុងប្រយ័ត្ន ខ្ចប់វានៅក្នុងក្រដាសអុច ៗពងជីងចក់ពណ៌សខ្មៅ ហើយញាត់វាយ៉ាងស្អាតដាក់ក្នុងកញ្ចប់ឥវ៉ាន់របស់ដាល្លីន ដោយមានសរសេរលិខិតខ្លីមួយថា « មានអ្វីមួយដែលភ្ញាក់ផ្អើលនៅក្នុងកញ្ចប់ឥវ៉ាន់របស់កូន » ។ បន្ទាប់មក ខ្ញុំរង់ចាំចម្លើយតបរបស់គាត់ដោយអន្ទះសារ ។

គាត់បានសរសេរថា « កូនបានគិតពីជីងចក់នោះតាំងពីម៉ាក់បានផ្ញើវាមកឲ្យកូនម្ល៉េះ ។ ពុំមែនគិតច្រើនអំពីជីងចក់ពិតប្រាកដនោះទេ ប៉ុន្តែអំពីពេលវេលាទាំងអស់ដែលបានចំណាយជិះឡានរៀងរាល់សប្តាហ៍ទៅទិញចង្រិត និងធ្វើកិច្ចការផ្សេងទៀត ស្តាប់យោបល់ រឿង និងទីបន្ទាល់របស់ម៉ាក់ខណៈពេលនៅក្នុងឡាន ។ វាគឺជាហេតុផលល្អដើម្បីទៅជាមួយម៉ាក់ ហើយនិយាយជាមួយម៉ាក់ ( កាលនោះកូនពុំបាននិយាយច្រើនទេ ប៉ុន្តែកូនបានស្តាប់ច្រើនវិញ ) » ។



ការទិញចង្រិត ។ តើនរណាដឹងថាវាសំខាន់បែប នេះ ? ក្នុងនាមជាឪពុកម្ដាយ យើងពុំបានគ្រោង ពេលវេលានៃការជះឥទ្ធិពលរបស់យើងជានិច្ចនោះ ទេ ។ ជារឿយ ៗវាបានកើតឡើង ។ វាប្រហែលជា ពេលដែលយើងដាក់កូនយើងឲ្យដេកលើគ្រែនៅពេល យប់ ពេលជិះទោងស្ដីជាមួយគ្នា ឬការជិះឡានទៅធ្វើ កិច្ចការនានា ។ យើងត្រូវចំណាយពេលនៅជាមួយ កូន ៗរបស់យើង ។

ព្រះអង្គសង្គ្រោះបានបង្ហាញគំរូដ៏អស្ចារ្យស្ដីពី ការចំណាយពេលសម្រាប់កុមារ ។ បន្ទាប់ពីចំណាយ ពេលបង្រៀនពួកសាសន៍នីហ្វៃយ៉ាងយូរមក ព្រះគ្រីស្ទ បានត្រាស់បង្គាប់ឲ្យប្រជាជននាំយកកុមារតូច ៗរបស់ ពួកគេមកកាន់ទ្រង់ ។ ទ្រង់បានលុតជង្គង់ចុះនៅក្នុង ចំណោមកុមារតូច ៗ ហើយបានអធិស្ឋាន ។ បន្ទាប់ ពីទ្រង់បានអធិស្ឋានរួច ទ្រង់ព្រះកន្សែង ។ បន្ទាប់ ពីនោះមក ទ្រង់ « បានយកកូនក្មេងរបស់ពួកគេ ម្ដង ម្នាក់ ៗហើយបានប្រទានពរដល់ពួកវា ហើយបាន អធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកគេ » ( នីហ្វៃទី ៣ ១៧:២១ ) ។

កុមារទាំងនោះបានដឹងថា ព្រះយេស៊ូវស្រឡាញ់ ពួកគេ ។ ទ្រង់មានព្រះទ័យចំណាយពេលសម្រាប់ ពួកគេ ។ ទ្រង់បានស្ដាប់ពួកគេ អធិស្ឋានឲ្យពួកគេ ហើយទ្រង់បានប្រទានពរពួកគេ ។ អស់អ្នកដែលបាន ឃើញព្រឹត្តិការណ៍នេះ បានពោរពេញដោយអំណាច ដែលដំណើររឿងនេះបានកត់ត្រាថា « ភ្នែកមិនដែល ឃើញសោះ ឯត្រចៀកក៏មិនដែលបានឮរឿងដ៏មហិមា និងអស្ចារ្យ ដូចយើងបានឃើញ ហើយបានឮព្រះ យេស៊ូវ ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះវរបិតាឡើយ » ( នីហ្វៃទី ៣ ១៧:១៦ ) ។

ឥទ្ធិពលដែលព្រះយេស៊ូវគ្រីស្ទបានមានលើកុមារទាំង នោះមានយូរអង្វែងអស់ពេលជាច្រើនជំនាន់ ។ ពេល យើងដាក់ចំណាប់អារម្មណ៍ និងពេលវេលារបស់យើង ទៅលើកូន ៗយើង ទោះបីយើងត្រូវទៅជាមួយពួកគេ ដើម្បីទិញចង្រិតក្ដី ដោយក្ដីសង្ឃឹមនោះឥទ្ធិពលយើង នឹងមានយូរអង្វែងដល់រាប់ជំនាន់ផងដែរ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋមេន ស.រ.អា.*

# ពេលឪពុក ឬម្ដាយ ឬទាំងឪពុក និងម្ដាយ ពុំចូលរួមសាសនាចក្រ

**ដោយ ខាមែល នូវែល**

ប្រធាន រ័សុល អិម ណិលសុន បានចម្រើនវ័យធំឡើងនៅក្នុងផ្ទះដែលពោរពេញដោយក្ដីស្រឡាញ់ជាមួយឪពុកម្ដាយដែលលោកស្រឡាញ់ជាខ្លាំង ។ ប៉ុន្តែកាលពីនៅតូច លោកបានទៅព្រះវិហារដោយគ្មានម្ដាយ ឬឪពុកលោកទៅជាមួយលោកទេ ហើយលោកចង់ផ្សារភ្ជាប់នឹងគ្រួសារលោកក្នុងព្រះវិហារបរិសុទ្ធជាយូរមកហើយ ។[1] ប៉ុន្តែគ្មានកូនណាម្នាក់ត្រូវដើរលើផ្លូវនៃសេចក្ដីសញ្ញាតែឯងឡើយ ។ សេចក្ដីស្រឡាញ់ និងការមើលថែរបស់គ្រួសារ និងសមាជិកវួដអាចបំពេញការខ្វះចន្លោះសម្រាប់កុមារ ដែលពុំអាចមានដំណឹងល្អជួយជ្រោមជ្រែងពួកគេនៅផ្ទះ ។ ការបង្រៀនដំណឹងល្អដ៏ល្អ និងបទពិសោធន៍ល្អៗនៅផ្ទះ និងព្រះវិហារអាចជួយកុមារគ្រប់រូបឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ។



ការនិយាយទៅកាន់កុមារអំពីសេចក្ដីល្អដែលពួកគេមានទាំងនៅផ្ទះ និងព្រះវិហារ អាចជួយពួកគេឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ។

## សម្រាប់ឪពុក ឬម្ដាយដែលចូលរួមព្រះវិហារដោយពុំមានស្វាមី ឬភរិយាចូលរួមជាមួយ

១. **សូមចែកចាយពរជ័យនៃការរស់នៅតាមដំណឹងល្អ ។** ជួយកុមារឲ្យយល់ថា ការរស់នៅតាមដំណឹងល្អអាចនាំមកនូវភាពសុខសាន្ត—និងសម្រាលបន្ទុក ។ សូមពន្យល់ពីមូលហេតុដែលអ្នកជ្រើសរើសចូលរួមសាសនាចក្រ ដោយកុំនិយាយអាក្រក់ពីឪពុកម្ដាយណាម្នាក់ដែលជ្រើសរើសពុំចូលរួមព្រះវិហារ ។ សូមចែកចាយអារម្មណ៍របស់អ្នកអំពីរបៀបរក្សាសេចក្ដីសញ្ញាបុណ្យជ្រមុជទឹករបស់អ្នក ផ្ដល់ការលួងលោម និងការណែនាំដល់អ្នក ។

២. **បណ្ដុះឲ្យមានឥរិយាបទវិជ្ជមានមួយ ។** សូមជួយកុមារឲ្យឃើញពីសេចក្ដីល្អនៅក្នុងក្រុមគ្រួសាររបស់ពួកគេ ។ អ្នកក៏អាចជួយពួកគេឲ្យឃើញសេចក្ដីល្អនៅក្នុងគ្រូបង្រៀន ថ្នាក់ដឹកនាំ និងសមាជិកវួដក្នុងសាសនាចក្ររបស់ពួកគេផងដែរ ។ និយាយអំពីអ្វីដែលកូនរបស់អ្នកបានរៀននៅព្រះវិហារ ។ កុំគិតពីយោបល់ទន់ខ្សោយ ឬដែលគ្មានការយល់ចិត្តរបស់មនុស្សដទៃទឡើយ ។ ផ្ទុយទៅវិញ និយាយវិជ្ជមាន ហើយបង្ហាញឆន្ទៈដើម្បីរៀនពីមនុស្សដទៃ ។

៣. **គ្រប់គ្រងអារម្មណ៍អវិជ្ជមាន ។** សូមជួយកុមារឲ្យស្គាល់អារម្មណ៍អវិជ្ជមាន ដូចជាការភ័យខ្លាច ភាពឯកោ ការខកចិត្ត និងកំហឹង ។ បន្ទាប់មក អ្នកអាចជួយពួកគេដោះស្រាយអារម្មណ៍របស់ពួកគេតាមរយៈការគូររូបភាព ការលេងកម្សាន្ត ឬការនិយាយគ្នា ។ ប្រសិនបើចាំបាច់ អ្នកក៏អាចស្វែងរកជំនួយពីអ្នកមានវិជ្ជាជីវៈផងដែរ ។ ការព្យាបាលដួងចិត្តដែលមានរបួសនឹងជួយមនុស្សគ្រប់គ្នា ឲ្យកាន់តែងាយទទួលយក

អារម្មណ៍ខាងវិញ្ញាណ ហើយមានបទពិសោធន៍ប្រសើរឡើងនៅព្រះវិហារ ។

៤. **ប្រសិនបើចាំបាច់ សូមស្វែងរកជំនួយ ។** ប្រសិនបើអ្នកត្រូវការជំនួយ កុំរង់ចាំរហូតដល់មានគេមកសុំជួយឡើយ ។ ជួនកាលថ្នាក់ដឹកនាំសាសនាចក្រ និងសមាជិកវួដពុំអាចសង្កេតឃើញពីតម្រូវការនោះ ឬពួកគាត់ប្រហែលជាស្ទាក់ស្ទើរនឹងជួយដោយគ្មានការស្នើសុំ ។ ប្រសិនបើកុមារត្រូវការការប្រសិទ្ធពរ សូមពិចារណាប្រកបដោយការអធិស្ឋានពីបុគ្គលណាដែលអាចជួយបាន ហើយបន្ទាប់មកសូមជំនួយនោះ ។ ក៏សូមពិចារណាពីបុគ្គលដែលអ្នកអាចជួយបានផងដែរ ។

## សម្រាប់មជ្ឈិមវ័យទាំងអស់

១. **សូមសង្កេតមើល និងស្រឡាញ់កុមារដែលចូលរួមព្រះវិហារជាមួយតែឪពុក ឬម្ដាយ ឬតែម្នាក់ឯង ។** រៀនស្គាល់ឈ្មោះពួកគេ ហើយស្វាគមន៍ពួកគេដោយកក់ក្ដៅ និងសន្ដានចិត្តល្អ ។ កុំវិនិច្ឆ័យពួកគេដោយសារតែកាលៈទេសៈពួកគេ ហើយកុំសួរសំណួរអំពីអវត្តមានរបស់ឪពុកម្ដាយពួកគេឡើយ ។ ពេលកុមារទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ដោយស្មោះសរពីសមាជិកសាសនាចក្រ នោះពួកគេកាន់តែមានអារម្មណ៍ធូរស្បើយ រៀន និងទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។

២. **ត្រូវដឹងពីតម្រូវការពិសេស ។** ពេលកុមារចូលរួមព្រះវិហារជាមួយតែឪពុក ឬម្ដាយ ឬតែម្នាក់ឯង សូមគិតគូរពីរបៀបនៃការបង្រៀន ឬសកម្មភាពជាក់លាក់ដែលអាចជះឥទ្ធិពលដល់ពួកគេ ។ នៅក្នុងមេរៀនមួយស្ដីពីការប្រសិទ្ធពរបព្វជិតភាព សូមបង្រៀនថា មនុស្សគ្រប់រូបអាចទទួលបានពរជ័យទាំងនេះ ។ ប្រសិនបើសកម្មភាពមួយមានជាប់ទាក់ទងនឹងឪពុកម្ដាយ សូមរួមបញ្ចូលទាំងឪពុកម្ដាយទាំងពីរ ។ សូមស្គាល់កុមារដែលអាចមានអារម្មណ៍ងាយទទួលរងការឈឺចាប់នៅថ្ងៃពិសេសដូចជា ទិវាបុណ្យរំឭកគុណឪពុក ឬទិវាបុណ្យរំឭកគុណម្ដាយ ។

៣. **សូមជួយពួកគេឲ្យស្រឡាញ់ ហើយពង្រឹងគ្រួសាររបស់ពួកគេ ។** សូមបង្រៀនកុមារថា ក្រុមគ្រួសារត្រូវបានតែងតាំងឡើងដោយព្រះ ។[២] សូមលើកទឹកចិត្តពួកគេឲ្យមានអំណរគុណចំពោះសេចក្ដីល្អនៅក្នុងក្រុមគ្រួសារពួកគេ ។ កិច្ចការពង្សប្រវត្តិអាចជួយកុមារឲ្យដឹងថា គ្រួសាររបស់ពួកគេចាប់ផ្ដើមពីមុនពួកគេបានកើត ។ ហើយការធ្វើកិច្ចការពង្សប្រវត្តិអាចជួយផ្ដល់ពរដល់ពួកគេ « ឲ្យខិតកាន់តែជិត និងមានអំណរនៅក្នុងគ្រួសារ [ របស់ពួកគេ ] » ។[៣]

៤. **បង្រៀនគោលលទ្ធិពិតដល់ពួកគេ ។** សិទ្ធិជ្រើសរើសគឺជាគោលលទ្ធិគ្រឹះមួយនៅក្នុងផែនការនៃសេចក្ដីសង្គ្រោះ ហើយកុមារពុំទទួលខុសត្រូវចំពោះជម្រើស និងអំពើបាបរបស់ឪពុកម្ដាយឡើយ ( សូមមើល ម៉ូសេ ៦:៥៤ ) ។ បញ្ហារបស់ឪពុកម្ដាយក៏ពុំមែនជាកំហុសរបស់កូនៗពួកគេ ហើយក៏ពុំមែនជាការទទួលខុសត្រូវរបស់កុមារដើម្បីដោះស្រាយវាឡើយ ។ ការដឹងពីរឿងនេះអាចជួយកុមារឲ្យមានក្ដីបារម្ភតិចតួច អំពីរឿងដែលពួកគេពុំអាចផ្លាស់ប្ដូរបាន ហើយមានអំណរគុណដល់ពរជ័យជាច្រើនប្រចាំថ្ងៃអំពីក្រុមគ្រួសារ ។

ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយបានបង្រៀនថា ៖ « ព្រះវរបិតាសួគ៌យើង មានព្រះទ័យរីករាយដើម្បីប្រមូលផ្ដុំ ហើយប្រទានពរដល់គ្រួសារទ្រង់ ។ ផែនការរបស់ទ្រង់ ផ្ដល់ឲ្យពួកគេនូវឱកាសដើម្បីទទួលយក ឬ បដិសេធការអញ្ជើញរបស់ទ្រង់ដែរ ។ គ្រួសារគឺជាផ្នែកសំខាន់នៃផែនការនេះ » ។[៤] ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

១. សូមមើល រ័សុល អិម ណិលសុន « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៣–៩៦ ។
២. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១៤៥ ។
៣. ឃ្វីនថិន អិល ឃុក « The Joy of Family History Work » *Liahona* ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ២៧ ។
៤. ហិនរី ប៊ី អាវរីង « Gathering the Family of God » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ២០–២១ ។

### សម្រាប់កុមារ

នៅក្នុងទស្សនាវដ្ដី *ប្រិយមិត្ត* ៖

- បទពិសោធន៍ពីកុមារភាពរបស់ប្រធាន ណិលសុន ៖ « អំណរគុណចំពោះឪពុកម្ដាយ » ( ខែ មិថុនា ឆ្នាំ ២០១៩ ទំព័រ ៦២ )
- « ជំពូកថ្មីមួយ » ( ខែ មិថុនា ឆ្នាំ ២០១៩ ទំព័រ ៦៤ )
- « Steven's First Future Father's Day ( បុណ្យរំឭកគុណឪពុកនាពេលអនាគតដំបូងគេរបស់ស្ទីវិន ) » ( *Liahona* ខែ មិថុនា ឆ្នាំ ២០១៥ ទំព័រ ៧២ )

### សម្រាប់យុវវ័យ

នៅក្នុង *លីអាហូណា* ៖

- « ជីវិតគឺជាកីឡារ៉ាត់ម៉ារ៉ាតុន » ( ខែ មេសា ឆ្នាំ ២០១៩ ទំព័រ ៥៤ )

រូបថតដោយ ខាយ៉ើន ក្រៀម



## ផែនការដ៏ល្អឥតខ្ចោះ

**តើ**នៅពេលណាជាលើកចុងក្រោយគេ ដែលផែនការរបស់អ្នកបានបរាជ័យ ? សប្ដាហ៍មុនឬ ? ផែនការខ្ញុំបានបរាជ័យកាលពីសប្ដាហ៍មុន ។ មិនថាផែនការយើងល្អឥតខ្ចោះប៉ុណ្ណានោះទេ **ភាពពុំបានរំពឹងទុកបានផ្លាស់ប្ដូរនៅក្នុងជីវិតយើង** ទំនងជាកើតមានដល់មនុស្សគ្រប់គ្នា ។ ខ្ញុំពុំធ្លាប់បានគ្រោងផែនការដើម្បីរលូតកូនចំនួនបួនដងនៅចន្លោះនៃការមានកូនទាំងពីររបស់ខ្ញុំឡើយ ប៉ុន្តែខ្ញុំបានរលូតកូនបួនដង ។ ពេលផែនការដែលយើងបានដាក់ប្រកបដោយការអធិស្ឋានបានប្រែទៅជាអ្វីដែលយើងពុំបានរំពឹងទុក—ឬពុំដំណើរការសោះ—**តើយើងធ្វើដូចម្ដេច ?** នៅក្នុងបញ្ហានេះយុវមជ្ឈិមវ័យដែលមានស្ថានភាពផ្សេងៗគ្នាចែកចាយចម្លើយដែលពួកគេមានចំពោះសំណួរនេះ ពេលផែនការគ្រួសាររបស់ពួកគេពុំដំណើរការតាមការគ្រោងទុក ។

សម្រាប់ខ្ញុំ និងស្វាមីខ្ញុំ ការរលូតកូនបានធ្វើឲ្យយើងប្ដូរផែនការរបស់យើង ហើយធ្វើឲ្យយើងខូចចិត្ត ( សូមមើលទំព័រ ៤៤ ) ។ សម្រាប់ខាធើរីន និងស្វាមីគាត់ ការមើលទៅគំនិតរបស់សង្គមដើម្បីរកឃើញសំឡេងនៃព្រះអម្ចាស់ បានក្លាយជាការលំបាកមួយនៅលើផ្លូវរបស់ពួកគេ ( សូមមើលទំព័រ ៤៨ ) ។

ក្រៅពីអត្ថបទដែលមានតែជាឌីជីថល គ្រីស្ទីណាចែកចាយការភ័យខ្លាច និងការព្រួយបារម្ភរបស់គាត់អំពីការក្លាយជាម្ដាយមួយរូប ហើយប្រែអិនបានប្រាប់លម្អិតពីការចេញទៅបម្រើកងទ័ព ស្ទើរតែបញ្ចប់ផែនការគ្រួសាររបស់គាត់ និងប្រពន្ធគាត់ ។ ខាធីយុវមជ្ឈិមវ័យនៅលីវម្នាក់ផ្ដល់ការយល់ដឹង អំពីលក្ខណៈអស់កល្បនៃអត្តសញ្ញាណរបស់យើងក្នុងនាមជាឪពុកម្ដាយ ។

ទោះបីអ្នកកំពុងរង់ចាំមានកូនដើម្បីផ្ដល់ពរដល់ផ្ទះរបស់អ្នកក្ដី ការមានកូនច្រើនជាងគម្រោងដើមរបស់អ្នក ឬការរង់ចាំការរៀបអាពាហ៍ពិពាហ៍ មានអ្វីមួយដែលពិតប្រាកដ ៖ **ព្រះវរបិតាសួគ៌មានផែនការល្អឥតខ្ចោះ** ហើយទ្រង់ដឹកនាំ និងគាំទ្រយើងតាមរបៀបមួយដោយផ្ទាល់ ដោយរៀងៗខ្លួន ពេលយើងព្យាយាមសម្របឆន្ទៈយើងទៅនឹងព្រះទ័យរបស់ទ្រង់ ។

ដោយមិនគិតពីលទ្ធផល **ចំណង់ដើម្បីមានកូនមកកាន់ពិភពលោកនេះ** នឹងផ្ដល់ពរដល់យើងជាមួយនឹងការមានទស្សនវិស័យកាន់តែប្រសើរឡើង អំពីផែនការនៃសុភមង្គលដ៏មហិមារបស់ព្រះវរបិតាសួគ៌ ។ ទោះបីនៅក្នុងដំណាក់កាលណាក៏ដោយនៃការចិញ្ចឹមបីបាច់គ្រួសាររបស់អ្នកក្នុងពេលនេះ ពេលអ្នកអានរឿងរបស់យើង នោះខ្ញុំសង្ឃឹមដោយស្មោះសរថា ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នកទៅរកការយល់ដឹង ឬចម្លើយដែលអាចជួយអ្នកនៅតាមដំណើររបស់អ្នកបាន ។

សូមរីករាយនឹងការអាន !

Marianne m Bracht

# យុវមជ្ឈិមវ័យ

## ពាក្យទូន្មានល្អបំផុត. . .

*យុវមជ្ឈិមវ័យចែកចាយពាក្យទូន្មានល្អបំផុត ដែលពួកគេធ្លាប់បានទទួលអំពីការមានកូន ៖*

« ពេលយើងរៀបការដំបូង គ្រូបង្រៀនដ៏អស្ចារ្យម្នាក់បានថ្លែងថា វាគឺជាជម្រើសរវាងប្អូន និងប្ដីរបស់ប្អូន ព្រមទាំងព្រះអម្ចាស់ ។ គាត់បានព្រមានយើងថា ជារឿយៗមនុស្សនិយាយថា ការមានកូនគឺជារឿងរវាងស្វាមី និងភរិយា ហើយគ្មានព្រះអម្ចាស់ទេ ។ ការទុកទ្រង់នៅក្នុងការសម្រេចចិត្តរបស់យើង បានផ្ដល់ពរដល់យើងជាងអ្វីដែលខ្ញុំអាចថ្លែងបានទៅទៀត » ។
**—ប៉ូននី ខូនីក រដ្ឋអៃដាហូ ស.រ.អា.**

« កុំរង់ចាំរហូតដល់ ‹ គ្រាល្អឥតខ្ចោះ › ដើម្បីមានកូនឡើយ—អ្នកនឹងរង់ចាំជារៀងរហូតហើយ » ។
**—អាននី ហល ទីក្រុងឃ្វីនលែន ប្រទេសអូស្ត្រាលី**

« សូមកុំបារម្ភពីសម្ដីរបស់មនុស្សដទៃ ! រឿងនេះជារឿងរវាងអ្នក និងស្វាមី ឬភរិយាអ្នក ព្រមទាំងព្រះវរបិតាសួគ៌ ។
**—គូឡានី វែតធើរ ទីក្រុង អូខ្លេន ប្រទេសនូវែលសេឡង់**

*តើពាក្យទូន្មានល្អបំផុតអ្វីខ្លះ ដែលអ្នកធ្លាប់បានទទួលអំពីការយកឈ្នះលើទុក្ខវេទនា ? សូមផ្ញើចម្លើយរបស់អ្នកតាមរយៈ* **liahona.lds.org** *ឲ្យបានត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៩ ។*

## ចែកចាយរឿងរបស់អ្នក

តើអ្នកមានរឿងអស្ចារ្យដើម្បីចែកចាយឬទេ ? ឬតើអ្នកចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? ដូច្នេះ យើងចង់ឮពីអ្នក ! អ្នកអាចផ្ញើអត្ថបទ ឬមតិកែលម្អរបស់អ្នកតាមគេហទំព័រ **liahona.lds.org** ។

## អំពីអ្នកនិពន្ធផ្នែកយុវមជ្ឈិមវ័យ



**ម៉ារីអាន វ៉ុន ប្រាច** ចូលចិត្តពេលវេលាជាមួយគ្រួសារ តន្ត្រី និងពន្លឺព្រះអាទិត្យ ។ ជាពលរដ្ឋនៅរស់នៅរដ្ឋមីឈីហ្គេន ស.រ.អា. ជាកន្លែងដែលព្រះអាទិត្យពុំរះជានិច្ចនោះទេ គាត់ដឹងថា ពន្លឺនៃព្រះគ្រីស្ទអាចបំភ្លឺគ្រប់ថ្ងៃទាំងអស់ មិនថាថ្ងៃដែលមានពពកក្រាស់បែបណានោះទេ ។



**ខាធើរីន វ៉ាម៉ាយអើរ ឌី ភីណេដា** មកពីទីក្រុងម៉ាណាហ្គោ ប្រទេសនីការ៉ាហ្គោ ហើយបានចូលជាសមាជិកសាសនាចក្រកាលគាត់អាយុ ១៨ ឆ្នាំ ។ គាត់បានសិក្សារបៀបបង្រៀនភាសាអង់គ្លេសជាភាសាបរទេស ហើយធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយ ។ គាត់ និងស្វាមីគាត់បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ហ្គូតេម៉ាឡា ស៊ីធី ហ្គូតេម៉ាឡា ហើយមានកូនស្រស់ស្អាតបីនាក់ ។



**ខាធី ស៊ូ អែមប្លី** គិតថា ពិភពលោកនេះមានសុទ្ធតែមនុស្សល្អៗដែលគួរតែចែកចាយរឿងរបស់ពួកគេ ។ គាត់សិក្សាផ្នែកអ្នកសារព័ត៌មាន និងភាសាអេស្ប៉ាញ ដោយមានគោលដៅចង់ចែកចាយសេចក្ដីល្អ #sharegoodness ។



**ប្រែអិន ម៉ូរីល,** ភរិយា និងកូនស្រីពីរនាក់របស់គាត់ស្នាក់នៅបន្ទាយកងទ័ពជើងទឹកន័រហ្វក នៅរដ្ឋ វីជីញ៉ា ស.រ.អា. ។ ក្នុងនាមជាអនុសេនីយ៍ម្នាក់ គាត់ជាមន្ត្រីបើកបរយន្តហោះ E-២ Hawkeye ឲ្យកងទ័ពជើងទឹក ។



**គ្រីស្ទីណា គ្រូសទៀន** ទើបតែបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ។ គាត់ចំណាយពេលទំនេររបស់គាត់ដើម្បីអានសៀវភៅ និងប្រមូលសៀវភៅសម្រាប់ធ្វើបណ្ណាល័យដែលជាក្ដីសង្ឃឹមនាពេលអនាគតរបស់គាត់ ។ គាត់ និងស្វាមីគាត់កំពុងរស់នៅយ៉ាងរីករាយនៅក្នុងផ្ទះថ្មីរបស់ពួកគេនៅរដ្ឋតិចសាស ស.រ.អា. ជាមួយកូនស្រីតូចរបស់ពួកគេ ។

## នៅក្នុងវគ្គនេះ


៤៤ **ការរង់ចាំទទួលពរជ័យក្នុងជីវិត**
ដោយ ម៉ារីអាន វ៉ុន ប្រាច

៤៨ **បានទទួលពរតាមរយៈការមានកូន**
ដោយ ខាធើរីន វ៉ាម៉ាយអើរ ឌី ភីណេដា




## មានតែឌីជីថលប៉ុណ្ណោះ


**អត្តសញ្ញាណអស់កល្បជានិច្ចរបស់យើងក្នុងនាមជាឪពុកម្ដាយ**
ដោយ ខាធី ស៊ូ អែមប្លី

**តម្រូវការនៃទ័ពជើងទឹក—និងក្រុមគ្រួសាររបស់យើង**
ដោយ ប្រែអិន ម៉ូរីល

**ការយកឈ្នះលើការភ័យខ្លាចរបស់ខ្ញុំដើម្បីមានកូន**
ដោយ គ្រីស្ទីណា គ្រូសទៀន


ស្វែងរកអត្ថបទទាំងនេះ និងអ្វីៗបន្ថែមទៀត ៖

- នៅគេហទំព័រ **liahona.lds.org**
- នៅក្នុង **យុវមជ្ឈិមវ័យប្រចាំសប្ដាហ៍** ( ខាងក្រោមវគ្គ « យុវមជ្ឈិមវ័យ » នៅក្នុងកម្មវិធី Gospel Library )
- នៅគេហទំព័រ **facebook.com/liahona**

# ការរង់ចាំ ទទួលពរជ័យ ក្នុងជីវិត

ការមានបទពិសោធន៍នៃការរលូតកូនពីមួយទៅមួយទៀត ធ្វើឲ្យខ្ញុំមានអារម្មណ៍រងទុក្ខជាបន្តបន្ទាប់ក្នុងជីវិតខ្ញុំ ប៉ុន្តែពេលខ្ញុំបង្វែរវាទៅកាន់ព្រះអម្ចាស់ នោះខ្ញុំឃើញថា ការបាត់បង់កូនម្នាក់ៗ គឺមានមកជាមួយនូវភាពសុខសាន្ត ទស្សនវិស័យ និងភាពរីកចម្រើន ។





**ដោយ ម៉ារីអាន រ៉ុន ប្រាច**

ម្រាមដៃខ្ញុំបានកាន់ចង្កូតឡាន ពេលខ្ញុំសម្លឹងមើលភ្លើងក្រហមមិនដាក់ភ្នែកដោយអន្ទះសារ ។ ទីបំផុត ពេលភ្លើងនោះបានប្ដូរទៅពណ៌បៃតង ខ្ញុំបានបន្ថែមល្បឿនទៅមុខ ដើម្បីគ្រាន់តែរង់ចាំភ្លើងស្តុបមួយផ្សេងទៀតដែលហាក់ដូចជាមានពណ៌ក្រហមរហូត ។ ខ្ញុំត្រូវចំណាយពេល ១០ នាទីទៀតដើម្បីទៅដល់កន្លែងដែលត្រូវរៀនជាមួយសិស្សដែលជាអ្នកផ្សព្វផ្សាយសាសនា ដែលការបង្រៀននោះគួរតែចាប់ផ្តើមតាំងពី ៥ នាទីមុន ។ ប្រសិនបើខ្ញុំជាម្ដាយដែលមានភាពវៃឆ្លាត នោះខ្ញុំទាយថានឹងមានកំហឹងរយៈពេល ១៥ នាទីមកពីកូនស្រីអាយុជិតបីឆ្នាំរបស់ខ្ញុំ ពេលយើងចាកចេញពីផ្ទះ ប៉ុន្តែខ្ញុំពុំមែនជាម្ដាយវៃឆ្លាតទេ ។ មែនហើយ គ្មានបញ្ហាអ្វីធ្ងន់ធ្ងរឡើយ ប្រសិនបើខ្ញុំទៅយឺតនោះ ប៉ុន្តែដោយសារខ្ញុំបានព្យាយាមធ្វើកិច្ចការល្អៗនោះ តើខ្ញុំពុំស័ក្តិសមនឹងទទួលបានអ្វីដែលល្អឬ សូម្បីតែឲ្យភ្លើងស្តុប *ដំណើរការ* តាមចិត្តខ្ញុំចង់បានមិនបានទេឬ ? ពេលខ្ញុំរង់ចាំភ្លើងស្តុបមួយទៀតទាំងអន្ទះសារ នោះខ្ញុំអាចទទួលអារម្មណ៍នៃភាពស្មុគស្មាញរបស់ខ្ញុំក្ដៅឆួលឲ្យមានកំហឹងឡើង ។ « ខ្ញុំបានព្យាយាមធ្វើកិច្ចការល្អៗហើយ ខ្ញុំព្យាយាមអស់ពីសមត្ថភាពខ្ញុំហើយ ! តើជំនួយដែលខ្ញុំត្រូវការនោះនៅឯណាទៅ ? »

កាលពីម្ភៃខែមុន ខ្ញុំបានឃើញថា ខ្ញុំបានសួរសំណួរស្រដៀងគ្នានេះនៅក្នុងស្ថានភាពស្រដៀងគ្នាមួយគ្រាន់តែវានៅក្នុងកន្លែងមួយដែលខ្ញុំនៅខ្វះភាពសុខសាន្ត និងស្ងប់ស្ងាត់ ។

នៅក្នុងព្រៃពិសិដ្ឋនៅទីក្រុង ប៉ាលម៉ៃរ៉ា រដ្ឋ នូវ យ៉ោក ស្លឹកឈើទើបតែនឹងចេញពន្លកនៅលើមែកឈើពណ៌ត្នោតនៅជុំវិញខ្ញុំ ។ រុក្ខជាតិតូចៗថ្មីពណ៌បៃតងដែលដុះពាសពេញដីហាក់ដូចជាដកដង្ហើមជីវិតចេញទៅក្នុងអាកាស ។ ខ្ញុំឮតែសំឡេងស្លឹកឈើត្រូវខ្យល់ស្រទន់ ការដើរកម្សាន្ត និងសម្រឹបជើងរបស់ខ្ញុំប៉ុណ្ណោះ—គ្មានឡាន គ្មានផ្លូវ គ្មានសំឡេងសន្ទនាគ្នាឮៗឡើយ ។ ប៉ុន្តែទោះបីជាមានភាពស្ងប់ស្ងាត់ក្ដី ចិត្តខ្ញុំបានពោរពេញទៅដោយសំណួរ និងភាពមិនប្រាកដប្រជា ។ ស្វាមីខ្ញុំឡែន និងខ្ញុំ បានរង់ចាំយ៉ាងលំបាកអស់ពេល ៧២ ម៉ោង ដើម្បីចាំស្ដាប់វេជ្ជបណ្ឌិតរបស់ខ្ញុំទូរសព្ទប្រាប់ពីលទ្ធផលនៃការពិនិត្យអេកូ និងតេស្តឈាមនៅនាទីចុងក្រោយ ។ ខ្ញុំចង់ទទួលបានចម្លើយ និងការលួងចិត្តយ៉ាងខ្លាំង ។

## *ការទទួលការលួងលោម*

*« ព្រះអម្ចាស់ទ្រង់បានយាងមករកគេដោយព្រះវិញ្ញាណរបស់ទ្រង់ ហើយមានព្រះបន្ទូលទៅគេថា ៖ ចូរក្សាន្តចិត្តចុះ ។ ហើយពួកគេក៏បានក្សាន្តចិត្តទៅ » ( អាលម៉ា ១៧:១០ )* ។

ខ្ញុំបានឃើញថា ខ្ញុំបានសម្លឹងមើលរងផ្កាដែលនៅរស់ក្នុងរដូវរងារ នៅខាងក្រៅព្រះវិហារបរិសុទ្ធ ប៉ាលម៉ៃរ៉ា នូវ យ៉ោក ។ ចិត្តខ្ញុំពោរពេញដោយសំណួរដែលខ្ញុំបានគិតអំពីវា ៖ « ប្រសិនបើខ្ញុំរលូតកូននេះ តើបន្ទាប់ទៀតមានអ្វីកើតឡើងទៅ ? ហេតុអ្វី ? » ពេលខ្យល់នៃរដូវផ្ការីកបក់ជុំវិញខ្ញុំ ព្រះអម្ចាស់បានមានបន្ទូលលួងលោមមកក្នុងចិត្តខ្ញុំ ដែលខ្ញុំប្រាថ្នាចង់បាន ។ ខ្ញុំលែងត្រូវការវេជ្ជបណ្ឌិតប្រាប់ខ្ញុំឲ្យដឹងទៀតហើយ ខ្ញុំបានដឹងថា ខ្ញុំនឹងរលូតកូននេះ ប៉ុន្តែរំពេចនោះ ខ្ញុំបានយល់ថា ព្រលឹងដ៏តូចនេះគឺនៅក្នុងព្រះហស្តល្អឥតខ្ចោះ ព្រះហស្តពោរពេញដោយក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ។ ភ្លាមនោះ ភាពអស់សង្ឃឹមដែលមានក្នុងចិត្តខ្ញុំ បានជំនួសដោយភាពសុខសាន្តដែលបានបញ្ជាក់គាំទ្រខ្ញុំពេញប៉ុន្មានសប្ដាហ៍ និងខែក្រោយមក ។

## *ការរង់ចាំពន្លឺពណ៌បៃតង*

*« ខ្ញុំអរគុណចំពោះព្រះអម្ចាស់ដែលបានយាងមករកខ្ញុំតាមវិធីជាច្រើន ជាមួយព្រះដ៏ជាជំនួយ ពេលខ្ញុំត្រូវការភាពសុខសាន្ត ។ ប៉ុន្តែព្រះវរបិតាសួគ៌របស់យើងពុំខ្វល់ព្រះទ័យតែអំពីការក្សាន្តចិត្តរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែខ្វល់ព្រះទ័យកាន់តែខ្លាំងអំពីការរីកចម្រើនឡើងរបស់យើង » ។[១]*
*—ប្រធាន ហិនរី ប៊ី អាវរិង*

បីបួនថ្ងៃបន្ទាប់ពីទៅលេងទីក្រុងប៉ាល់ម៉ៃរ៉ា ខ្ញុំបានរលូតកូនដែលធ្វើឲ្យចិត្តខ្ទេចខ្ទាំជាខ្លាំង ។ ទោះបីជាអារម្មណ៍នៃភាពសុខសាន្តបានបន្តគាំទ្រខ្ញុំក្ដី ខ្ញុំមានអារម្មណ៍ថា ទន់ខ្សោយទាំងផ្នែករាងកាយ និងអារម្មណ៍ ដោយសារការបាត់បង់ និងការពុំបានរៀបចំសម្រាប់ការរង់ចាំដែលបានកើតឡើងបន្ទាប់មកទៀត ។ ដំបូងខ្ញុំបានរង់ចាំលទ្ធផលពីមន្ទីរពិសោធន៍ ដែលបានបង្ហាញថា វាជាការមានផ្ទៃពោះកម្រកើតមានមួយ ជាការមានផ្ទៃពោះកូនពង ។ បន្ទាប់មក ខ្ញុំរង់ចាំតេស្តឈាមប្រចាំសប្តាហ៍ ពីរសប្តាហ៍ម្តង ហើយទីបំផុតប្រចាំខែ ដើម្បីប្រាកដថា គ្មានសញ្ញានៃមហារីកទេ ។ ទោះបីជារង់ចាំអស់ពេលជាច្រើនខែក្តី ឡែន និងខ្ញុំអាចឃើញជំនួយពីព្រះអម្ចាស់យ៉ាងងាយ ក្នុងការលួងលោម និងអះអាងដល់យើងនៅអំឡុងគ្រានោះ ។ ការមានផ្ទៃពោះពងកូនពុំមានឥទ្ធិពលយូរអង្វែងឡើយ ហើយបន្ទាប់ពីប្រាំមួយខែបន្ទាប់មកទៀត វេជ្ជបណ្ឌិតរបស់ខ្ញុំបាននិយាយថា យើងអាចព្យាយាមយកកូនមួយទៀតបាន ។ ខ្ញុំបានត្រឡប់មកលើផ្លូវនៃភាពរីកចម្រើនក្នុងជីវិតខ្ញុំ ទីបំផុតភ្លើងបានដូរពីពណ៌ក្រហមទៅជាពណ៌បៃតងវិញ ។

ប៉ុន្តែគ្រាន់តែបីខែ និងតេស្តឈាមបីបួនដងមក ខ្ញុំបានរលូតកូនម្តងទៀត—លើកនេះវាកើតឡើងតែមួយសប្តាហ៍មុនបុណ្យគ្រីស្ទម៉ាស់ប៉ុណ្ណោះ ។ បីខែទៀតបានកន្លងផុតទៅ ហើយក្តីសង្ឃឹមរបស់ខ្ញុំបានមានឡើងវិញ បន្ទាប់ពីធ្វើតេស្តថា ខ្ញុំមានផ្ទៃពោះម្តងទៀត តែមួយសប្តាហ៍ក្រោយមកខ្ញុំបានរលូតកូនទៀត—ជាភ្លើងស្តុបម្តងទៀត ។

## *ការដាក់សេចក្តីជំនឿទៅនឹងការសាកល្បង*

*« ទោះជាយើងមានជំនឿរឹងមាំក្តី ក៏មានភ្នំជាច្រើននឹងពុំរំកិលចេញដែរ ។ . . . ប្រសិនបើរាល់ការផ្តួយទាំងអស់ ត្រូវបានកាត់បន្ថយ ប្រសិនបើរាល់ការឈឺចាប់ត្រូវបានដកចេញ នោះគោលបំណងសំខាន់នៃផែនការរបស់ព្រះវរបិតា នឹងត្រូវបំផ្លាញហើយ » ។[២] —អែលឌើរ ដាវីឌ អេ បែដណា*

ខ្ញុំបានមានផ្ទៃពោះម្តងទៀត ហើយថ្ងៃកំណត់ឆ្លងទន្លេរបស់ខ្ញុំគឺជៀកនឹងបុណ្យគ្រីស្ទម៉ាស់បន្ទាប់ ។ ខ្ញុំមានអារម្មណ៍ល្អនឹងការមានផ្ទៃពោះលើកនេះ ។ យើងបានឃើញចង្វាក់បេះដូងកូននៅលើកដំបូងនៃការពិនិត្យអេកូ ហើយបានដឹងថា សមាជិកគ្រួសារយើងបានអធិស្ឋានសម្រាប់យើង ។ អំឡុងពេលយើងអង្គុយនៅក្នុងវគ្គអំណោយទានពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធនាថ្ងៃមួយ ខ្ញុំបានមានគំនិតប្លែកជាច្រើន ៖ « ប្រសិនបើខ្ញុំនឹងរលូតកូននេះ តើសេចក្តីជំនឿរបស់ខ្ញុំនឹងបន្តរឹងមាំដែរឬទេ ? ប្រាកដណាស់ សេចក្តីជំនឿខ្ញុំនៅតែរឹងមាំ ។ ប៉ុន្តែប្រាកដណាស់ ខ្ញុំពុំរលូតកូនទៀតឡើយ ដោយសារលើកនេះ ខ្ញុំបានត្រៀមទទួលយកព្រះទ័យរបស់ព្រះអម្ចាស់ទោះវាជាអ្វីក៏ដោយ » ។

ទោះបីខ្ញុំមានឥរិយាបថវិជ្ជមានក្តី បីបួនសប្តាហ៍ក្រោយមក ខ្ញុំបានឃើញរោគសញ្ញារលូត ខ្ញុំបានទៅពិនិត្យអេកូ ហើយបានចាប់ផ្តើមដំណើរការនៃឈឺចាប់ដែលខ្ញុំបានធ្លាប់ទទួលទាំងអស់ ។ សេចក្តីជំនឿពុំបានរឹងមាំដូចខ្ញុំបានរំពឹងទុកឡើយ ។ ចម្លើយដែលគាំទ្រខ្ញុំកាលពីការរលូតកូនពីមុនៗរបស់ខ្ញុំហាក់ដូចជាពុំគ្រាប់គ្រាន់ឡើយ ។ ការបាក់ទឹកចិត្តបានមានក្នុងចិត្តខ្ញុំ ។ ខ្ញុំមានអារម្មណ៍ថា ខូចចិត្ត ទទេស្អាត ហើយត្រូវគេក្បត់ទៀតផង ។ ស្វាមីខ្ញុំ និងខ្ញុំពុំមែនជាមនុស្សតែមួយគត់ដែលរង់ចាំព្រះអម្ចាស់ឡើយ ជារឿយៗកូនស្រីរបស់យើងបានប្រាប់យើងថា គាត់ចង់បានប្អូនប្រុស ឬប្អូនស្រីម្នាក់ខ្លាំងណាស់ ។ យើងក៏ឈឺចិត្តជំនួសនាង ។ ពេលខ្ញុំបង្ហូរអារម្មណ៍ទន់ខ្សោយនោះថ្វាយទៅព្រះអម្ចាស់ក្នុងការអធិស្ឋានដ៏ស្មោះសរ នោះខ្ញុំបានទទួលសាក្សីយ៉ាងច្បាស់ម្តងទៀតថា ព្រះវរបិតាសួគ៌ជ្រាបដឹងពីការឈឺចាប់ និងកាលៈទេសៈរបស់ខ្ញុំ ហើយទ្រង់ស្រឡាញ់ខ្ញុំ ។ ទោះបីកាលៈទេសៈរបស់ខ្ញុំនៅដដែលក្តី បទពិសោធន៍ដ៏ផ្អែមល្ហែម និងសាមញ្ញប្រកបដោយអព្ភូតហេតុនេះ បានសម្រាលបន្ទុកដែលខ្ញុំមាន ហើយផ្តល់លទ្ធភាពឲ្យខ្ញុំដោះស្រាយ ហើយមានអារម្មណ៍រីករាយ ពេលខ្ញុំបានបន្តហែលឆ្លងកាត់ក្នុងជីវិតពីមួយថ្ងៃទៅមួយថ្ងៃ ។ ទោះជាថ្ងៃអនាគតមានសភាពបែបណាក្តី ខ្ញុំនឹងមិនកើតអ្វីទេ ។

ពេលការធ្វើតេស្តផ្នែកស្បែនដែលគ្មានចម្លើយបានត្រឡប់មកវិញក្នុងរយៈពេលបីបួនខែក្រោយមក នោះយើងមានអារម្មណ៍ច្របូកច្របល់ម្តងទៀតអំពីគោលបំណងនៃឧបសគ្គទាំងនេះដែលកើតឡើងក្នុងជីវិតយើង ។ ខ្ញុំបានព្យាយាមអស់ពីលទ្ធភាពខ្ញុំដើម្បីដាក់បំណងខ្ញុំផ្ទាល់មួយអន្លើ ហើយសម្របឆន្ទៈខ្ញុំជាមួយនឹងព្រះទ័យរបស់អម្ចាស់ ប៉ុន្តែអំឡុងពេលនៃគ្រាលំបាកនេះ ចិត្តខ្ញុំបានស្រែកឡើងថា « តើខ្ញុំគួរតែរៀនអ្វីពីបទពិសោធន៍នេះ ? ខ្ញុំកំពុងព្យាយាមធ្វើកិច្ចការល្អៗហើយ ! តើជំនួយដែលខ្ញុំត្រូវការនោះនៅឯណាទៅ ? »

## *ការផ្លាស់ប្តូរប្រតិកម្មរបស់ខ្ញុំ*

« *ការលំបាកគឺជា* រឿងដែលមានជាប់ជានិច្ច ! *យើងទាំងអស់គ្នាមានឧបសគ្គ ។* អ្វីដែលប្រែប្រួល *គឺជាប្រតិកម្មយើងចំពោះភាពលំបាកនោះ » ។[៣] —អែលឌើរ ស្តែនលី ជី អេលីស*





ប្រាំបីខែបន្ទាប់ពីការរលូតកូនលើកទីបួនរបស់ខ្ញុំមក និងបីបួនសប្ដាហ៍បន្ទាប់ពីការបើកឡានទាំងចប់បារម្ភក្នុងចិត្ត ទៅជួបស៊ីស្ទើរជាអ្នកផ្សព្វផ្សាយសាសនាមក ខ្ញុំបានរង់ចាំដោយសុខសាន្តនៅភ្លើងស្តុបមួយតាមផ្លូវត្រឡប់មកផ្ទះខ្ញុំវិញ ពេលចម្លើយរបស់ខ្ញុំត្រូវបានឆ្លើយតប ។ ពេលខ្ញុំបានមើលទៅឡានជាច្រើនដែលឈប់នៅជាប់នឹងខ្ញុំ និងឡានដែលបើកនៅមុខឡានខ្ញុំ ខ្ញុំបានទទួលទស្សនវិស័យអស់កល្បមួយអំពីជីវិតខ្ញុំ ។ ភ្លាមនោះខ្ញុំបានដឹងថា អ្វីៗទាំងអស់ដែលសំខាន់នៅក្នុងជីវិតខ្ញុំគឺថា ខ្ញុំបន្តនៅលើផ្លូវដែលនឹងនាំខ្ញុំត្រឡប់ទៅផ្ទះសួគ៌របស់ខ្ញុំវិញ ។ ការរង់ចាំនៅ « ភ្លើងស្តុប » ប៉ុន្មានដងក៏ដោយ ក៏វាមិនប៉ះពាល់ដល់ទិសដៅរបស់ខ្ញុំដែរ ។ ប៉ុន្តែរបៀបដែលខ្ញុំឆ្លើយតបចំពោះរឿងទាំងនោះទេដែលវាប៉ះពាល់ដល់ទិសដៅខ្ញុំ ។

ខ្ញុំបានចាប់ផ្ដើមរីករាយនៅគ្រប់ការរង់ចាំពរជ័យនានានៅក្នុងជីវិតខ្ញុំ ទាំងការប្រៀបធៀប និងពិតប្រាកដ ។ ជំនួសឲ្យការខ្ជះខ្ជាយពេលវេលា ឱកាសនីមួយៗតម្រូវឲ្យមានភាពអត់ធ្មត់ ហើយទទួលទស្សនវិស័យដែលកើតមានបានតែតាមរយៈការរង់ចាំតែប៉ុណ្ណោះ ។ គឺដូចជាគ្រប់ពេលដែលភ្លើងចរាចរណ៍ពណ៌ក្រហមត្រូវជាគូនឹងភ្លើងពណ៌បៃតងនៅក្នុងទិសដៅផ្សេងគ្នាក្ដី ខ្ញុំបានរកឃើញថា គ្រប់ការរង់ចាំក្នុងជីវិតរបស់ខ្ញុំ បានបើកឱកាសសម្រាប់ភាពរីកចម្រើន គ្រាន់តែវាមិនចាំបាច់តែតាមរបៀបដែលខ្ញុំបានគ្រោងទុកដើម្បីរីកចម្រើនតែប៉ុណ្ណោះ ។ ជាជាងការបន្តមានការខកចិត្ត ខ្ញុំបានចាប់ផ្ដើមរីករាយនៅក្នុងឱកាសសម្រាប់ការរីកចម្រើន ដែលគ្រប់ការផ្លាស់ប្ដូរព្រឹត្តិការណ៍នានាដែលពុំបានរំពឹងទុកបានកើតឡើង ។

## *ផ្ដោតទៅលើព្រះអង្គសង្គ្រោះ*

*« សំណួរសំខាន់មួយដើម្បីពិចារណានោះគឺ ‹ តើយើងដាក់សេចក្ដីជំនឿរបស់យើងនៅទីណា ? › តើសេចក្ដីជំនឿរបស់យើងផ្ដោតទៅលើការចង់បានដ៏ងាយស្រួល ដើម្បីឲ្យបានធូរស្បើយពីការឈឺចាប់ និងការរងទុក្ខ ឬសេចក្ដីជំនឿយើងផ្ដោតយ៉ាងរឹងប៉ឹងលើព្រះជាព្រះវរបិតា និងផែនការដ៏បរិសុទ្ធរបស់ទ្រង់ និងលើព្រះយេស៊ូវជាព្រះគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ដែរឬទេ ? »[៤] —អែលឌើរ ដូណាល អិល ហាលស្ត្រម*

រយៈពេលពីរឆ្នាំដ៏យូរបន្ទាប់ពីការរលូតកូនដំបូងរបស់ខ្ញុំមក ខ្ញុំបានផ្ដល់កំណើតដល់កូនប្រុសម្នាក់ដ៏ស្រស់ស្អាតដែលមានសុខភាពល្អ ។ នៅក្នុងគ្រាដែលនាំទៅរកថ្ងៃនៃអំណរសម្រាប់គ្រួសារយើង នោះខ្ញុំបានដឹងថា ព្រះយេស៊ូវគ្រីស្ទពុំបានរងទុក្ខសម្រាប់ខ្ញុំ ដើម្បីដកយកការរងទុក្ខទាំងអស់ចេញពីជីវិតខ្ញុំឡើយ ។ ផ្ទុយទៅវិញ ទ្រង់បានរងទុក្ខដើម្បីខ្ញុំអាចត្រូវបានពង្រឹង និងរីកចម្រើនពីឧបសគ្គដែលខ្ញុំជួបវិញ ។ ទោះបីជាក្នុងគ្រានៃការខូចចិត្តចំពោះការបាត់បង់ និងរយៈពេលរង់ចាំរាប់ខែដ៏យូរនៅតែចងចាំដោយក្ដីឈឺចាប់ក្ដី វាបានក្លាយជារតនៈសម្បត្តិនៅក្នុងជីវិតខ្ញុំ ។ នៅក្នុងគ្រាពិសិដ្ឋទាំងនោះ ខ្ញុំបានយល់ច្បាស់ពីរបៀបដែលព្រះអង្គសង្គ្រោះជ្រាបពីការរងទុក្ខនីមួយៗរបស់ខ្ញុំ ។ ទ្រង់បានសង្គ្រោះខ្ញុំតាមរបៀបមួយ ដែលខ្ញុំមានតែបុគ្គលម្នាក់ដែលដឹងពីក្ដីទុក្ខផ្ទាល់របស់ខ្ញុំប៉ុណ្ណោះ ដែលអាចសង្គ្រោះខ្ញុំបាន ។ ខណៈដែលការផ្ទុយនៅក្នុងជីវិតយើងហាក់ដូចជារាំងផែនការរីកចម្រើនរបស់យើង នោះព្រះអម្ចាស់ប្រើការផ្ទុយនោះដើម្បីជំរុញយើងឲ្យឆ្ពោះទៅមុខទៅកាន់ទីដ៏ខ្ពស់ជាង—ដោយការស្គាល់ និងការនៅជាប់នឹងសេចក្ដីស្រឡាញ់របស់ទ្រង់ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋគិចសាស ស.រ.អា. ។*

**កំណត់ចំណាំ**


១. ហិនរី ប៊ី អាវរិង « My Peace I Leave with You » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័ ១៧ ។
២. ដេវីឌ អេ បែដណា « Accepting the Lord’s Will and Timing » *Liahona* ខែ សីហា ឆ្នាំ ២០១៦ ទំព័រ ២២ ។
៣. ស្ទែនលី ជី អេលីស « Do We Trust Him? Hard Is Good » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១១៣ ។
៤. ដូណាល អិល ហាលស្ត្រម « តើឈប់មានថ្ងៃនៃអព្ភូតហេតុហើយឬ ? » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៩០ ។



មនុស្សជាច្រើនបានមានការសង្ស័យពីយើងដែលចេះតែមានកូនថែមទៀត ប៉ុន្តែតាមរយៈកូនរបស់យើង យើងអាចយល់បានប្រសើរឡើងពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ហើយអភិវឌ្ឍសក្ដានុពលនៃភាពជាព្រះរបស់យើង ។

# បានទទួលពរតាមរយៈការមានកូន

**ដោយ ខាធើរីន រ៉ាម៉ាយអើរ ឌី ភីណេដា**

តើនេះជាកូនពៅរបស់អ្នកឬ ? » ដោយមានកូនពីរនាក់អាយុក្រោមប្រាំឆ្នាំរួចទៅហើយ នោះពេលខ្ញុំមានផ្ទៃពោះកូនទីបី ជារឿយៗមនុស្សហាក់ដូចជាមានគំនិតមួយអំពីកូនរបស់យើង ។ « តើនេះជាកូនពៅរបស់អ្នកឬ ? តើអ្នកគិតថា វាមិនលឿនពេកទេឬអី ? តើអ្នកនឹងធ្វើអ្វីជាមួយកូនទាំងបីនាក់នោះ ? » ទាំងនេះគឺជាសំណួរដែលខ្ញុំឮជារឿយ ។ ទោះបីវាជារឿងអាចយល់បានក្ដី ជារឿយៗប្រជាជននៅក្នុងប្រទេសខ្ញុំមានកូនតែម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ដោយសារតែបញ្ហាសេដ្ឋកិច្ចអ្វីដែលគេពុំដឹងនោះគឺថា ពេលស្វាមីខ្ញុំ និងខ្ញុំបានណាត់ដើរលេងជាគូរនោះ យើងបាននិយាយអំពីចំនួនកូនដែលយើងចង់បាន និងពេលវេលាដែលយើងចង់បានពួកគេ ។ ផែនការគ្រួសារគឺជារឿងសំខាន់ ហើយជាការសម្រេចចិត្តសំខាន់មួយចំពោះពួកយើង ដូច្នេះវាត្រូវធ្វើឡើងរវាងយើងទាំងពីរនាក់ ដោយស្វែងរកការណែនាំពីព្រះជានិច្ច ។ យើងបានស្ដាប់ព្រះវិញ្ញាណ ជាជាងស្ដាប់មនុស្សដែលនៅជុំវិញយើង ហើយយើងមានពរដោយការមានកូន ។

ពេលព្រះអម្ចាស់បានធ្វើសេចក្ដីសញ្ញាមួយជាមួយអ័ប្រាហាំ ទ្រង់បានសន្យាថា លោកនឹងមានកូនច្រើន ( សូមមើល លោកុប្បត្តិ ១៧:៥–៦; ២២:១៧ ) ។ តាមរយៈវគ្គបទគម្ពីរនោះ យើងបានទទួលអារម្មណ៍ថាចំពោះព្រះវរបិតាសួគ៌យើង ការមានកូនគឺជាពរជ័យមួយដ៏អស្ចារ្យបំផុតដែលយើងអាចទទួល ។ តាមរយៈកូនរបស់យើង យើងអាចយល់បានប្រសើរឡើងពីសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌យើង ហើយយើងអភិវឌ្ឍសក្ដានុពលនៃភាពជាព្រះរបស់យើង ។ ពេលអ្នកមានកូន អ្នកពុំគ្រាន់តែជួយវិញ្ញាណទាំងនោះដែលនៅក្នុងជីវិតមុនឆាកជីវិតនេះឲ្យមកកាន់ផែនដី ហើយទទួលរូបរាងកាយប៉ុណ្ណោះទេ អ្នកក៏ថែមទាំងមានឯកសិទ្ធិនៃការបង្រៀនដំណឹងល្អដល់ពួកគេផងដែរ ។ ខ្ញុំជឿថាចំណុចពីរបីនៅក្នុងជីវិតយើងរៀបចំយើងកាន់តែប្រសើរឡើងសម្រាប់ជីវិតអស់កល្បជានិច្ច ជាងការមានកូន ។ ក្រុមគ្រួសារយើងគឺជាកន្លែងល្អបំផុតដែលយើងរៀនអនុវត្តបុគ្គលិកលក្ខណៈរបស់ព្រះអម្ចាស់ ។ ឥឡូវនេះ ខ្ញុំគឺជា



ម្ដាយមួយរូប ខ្ញុំត្រូវបានរំឭកពីសារៈសំខាន់ដើម្បីបន្តនៅជិតនឹងព្រះវរបិតាសួគ៌ខ្ញុំប្រចាំថ្ងៃ ។ ខ្ញុំអធិស្ឋានគ្រប់ពេលទូលសូមការណែនាំ កម្លាំង និងការអត់ធ្មត់ ហើយថ្លែងអំណរគុណទ្រង់សម្រាប់ពរជ័យជាច្រើន ដែលកើតឡើងជាមួយនឹងការមានកូន ។

ភាពជាឪពុកម្ដាយគឺជាបទពិសោធន៍ផ្លាស់ប្ដូរជីវិតមួយដែលពោរពេញដោយឧបសគ្គមួយចំនួន ប៉ុន្តែក៏មានអំណរជាច្រើនផងដែរ ។ គ្រប់ពេលដែលខ្ញុំស្ដាប់កូនស្រីច្បងរបស់ខ្ញុំច្រៀងចម្រៀងថ្នាក់អង្គការបឋមសិក្សា ឬមើលកូនប្រុសអាយុពីរឆ្នាំរបស់ខ្ញុំ ព្យាយាមបិទភ្នែកគាត់អំឡុងពេលអធិស្ឋានជាគ្រួសាររបស់យើង ឬពេលខ្ញុំបីកូនប្រុសខ្ញុំដែលកំពុងដេកនៅក្នុងរង្វង់ដៃខ្ញុំ នោះខ្ញុំមានអារម្មណ៍ថា ចិត្តខ្ញុំពោរពេញដោយអំណរដែលពុំអាចថ្លែងបាន ។ កូនៗរបស់យើងគឺជាកម្លាំងដែលបន្តឲ្យយើងស៊ូទ្រាំរហូតដល់ទីបញ្ចប់ ទោះបីជាមានឧបសគ្គច្រើនប៉ុណ្ណាដែលយើងប្រឈមមុខក្នុងជីវិតក្ដី ។ ខ្ញុំពិតជាមានអំណរគុណចំពោះព្រះវរបិតាសួគ៌ខ្ញុំចំពោះការផ្ដល់ឱកាសដើម្បីក្លាយជាម្ដាយនៃកូនៗរបស់ខ្ញុំ ។

ខ្ញុំដឹងថា ព្រះវរបិតាសួគ៌របស់យើងស្រឡាញ់យើង ។ ខ្ញុំបានទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ទ្រង់ អំឡុងពេលនៃគ្រាដ៏ផ្អែមល្ហែមនៃសុភមង្គលយូរអង្វែងដ៏ពិត និងអំឡុងពេលនៃការសាកល្បងរបស់យើង ។ ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីបង្ហាញយើងនូវផ្លូវដែលត្រឡប់ទៅកាន់ផ្ទះសួគ៌ារបស់យើងវិញ ។ ខ្ញុំស្រឡាញ់គ្រួសាររបស់ខ្ញុំ ហើយខ្ញុំដឹងថា ក្រុមគ្រួសារអាចនៅជុំគ្នាជានិរន្តរ៍ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុងម៉ាណាហ្គេ ប្រទេសនីការ៉ាហ្គេ ។*



# នៅសាលាដែលខ្ញុំទៅរៀនសព្វថ្ងៃនេះ

មានសមាជិកតិចតួចណាស់ ។ ដូច្នេះវាមានសារៈសំខាន់ដើម្បីរស់នៅតាមបទដ្ឋានរបស់ខ្ញុំ ដោយសារវាគឺជារបៀបតែមួយគត់សម្រាប់ឲ្យពន្លឺនៃដំណឹងល្អបានបញ្ចាំងចេញទៅតាមរយៈខ្ញុំ ដើម្បីឲ្យអ្នកមិនមែនជាសមាជិកអាចរកឃើញផ្លូវរបស់ពួកគេទៅកាន់សាសនាចក្រនៅទីបំផុត ។ ប្រហែលវាពុំមែនជាពេលឥឡូវនេះទេ ប៉ុន្តែថ្ងៃណាមួយ ពួកគេនឹងចងចាំថា មានក្មេងប្រុសចម្លែកម្នាក់នេះដែលមិនផឹកតែទឹកកក និងកាហ្វេ មិនជេរ នោះគឺជាសមាជិកនៃព្រះវិហារមួយ ។ ប្រហែលជាថ្ងៃណាមួយគំរូរបស់ខ្ញុំនឹងដឹកនាំពួកគេទៅកាន់កន្លែងដែលពួកគេត្រូវទៅ ។

វាអាចជាការពិបាកដើម្បីធ្វើខ្លួនខុសពីគេ ដើម្បីឈរយ៉ាងរឹងប៉ឹង ។ វាងាយស្រួលដើម្បីទម្លាក់បទដ្ឋានចោល ។ គំរូ និងការអធិស្ឋានរបស់គ្រួសារខ្ញុំពិតជារក្សាខ្ញុំឲ្យបន្តធ្វើកិច្ចការពេញមួយថ្ងៃ ។ ការអធិស្ឋានរំឭកខ្ញុំឲ្យរក្សាបទដ្ឋានរបស់ខ្ញុំ ។

គ្មានមន្ទិលសង្ស័យណាសូម្បីតែបន្តិចអំពីអ្វីដែលអ្នកកំពុងធ្វើនោះថា មិនត្រឹមត្រូវឡើយ ។ មនុស្សតែងតែព្យាយាមចំអកឡកឡឺយដល់អ្នកនូវរឿងដែលពួកគេពុំដែលធ្វើ ។ ប្រហែលជាអ្នកមិនមែនជាមនុស្សអស្ចារ្យទេ ។ រឿងនោះមិនជាអ្វីទេ ។ ព្រះវរបិតាសួគ៌របស់អ្នក និងព្រះយេស៊ូវគ្រីស្ទទតឃើញថា អ្នកជាមនុស្សអស្ចារ្យក្នុងការគោរពតាមបទដ្ឋាន ។ ទីបំផុតអ្នកនឹងដឹងថា អ្វីដែលអ្នកកំពុងធ្វើឥឡូវនេះធ្វើឲ្យអ្នករីករាយ ។ វាគឺពិតជាមាននូវសេចក្ដីអំណរដ៏យូរអង្វែងដែលកើតមកពីការរក្សាបទដ្ឋានរបស់អ្នក ។ ដូច្នេះ សូមបន្តទៅមុខទៀត សូមរក្សាបទដ្ឋាននៃការរស់នៅរបស់អ្នក !

**ណាថាន អូ**

ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន



# យុវវ័យ

## នៅក្នុងវគ្គនេះ




៥២ ការរៀបចំខ្លួនសម្រាប់ជីវិត ៖
ការដាក់គោលដៅប្រាកដប្រជាដែលអ្នកអាចសម្រេចបាន
ដោយ ឆាខែល រូដលៃញ

៥៤ ការយល់ដឹងអំពីផែនការនៃសេចក្ដីសង្គ្រោះបានផ្ដល់ភាពសុខសាន្តដល់ខ្ញុំ
ដោយ ណែស្ស ប៉ហ្គោល ជេ មីកាប៉ានី

៥៦ ប្រជាជននៅកាលីឡេ
ដោយ ស្រៀនណា ខល ហើរបើត

៦០ សំណួរ និងចម្លើយ ៖
តើខ្ញុំអាចទុកឧបករណ៍អេឡិចត្រូនិចមិនឲ្យរំខានអារម្មណ៍របស់ខ្ញុំយ៉ាងដូចម្ដេចទាំងនៅព្រះវិហារ និងនៅក្នុងថ្នាក់សិក្ខាសាលា ?

៦២ ទីកន្លែងរបស់យើង

៦៤ ពាក្យចុងក្រោយ ៖
« កុំឲ្យខ្លាចអ្វីឡើយ ពីព្រោះយើងនៅជាមួយ »
ដោយអែលឌើរ ដាវីឌ អេ បែដណា



# ការដាក់គោលដៅ ប្រាកដប្រជា
## *ដែលអ្នកអាចសម្រេចបាន*

*តើអ្នករីកចម្រើនដែរឬទេ ? ក្លាយជាមនុស្សកាន់តែពូកែឡើងក្នុងជំនាញជាក់លាក់មួយដែរឬទេ ? រៀនអ្វីមួយថ្មីទាំងស្រុងដែរឬទេ ? អ្នកត្រូវតែដាក់គោលដៅមួយចំនួនដើម្បីឈានទៅដល់ទីនោះ ។*

**ដោយ ឆាំខេល រូដលែញ**
ទស្សនាវដ្ដីសាសនាចក្រ

ជួនកាលយើងសរសេរទុកនូវគោលដៅជាច្រើន ហើយពិតជាព្យាយាមយ៉ាងខ្លាំងដើម្បីសម្រេចវា ប៉ុន្តែក្រោយមកយើងភ្លេចគោលដៅនោះ ឬបោះបង់វាចោល ។ ស្គាល់ទៅដូចអញ្ចឹងដែរឬទេ ? ហេតុអ្វីវាកើតឡើងបែបនោះ នៅពេលយើងចង់ផ្លាស់ប្ដូរ ហើយប្រែខ្លួនឲ្យបានកាន់តែប្រសើរនោះ ជួនកាលយើងគ្រាន់តែពុំអាចធ្វើតាមគោលដៅដែលយើងបានដាក់ឲ្យបានជាប់លាប់ប៉ុណ្ណោះ ? មែនហើយ វាត្រូវបានកំណត់ដោយភាពប្រាកដប្រជាដ៏ខ្លាំងនៃគោលដៅរបស់យើង និងការខិតខំយ៉ាងខ្លាំងដែលយើងមានឆន្ទៈដើម្បីធ្វើ !

នេះគឺជាចំណុចគន្លឹះមួយចំនួនអំពីការដាក់គោលដៅដែលប្រាកដប្រជា ៖

- **ដាក់គោលដៅផ្សេងៗ ។** ផ្ដោតទៅលើការពង្រឹងផ្នែកជាច្រើននៃជីវិតរបស់អ្នក ពុំមែនតែមួយផ្នែកទេ ។ ព្រះអង្គសង្គ្រោះបានធ្វើគំរូដ៏ល្អឥតខ្ចោះមួយ ៖ « ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ( លូកា ២:៥២ ) ។ នោះជារបៀបដែលទ្រង់បានរីកចម្រើនខាងផ្លូវចិត្ត រូបកាយ សង្គម និង ខាងវិញ្ញាណ ។ អ្នកអាចដាក់គោលដៅធ្វើដូចគ្នានេះផងដែរ ។ ការដឹងថា គោលដៅរបស់អ្នកកំពុងជួយអ្នកឲ្យប្រែក្លាយជាមនុស្សប្រសើរឡើង អាចជួយជំរុញចិត្តអ្នកឲ្យបន្តខិតខំសម្រេចបានគោលដៅនោះ ។

- **កត់ត្រាគោលដៅរបស់អ្នក ។** សូមរក្សាគោលដៅរបស់អ្នកនៅកន្លែងដែលអ្នកអាចឃើញវារៀងរាល់ថ្ងៃ ។ មិនថាបិទវានៅលើក្ដារខៀននៅក្នុងបន្ទប់ នៅក្នុងទូរដាក់ឥវ៉ាន់របស់អ្នកនៅឯសាលា ឬសូម្បីតែនៅក្នុងទូរសព្ទរបស់អ្នក សូមមើលវាឲ្យបានញឹកញាប់ ។ ដរាបណាអ្នកត្រូវបានរំឭកអំពីគោលដៅដែលអ្នកបានដាក់ ដរាបនោះអ្នកនឹងបន្តខិតខំដើម្បីសម្រេចវាឲ្យបាន ។

Getty Images





## គោលដៅសំខាន់បំផុត

« *ការត្រឡប់* ទៅកាន់ទីវត្តមាន [ របស់ព្រះ ] វិញ ហើយ *ទទួល* ពរជ័យអស់កល្បជានិច្ច ដែលកើតមកពីការចុះ ហើយរក្សាសេចក្ដីសញ្ញាគឺជាគោលដៅសំខាន់បំផុតដែលយើងអាចដាក់ » ។

ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់ « ត្រឡប់ទៅ ហើយទទួល » សន្និសីទទូទៅខែមេសា ឆ្នាំ ២០១៧ ។

- **ត្រូវមានភាពជាក់លាក់ ។** ប្រសិនបើអ្នកមានគោលដៅមួយថា « រៀនអ្វីមួយថ្មី » នៅលើបញ្ជីគោលដៅរបស់អ្នក វាប្រាកដជាគោលដៅប្រាកដប្រជាមួយ ប៉ុន្តែវាពុំជាក់លាក់ទេ ។ តើអ្នកចង់រៀនអ្វី ? ចង់ចេះលេងឧបករណ៍តន្ត្រីមួយឬ ? ចង់ចេះធ្វើម្ហូបមួយមុខឬ ? ប្រហែលជាធ្វើកិច្ចការកម្សាន្តមួយថ្មីជាមួយគ្នាឬ ? សូមមានភាពជាក់លាក់អំពីអ្វីដែលអ្នកចង់សម្រេចបាន !

- **ដាក់គោលដៅរយៈពេលខ្លី ។** អ្នកអាចដាក់គោលដៅធំមួយសម្រាប់ខ្លួនអ្នក ប៉ុន្តែដើម្បីសម្រេចបានគោលដៅនោះ អ្នកត្រូវសម្រេចគោលដៅតូចៗសិនដើម្បីសម្រេចគោលដៅធំនោះ ។ ប្រាកដណាស់ អ្នកចាំបាច់ត្រូវមានផែនការមួយ ។ ឧទាហរណ៍ អ្នកចង់រត់កីឡាម៉ារ៉ាតុនឆ្នាំនេះ ។ ដើម្បីហាត់ប្រាណឲ្យអ្នកអាចរត់ចម្ងាយ ៤២ គីឡូម៉ែត្រ អ្នកត្រូវចាប់ផ្ដើមពីចម្ងាយតិចៗសិន ។ សូមដាក់គោលដៅរត់ចម្ងាយពីរបីគីឡូម៉ែត្រ រៀងរាល់សប្ដាហ៍ ហើយបង្កើនចម្ងាយរបស់អ្នកដោយសន្សឹមៗរៀងរាល់សប្ដាហ៍ ។ ពេលយើងដាក់ផែនការសម្រេចគោលដៅរបស់យើង ព្រះនឹងជួយយើងសម្រេចគោលដៅទាំងនោះ ( សូមមើល សុភាសិត ១៦:៩ ) ។

- **សូមមានពេលវេលាដើម្បីសម្រេចគោលដៅរបស់អ្នក ។** ដោយសារអ្នកមានភាពមមាញឹក វាអាចងាយធ្វើឲ្យគោលដៅអ្នកត្រូវបានបំភ្លេចដោយសារតែសាលារៀន ការងារ មិត្តភក្តិ និងគ្រួសារ ។ ប៉ុន្តែប្រសិនបើអ្នកញែកពេលវេលាជាក់លាក់ ដើម្បីខិតខំធ្វើគោលដៅរបស់អ្នករៀងរាល់ថ្ងៃ រៀងរាល់សប្ដាហ៍ ឬពេលណាក៏ដោយដែលអ្នកចង់ធ្វើនោះអ្នកកាន់តែបន្តធ្វើតាមគោលដៅនោះ ។

- **សូមកុំធ្វើច្រើនពេក ។** កុំដាក់គោលដៅច្រើនពេកដែលអ្នកពិបាកចាំនូវអ្វីគ្រប់យ៉ាងដែលអ្នកបានគ្រោងដើម្បីធ្វើ ។ ប្រសិនបើអ្នកចាប់ផ្ដើមជាមួយនឹងគោលដៅសំខាន់ៗពីរ ជំនួសឲ្យការខិតខំព្យាយាមសម្រេចគោលដៅ ៤០ ក្នុងពេលតែមួយ នោះអ្នកនឹងមានអារម្មណ៍ពុំសូវស្មុគស្មាញ ហើយមានទំនុកចិត្តកាន់តែច្រើនឡើងនៅក្នុងការខិតខំរបស់អ្នកដើម្បីសម្រេចគោលដៅនោះ ។ យើងត្រូវធ្វើកិច្ចការនានា « ក្នុងប្រាជ្ញា និងរបៀបរៀបរយ ដ្បិតមិនត្រូវឲ្យអ្នកណារត់លឿនជាងកម្លាំងដែលគេមាននោះឡើយ » ( ម៉ូសាយ ៤:២៧ ) ។ ហើយពេលអ្នកសម្រេចបានគោលដៅមួយ អ្នកទំនងជាសម្រេចបានគោលដៅផ្សេងមួយទៀត ! កិច្ចការតូចតាចដឹកនាំទៅរកកិច្ចការធំបាន ។ ■

# ការយល់ដឹងអំពី
# ផែនការនៃសេចក្តីសង្គ្រោះ
# បានផ្តល់ភាពសុខសាន្តដល់ខ្ញុំ

*ពេលម្តាយខ្ញុំត្រូវបានធ្វើរោគវិនិច្ឆ័យដឹងថាមានជំងឺមហារីកកម្រិតចុងក្រោយ នោះខ្ញុំគ្រាន់តែអាចមើលឃើញពីទុក្ខព្រួយនាពេលអនាគតរបស់ខ្ញុំតែប៉ុណ្ណោះ ។ បន្ទាប់មកគាត់បានថ្លែងទីបន្ទាល់របស់គាត់អំពីផែនការនៃសេចក្តីសង្គ្រោះ ។*

**ដោយ ណែស្ស ប៉ាហ្គោល ឌេ មីកាប៉ានី**

ពីរបីឆ្នាំកន្លងទៅ នៅថ្ងៃខួបអាពាហ៍ពិពាហ៍របស់ម្តាយឪពុកខ្ញុំ ម្តាយខ្ញុំត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺមហារីកលំពែងដំណាក់ទី ៤ ។ លទ្ធផលស៊ីធីស្កេនរបស់គាត់បានបង្ហាញថា ជំងឺមហារីករបស់គាត់គំរាមកំហែងអាយុជីវិតគាត់ ហើយរូបកាយរបស់គាត់ទ្រុឌទ្រោមជាខ្លាំង ។ នៅគ្រានោះហើយ ដែលខ្ញុំបានដឹងថា ម្តាយរបស់ខ្ញុំពុំអាចរស់នៅបានយូរទៀតទេ ។

ខ្ញុំពុំទាន់បានត្រៀមខ្លួនចំពោះរឿងនោះទេ ។ ខ្ញុំបានស្រមៃពីសភាពនៃជីវិតខ្ញុំ ពេលគ្មានម្តាយខ្ញុំ ។ អ្វីៗគ្រប់យ៉ាងនឹងអាប់អួរ គ្មានសង្ឃឹម និងទុក្ខព្រួយ ។ គ្មានអំណរ ឬការសើចសប្បាយទៀតឡើយ—ហើយគ្មានការឱបដ៏កក់ក្តៅពីម្តាយខ្ញុំដែលនឹងលួងលោមខ្ញុំទៀតដែរ ។ វាហាក់ដូចជាខ្ញុំគ្មានជីវិតផងដែរ ។

ជាច្រើនខែបានកន្លងផុតទៅ ហើយរាងកាយម្តាយរបស់ខ្ញុំបានចុះខ្សោយទៅៗ ។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលបំផុតនោះ គឺបំណងប្រាថ្នារបស់គាត់ក្នុងការទៅព្រះវិហារ ចូលរួមការសិក្សាព្រះគម្ពីរប្រចាំថ្ងៃជាមួយគ្រួសារយើង បង្រៀនមេរៀននៅក្នុងរាត្រីជួបជុំគ្រួសារ ហើយថែមទាំងសើចជាមួយយើងផងដែរ ។



រចនារូបភាពដោយ រ៉ូហ្គេរីអូ កូអែលហូ

ថ្ងៃមួយ ខ្ញុំបានសួរគាត់ថា « តើម៉ាក់គ្មានសំណួរទៅកាន់ព្រះវរបិតាសួគ៌ទេឬ ? តើម៉ាក់ដែលឆ្ងល់ទេថាហេតុអ្វី *ម៉ាក់* មានជំងឺមហារីក ? ម្ដាយខ្ញុំបានញញឹមហើយបានចែកចាយទីបន្ទាល់របស់គាត់អំពីផែនការនៃសេចក្ដីសង្គ្រោះ ។ គាត់បានប្រាប់ខ្ញុំថា ខ្ញុំត្រូវតែយល់ពីផែនការណ៍នៃសេចក្ដីសង្គ្រោះ ដើម្បីទទួលអារម្មណ៍នៃភាពសុខសាន្តដ៏ប្រពៃដែលយើងនឹងទទួល ។ គាត់បានមានប្រសាសន៍ថា ប្រសិនបើខ្ញុំយល់ពីកន្លែងដែលយើងបានមក គោលបំណងរបស់យើងក្នុងជីវិតនេះ និងកន្លែងដែលយើងទៅ នោះខ្ញុំនឹងយល់ថា យើងនឹងនៅជាមួយគ្នាជានិច្ចខ្ញុំនឹងពុំបាត់បង់គាត់នោះទេ ។ គាត់បានលើកទឹកចិត្តខ្ញុំឲ្យបន្តរៀបចំខ្លួនបម្រើបេសកកម្ម ហើយចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងផែនការនៃសេចក្ដីសង្គ្រោះជាមួយមនុស្សដទៃ ដើម្បីពួកគេអាចទទួលពរជ័យនៃការលួងលោម និងសុភមង្គលនេះផងដែរ ។

ខ្ញុំបានដឹងថា ម្ដាយខ្ញុំមានប្រសាសន៍ត្រឹមត្រូវណាស់ ។ ហេតុអ្វីខ្ញុំមានអារម្មណ៍ភ័យខ្លាចបាត់បង់គាត់នៅលើផែនដីនេះ ប្រសិនបើខ្ញុំបានដឹងថា ដរាបណាខ្ញុំរក្សាសេចក្ដីសញ្ញាហើយបំពេញតាមព្រះទ័យរបស់ព្រះវរបិតា នោះខ្ញុំនឹងជួបគាត់នៅក្នុងជីវិតបន្ទាប់ទៀត ? ខ្ញុំមានអារម្មណ៍សុខសាន្ត ។

មួយរយៈក្រោយមក ម្ដាយរបស់ខ្ញុំបានស្លាប់ ។ អំឡុងពេលធ្វើពិធីបុណ្យសព—ជាពិធីដែលយើងបានធ្វើពីមុនការបញ្ចុះសពគាត់—ទោះបីនោះជាគ្រាលំបាក ហើយខ្ញុំមានទុក្ខក្ដី អ្វីៗគ្រប់យ៉ាងហាក់ដូចជាមានភាពសុខសាន្ត ហើយខ្ញុំនៅតែមានអារម្មណ៍ថា ម្ដាយខ្ញុំមានវត្តមាននៅទីនោះ ។ សូម្បីតែអ្នកដែលនៅជុំវិញខ្ញុំក៏ហាក់ដូចជាត្រូវបានលើកស្ទួយចិត្តផងដែរ ។ ខ្ញុំបានដឹងថា ខ្ញុំបានទទួលអារម្មណ៍នៃពរជ័យពិតប្រាកដនៃការយល់អំពីផែនការដ៏ទេវភាពរបស់ព្រះ ។

ក្រោយមក នៅពេលដែលត្រូវយកសពម្ដាយខ្ញុំទៅទីបញ្ចុះសព ក្មេងប្រុសម្នាក់បានមកជួបខ្ញុំ ហើយបានសួរខ្ញុំថា ហេតុអ្វីខ្ញុំអត់យំ ។ ខ្ញុំបានចាំពីអារម្មណ៍ដែលខ្ញុំបានគិតអំពីមរណភាពរបស់ម្ដាយខ្ញុំពីមុន និងអារម្មណ៍ដែលខ្ញុំបានឃើញតែពីទុក្ខព្រួយ និងភាពសោកសៅដ៏ខ្លាំង ។ ខ្ញុំបានញញឹម ហើយលុតជង្គង់ចុះត្រឹមកម្ពស់គាត់ ។ ខ្ញុំបានប្រាប់គាត់ថា « បងដឹងថា បងនឹងជួបម្ដាយបងម្ដងទៀត ប្រសិនបើបងបន្តធ្វើតាមបទបញ្ញត្តិរបស់ព្រះ » ។ ក្មេងប្រុសនោះបានញញឹមផងដែរ ហើយខ្ញុំបានដឹងថា គាត់បានទទួលអារម្មណ៍សុខសាន្តដូចខ្ញុំបានទទួលដែរ ។

ម្ដាយរបស់ខ្ញុំបានចែកឋានទៅមែន ប៉ុន្តែភាពអាប់អួរក្ដីអស់សង្ឃឹម និងភាពសោកសៅដែលខ្ញុំបានគិតថា នឹងមានក្នុងជីវិតខ្ញុំនោះពុំមានវត្តមានឡើយ ។ ខ្ញុំបានលាម្ដាយខ្ញុំ ហើយប្រាប់គាត់ថា យើងនឹងជួបគ្នានៅក្នុងជីវិតខាងមុខ ។ ខ្ញុំបានទទួលអារម្មណ៍លួងលោម ទោះបីជាយើងបាត់បង់គ្នាក្ដី ។ វាគឺជាពរជ័យមួយដែលកើតឡើងពីការយល់អំពី ផែនការនៃសេចក្ដីសង្គ្រោះ ។ ■

*អ្នកនិពន្ធរស់នៅប្រទេសហ្វីលីពីន ។*

ដើម្បីរៀនបន្ថែមទៀតអំពីជីវិតបន្ទាប់ពីសេចក្ដីស្លាប់ សូមអានគោលលទ្ធិ និងសេចក្ដីសញ្ញា កណ្ឌទី ៧៦ ដែលព្រះអម្ចាស់ពិពណ៌នាអំពីអស់អ្នកដែលគ្រងនគរសេឡេស្ទាល នគរទេរេសស្ទ្រាល នគរទេឡេស្ទាលទុកជាមរតក ហើយប្រៀបធៀបសិរីល្អនៃនគរទាំងនោះទៅនឹងព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ ។



# ប្រជាជននៅកាលីឡេ



**ស្រៀនណា ខល ហើរបើត**
ទស្សនាវដ្ដីសាសនាចក្រ

អំឡុងពេលព្រះអង្គសង្គ្រោះគង់នៅលើផែនដី ទ្រង់បានបង្រៀន និងប្រទានការងារបម្រើដល់មនុស្សជាច្រើន ។ មានមនុស្សមួយចំនួនដែលព្រះយេស៊ូវគ្រីស្ទបានប្រទានការងារបម្រើនៅកាលីឡេ ។ តើប្រជាជនទាំងនេះនឹងថ្លែងអ្វីខ្លះ ប្រសិនបើពួកគេអាចប្រាប់ពីរឿងរបស់ពួកគេផ្ទាល់ដែលមាននៅក្នុងព្រះគម្ពីរនោះ ? ទាំងនេះគឺជាគំនិតយោបល់មួយចំនួន ។



**កុមារ ៖** ខ្ញុំបានឈរក្បែរព្រះយេស៊ូវគ្រីស្ទ និង សាវករបស់ទ្រង់ ។ ពួកសាវកកំពុងប្រកែកគ្នាអំពីអ្វីមួយ ហើយព្រះយេស៊ូវបានសួរពួកលោកអំពីរឿងនោះ ។ ពួកសាវកបានស្ងាត់ ហើយគ្មាននរណាម្នាក់និយាយឡើយ ដោយសារពួកលោកបានប្រកែកគ្នាថា តើពួកលោកណាម្នាក់ដែលនឹងបានទៅជាធំនៅក្នុងនគរស្ថានសួគ៌ ។ បន្ទាប់មក ព្រះអង្គសង្គ្រោះបានមករកខ្ញុំ ។ ខ្ញុំបានឈរនៅកណ្ដាលពួកលោក ហើយទ្រង់បានលើកបីខ្ញុំក្នុងរង្វង់ព្រះហស្តទ្រង់ ។ ទ្រង់បានប្រាប់ពួកលោកថា នរណាដែលបន្ទាបខ្លួនដូចជាកូនក្មេងតូចនេះ គឺនឹងបានធំនៅក្នុងនគរស្ថានសួគ៌ហើយ ។ ( សូមមើល ម៉ាកុស ៩:៣៣–៣៧; ម៉ាថាយ ១៨:១–៥ ) ។



**កុមារាតូច ៖** ខ្ញុំបានឮពីព្រះយេស៊ូវគ្រីស្ទ និង អព្ភូតហេតុដែលទ្រង់បានសម្ដែងដល់ពួកអ្នកឈឺ ។ ដូច្នេះពេលទ្រង់យាងទៅទីរហោស នោះខ្ញុំបានចូលរួមនឹងហ្វូងមនុស្សដែលបានដើរតាមទ្រង់ ។ ពួកយើងមានគ្នាច្រើនណាស់ គឺប្រហែលជា ៥០០០ នាក់ ។ ខ្ញុំមានតែនំបុ័ងប្រាំដុំ និងត្រីពីរ ។ ព្រះយេស៊ូវគ្រីស្ទបានយកវា ហើយប្រទានពរវា ។ ដោយអព្ភូតហេតុ មនុស្សគ្រប់គ្នាបានបរិភោគអាហារដែលខ្ញុំមាននោះ ។ ប៉ុន្តែវាពុំបានបញ្ចប់ត្រឹមនោះទេ ។ ពេលមនុស្សទាំងនោះបានបរិភោគឆ្អែតហើយ ពួកសិស្សបានប្រមូលអាហារដែលនៅសល់នោះ ។ អាហារទាំងនោះដាក់បានពេញ ១២ កន្ត្រក់ទៀត ។ ( សូមមើល យ៉ូហាន ៦:៥–១៤ ) ។





**ប៊ុស ៖** ខ្ញុំបានមានជំងឺស្លាប់ដៃស្លាប់ជើង ដូច្នេះខ្ញុំពុំអាចកម្រើកបានទេ ។ ហើយក្រៅពីនោះ ខ្ញុំមានការញ័រដែលពុំអាចគ្រប់គ្រងបាន ។ វាមានការឈឺចាប់ណាស់ ។ មិត្តភក្តិរបស់ខ្ញុំបានឮថា ព្រះយេស៊ូវគ្រីស្ទកំពុងបង្រៀនគេនៅក្នុងផ្ទះមួយ ។ ពួកគេបានដឹងថា ទ្រង់អាចជួយខ្ញុំបាន ដូច្នេះពួកគេបានព្យាយាមនាំខ្ញុំទៅរកទ្រង់ ។ នៅផ្ទះនោះមានមនុស្សច្រើនកកកុញ ដូច្នេះពួកគេបានសម្រេចចិត្តដាក់ខ្ញុំចុះតាមដំបូលផ្ទះ ។ ពួកគេបានបើកដំបូលផ្ទះនោះ ហើយដាក់ខ្ញុំចុះនៅមុខព្រះភ័ក្ត្រព្រះយេស៊ូវគ្រីស្ទ ។ ពេលទ្រង់បានទតឃើញខ្ញុំ ទ្រង់មានបន្ទូលថា អំពើបាបរបស់ខ្ញុំត្រូវបានអត់ទោសឲ្យហើយ ។ ទ្រង់បានប្រាប់ខ្ញុំថា ចូរក្រោកឡើងយកគ្រែរបស់ខ្ញុំដើរទៅចេញ ។ ដូច្នេះខ្ញុំជាហើយដើរចេញទៅ—ហើយមនុស្សគ្រប់គ្នាមានក្តីអស្ចារ្យណាស់ ! ( សូមមើល ម៉ាកុស ២:១–១២ ) ។



**នាម៉ឺន ៖** ខ្ញុំនៅស្រុកកាណាកាលគ្រានោះ ។ ហើយកូនប្រុសខ្ញុំនៅក្រុងកាពើណិមហៀបនឹងស្លាប់ ។ ខ្ញុំបានឮថា ព្រះយេស៊ូវគ្រីស្ទគង់នៅតំបន់នោះ ដូច្នោះខ្ញុំបានទៅរកទ្រង់ ។ ពេលខ្ញុំបានជួបទ្រង់ ខ្ញុំបានទូលសុំទ្រង់ឲ្យទៅកាពើណិមដើម្បីព្យាបាលកូនប្រុសរបស់ខ្ញុំ ។ ទ្រង់បានមានបន្ទូលប្រាប់ខ្ញុំឲ្យទៅផ្ទះ ដោយសារកូនប្រុសរបស់ខ្ញុំនៅរស់ទេ ។ ខ្ញុំបានជឿទ្រង់ ។ ពេលខ្ញុំទៅដល់ផ្ទះវិញ អ្នកបម្រើខ្ញុំបានចេញមកទទួលខ្ញុំ ។ ពួកគេបានប្រាប់ខ្ញុំថា កូនប្រុសខ្ញុំនៅរស់ទេ ។ ខ្ញុំបានសួរពួកគេថា តើកូនប្រុសខ្ញុំបានចាប់ផ្តើមមានសុខភាពល្អវិញតាំងពីពេលណា ។ ពួកគេបានប្រាប់ខ្ញុំថា កាលពីម្សិលមិញនៅយាមទីប្រាំពីរ ។ វានៅចំពេលដែលព្រះគ្រីស្ទបានប្រាប់ខ្ញុំថា កូនប្រុសខ្ញុំនៅរស់ទេ ! ( សូមមើល យ៉ូហាន ៤:៤៦–៥៣ ) ។



**ម៉ារា ម៉ាក់ដាឡា ៖** ព្រះយេស៊ូវគ្រីស្ទបានបណ្តេញអារក្សប្រាំពីរចេញពីខ្ញុំ ។ ខ្ញុំបានដើរតាមទ្រង់ ពេលទ្រង់បានធ្វើដំណើរទៅភូមិជាច្រើនប្រកាសដំណឹងល្អ ។ ( សូមមើល លូកា ៨:១–៣ ) ។ ពេលព្រះគ្រីស្ទត្រូវបានគេឆ្កាង នោះខ្ញុំនៅក្បែរឈើឆ្កាងនោះ ( សូមមើល យ៉ូហាន ១៩:២៥ ) ។ ខ្ញុំបានទៅឯផ្នូរដែលគេបានបញ្ចុះព្រះសពរបស់ទ្រង់ ។ ខ្ញុំគឺជាបុគ្គលទីមួយដែលបានឃើញទ្រង់ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ ។ ដំបូងខ្ញុំបានគិតថា ទ្រង់គឺជាអ្នកថែសួន ប៉ុន្តែពេលទ្រង់បានហៅឈ្មោះខ្ញុំ នោះខ្ញុំបានដឹងថា ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ ។ ( សូមមើល យ៉ូហាន ២០:១១–១៦ ) ។

គំនូរព្រាងដោយ ស៊ីមីនី ប្លុកឃ័រ





**សាឡូមេ** ៖ ខ្ញុំជាភរិយារបស់សេបេដេ និងជាម្ដាយរបស់យ៉ាកុប និងយ៉ូហាន ដែលជាសាវកពីររូបរបស់ព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំបានដើរតាម និងបម្រើទ្រង់អំឡុងពេលទ្រង់គង់នៅកាលីឡេ ។ ខ្ញុំបាននៅគាល់កូថាពេលទ្រង់ត្រូវបានគេឆ្កាង ។ ( សូមមើល ម៉ាកុស ១៥:៣៧–៤១ ) ។ ខ្ញុំបានយកគ្រឿងក្រអូបទៅផ្នូររបស់ទ្រង់ ដើម្បីលាបតាំងប្រកាយទ្រង់ ប៉ុន្តែពេលខ្ញុំទៅដល់ផ្នូរ ទ្រង់ពុំបានគង់នៅទីនោះទេ ។ ផ្ទុយទៅវិញ ខ្ញុំបានឃើញបុរសម្នាក់ដែលស្លៀកពាក់រ៉ូបពណ៌ស ។ ដំបូងខ្ញុំខ្លាច ប៉ុន្តែលោកបានប្រាប់ខ្ញុំថា កុំឲ្យខ្លាចអី ។ លោកបានមានបន្ទូលថា ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញហើយ ហើយខ្ញុំគួរតែប្រាប់ពួកសាវកអំពីរឿងនេះ ។ ( សូមមើល ម៉ាកុស ១៦:១–៨ ) ។



**ម្ដាយក្មេករបស់ស៊ីម៉ូនពេត្រុស** ៖ ខ្ញុំមានជំងឺគ្រុនក្ដៅធ្ងន់ធ្ងរ ។ ពេលព្រះយេស៊ូវគ្រីស្ទបានឮថាខ្ញុំឈឺ ទ្រង់បានយាងមករកខ្ញុំ ។ ទ្រង់បានចាប់ដៃខ្ញុំ ហើយបានលើកខ្ញុំឡើង ។ ជំងឺគ្រុនក្ដៅនោះបានបាត់ពីខ្ញុំមួយរំពេច ។ ខ្ញុំមានអារម្មណ៍ស្រួលខ្លួនឡើងវិញ ហើយខ្ញុំថែមទាំងបានផ្ដល់ការងារបម្រើដល់មនុស្សដែលនៅជុំវិញខ្ញុំផងដែរ ។ ( សូមមើល ម៉ាកុស ១:២៩–៣១ ) ។



**ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន** ៖ កូនប្រុសរបស់ខ្ញុំទើបតែស្លាប់ ។ ខ្ញុំទើបតែបាត់បង់ស្វាមីរបស់ខ្ញុំ ។ ខ្ញុំមានទុក្ខក្រៀមក្រំណាស់ ។ ទោះបីមានមនុស្សជាច្រើននៅជាមួយខ្ញុំក្ដី ខ្ញុំនៅតែយំពុំឈប់ ។ ពេលយើងសែងសពកូនប្រុសរបស់ខ្ញុំចេញពីទ្វារក្រុង បុរសម្នាក់បានមកជួបខ្ញុំ ។ ទ្រង់គឺជាព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់មានព្រះទ័យអាណិតដល់ខ្ញុំ ហើយបានមានបន្ទូលប្រាប់ខ្ញុំកុំឲ្យខ្ញុំយំ ។ បន្ទាប់មក ទ្រង់បានយាងទៅរកកូនប្រុសខ្ញុំ ។ មនុស្សដែលសែងសពកូនខ្ញុំពួកគេនៅឈរស្ងៀម ។ ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលប្រាប់កូនប្រុសខ្ញុំឲ្យក្រោកឡើង ។ ហើយគាត់បានក្រោកឡើងមែន ។ គាត់បានក្រោកឡើងអង្គុយ ហើយចាប់តាំងនិយាយ ហើយគាត់បានមករកខ្ញុំវិញ ។ គាត់នៅរស់ទេ ! យើងទាំងអស់គ្នាបានសរសើរតម្កើងព្រះ ហើយបានដឹងថា មានព្យាការីម្នាក់ដ៏អស្ចារ្យនៅក្នុងចំណោមពួកយើង ។ ( សូមមើល លូកា ៧:១១–១៧ ) ។





**ម៉ារា ៖** ខ្ញុំបានឮពីព្រះមេស៊ី ដែលនឹងយាងមក ។ ខ្ញុំពុំបានរំពឹងថា នឹងធ្វើជាផ្នែកមួយនៃកិច្ចការនេះទេ ។ ខ្ញុំបានភ្ជាប់ពាក្យជាមួយយ៉ូសែបហើយ ពេលទេវតាមួយអង្គបានមកប្រាប់ខ្ញុំថា ខ្ញុំនឹងមានកូនប្រុសមួយ ដែលនឹងក្លាយជាព្រះរាជបុត្រានៃព្រះ ហើយដាក់ព្រះនាមទ្រង់ថាយេស៊ូវ ។ ( សូមមើល លូកា ១:២៦–៣៨ ) ។ ហើយព្រះមែស៊ីបានយាងមកមែន ។ ខ្ញុំបានផ្តល់កំណើតដល់ទ្រង់នៅក្នុងក្រោលសត្វ ។ ពួកអ្នកគង្វាល និងពួកហោរាបានមកឯទ្រង់ ហើយថ្វាយអំណោយដល់ទ្រង់ ។ ( សូមមើល ម៉ាថាយ ២:១–១២; លូកា ២:១–២០ ) ។ យ៉ូសែប និងខ្ញុំបានចិញ្ចឹមទ្រង់ ប៉ុន្តែទ្រង់ធ្វើឲ្យយើងមានក្តីអស្ចារ្យជានិច្ច ។ មានគ្រាមួយទ្រង់បានបាត់ខ្លួនបីថ្ងៃ ។ ទីបំផុតយើងបានរកទ្រង់ឃើញនៅព្រះវិហារបរិសុទ្ធ ។ ពួកអ្នកប្រាជ្ញាកំពុងស្តាប់ទ្រង់ ហើយសួរសំណួរដល់ទ្រង់ ។ ( សូមមើល លូកា ២:៤០–៥២ ) ។



**ហ្វីលីព ៖** ខ្ញុំគឺជាសាវកម្នាក់របស់ព្រះគ្រីស្ទ ។ ទ្រង់បានបញ្ជូនយើងឲ្យទៅប្រកាសដំណឹងល្អរបស់ទ្រង់ ។ ទ្រង់បានប្រាប់យើងឲ្យផ្តោតចិត្តទុកដាក់លើចៀមអ៊ីស្រាអែលដែលបានបាត់ ។ ទ្រង់ក៏បានប្រទានអំណាចដល់យើងដើម្បីព្យាបាលអ្នកឈឺ ព្យាបាលមនុស្សឃ្លង់ ប្រោសមនុស្សឲ្យរស់ឡើងវិញ និងបណ្តេញអារក្ស ។ ទ្រង់បានប្រាប់យើងកុំឲ្យយកប្រាក់ ឬសម្លៀកបំពាក់ឡើយ ប៉ុន្តែទ្រង់បានព្រមានយើងថា យើងនឹងត្រូវបានគេបៀតបៀន ។ ប៉ុន្តែយើងបានទុកចិត្តលើទ្រង់ ដោយសារយើងដឹងថា ប្រសិនបើយើងកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះយើងនឹងបានសង្គ្រោះ ។ ( សូមមើល ម៉ាថាយ ១០:១–១០, ១៧–១៨, ២២–២៣ ) ។



**ថាថាដេ យូដាស ៖** ខ្ញុំគឺជាសាវកម្នាក់របស់ព្រះគ្រីស្ទ ។ ថ្ងៃមួយ ពេលទ្រង់កំពុងបង្រៀនយើង—ទ្រង់បង្រៀនយើងជារឿយៗ—នោះទ្រង់បានប្រាប់យើងថា ទ្រង់នឹងពុំគង់នៅលើផែនដីបានយូរទៀតទេ ។ ទ្រង់បានប្រាប់យើងថា ប្រសិនបើយើងរក្សាបទបញ្ញត្តិទ្រង់ ហើយស្រឡាញ់ទ្រង់ នោះទ្រង់នឹងយាងមក ហើយបង្ហាញព្រះកាយទ្រង់ដល់ពួកយើង ។ ទ្រង់បានមានបន្ទូលថា ទ្រង់នឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយយើងឲ្យចាំអ្វីដែលទ្រង់បានបង្រៀនយើង ។ ( សូមមើល យ៉ូហាន ១៤:១៩–២៧ ) ។ ■



# « តើខ្ញុំអាចទុកឧបករណ៍អេឡិចត្រូនិចមិនឲ្យរំខានខ្ញុំទាំងនៅព្រះវិហារ និងនៅក្នុងថ្នាក់សិក្ខាសាលាដោយរបៀបណា ? »

*« ឧបករណ៍មានក្នុងដៃដូចជា ទូរសព្ទទំនើប គឺជាពរជ័យ ប៉ុន្តែវាក៏អាចរំខានយើងពីការស្ដាប់ឮ ‹ សំឡេងតូចរហៀង › ដែរ ។ វាគួរតែជាបាវបម្រើរបស់យើង មិនមែនជាចៅហ្វាយរបស់យើងនោះទេ ។ . . .*

*. . . ពេលទូរសព្ទទំនើបចាប់ផ្ដើមបង្អាក់ទំនាក់ទំនងយើងពីមិត្តភក្ដិ និងគ្រួសារ—ដែលសំខាន់ជាងនេះនោះគឺព្រះ—នោះយើងត្រូវតែកែប្រែ » ។*

ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Be Still, and Know That I Am God » ( ការប្រជុំធម្មនិដ្ឋានប្រព័ន្ធអប់រំសាសនាចក្រសម្រាប់យុវមជ្ឈិមវ័យ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៤ ) broadcasts.lds.org ។



### ឃ្លាតកាយណាយចិត្ត

ថ្មីៗនេះ ខ្ញុំបានសង្កេតឃើញពីទំនោរចិត្តខ្ញុំក្នុងការប្រើឧបករណ៍អេឡិចត្រូនិចនៅអំឡុងពេលធ្វើសកម្មភាពព្រះវិហារ និងសកម្មភាពយុវវ័យ ។ វាបានក្លាយជាទម្លាប់មួយ ។ គ្រប់ពេលដែលខ្ញុំបានឃើញទូរសព្ទ ខ្ញុំបានចាប់យកវាភ្លាម ហើយមើលថា តើមានការជូនដំណឹងថ្មី ឬសារថ្មីអ្វីដែលឬទេ ។ ដំណោះស្រាយ ? ខ្ញុំលាក់ទូរសព្ទពីខ្លួនខ្ញុំ ។ ទោះបីលាក់វានៅក្នុងកាបូប នៅក្រោមកៅអី ឬលាក់ជាមួយនឹងមិត្តខ្ញុំក្ដី—ប្រសិនបើខ្ញុំពុំឃើញទូរសព្ទខ្ញុំទេនោះ ខ្ញុំនឹងមិនត្រូវបានល្បួងឲ្យប្រើវាទេ ។

*តារីន អិម អាយុ ១៥ ឆ្នាំ រដ្ឋ ហ្វ្លរីដា ស.រ.អា.*



### រៀបចំឧបករណ៍អេឡិចត្រូនិចរបស់អ្នកដើម្បីកាត់បន្ថយការរំខានអារម្មណ៍

សូមរៀបចំឧបករណ៍អេឡិចត្រូនិចរបស់អ្នក ដូចនឹងរបៀបដែលអ្នករៀបចំគំនិត និងខ្លួនប្រាណរបស់អ្នកសម្រាប់ថ្ងៃឈប់សម្រាកដែរ ។ សូមដាក់ទូរសព្ទអ្នកក្នុងម៉ូដមិនឲ្យទទួលការជូនដំណឹងនៅអំឡុងពេលរៀន ។ អ្នកអាចដាក់កម្មវិធី Gospel Library ផ្សេងពីកម្មវិធីផ្សេងទៀត ដូច្នេះពេលអ្នកត្រូវការប្រើព្រះគម្ពីរ ឬសៀវភៅកំណត់ចំណាំ នោះអ្នកពុំត្រូវបានរំខានដោយកម្មវិធីផ្សេងទៀតទេ ។

*ដេលីហ្គៀម៉ា អេស អាយុ ២១ ឆ្នាំ ទីក្រុង សៅ ប៉ូឡូ ប្រទេសប្រេស៊ីល*

រូបថតនៃកាត់ទូរសព្ទដោយ ឆាពេ ប៊ីងហាំ

### អធិស្ឋានសូមជំនួយ

ខ្ញុំបានស្វែងរកព្រះវិញ្ញាណតាមរយៈការអធិស្ឋាន ។ វាជួយខ្ញុំឲ្យទុកឧបករណ៍អេឡិចត្រូនិចខ្ញុំមួយអន្លើសិននៅថ្ងៃឈប់សម្រាក និងអំឡុងពេលរៀនថ្នាក់សិក្ខាសាលា ។ ពេលណាខ្ញុំអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ខ្ញុំ និងពេលអានព្រះគម្ពីរមរមន ខ្ញុំទទួលរបៀបមួយដើម្បីទុកឧបករណ៍អេឡិចត្រូនិចខ្ញុំមួយអន្លើសិន ។

*ឌីសាយអើរ អិម អាយុ ១៨ ឆ្នាំ ស្រុកកូម៉ូអ៊ី ប្រទេសកូតឌីវ័រ*

### ចូរកុំភ្លេចព្រះគម្ពីរជាសៀវភៅ !

ការប្រើឧបករណ៍អេឡិចត្រូនិចសម្រាប់រៀនដំណឹងល្អគឺមិនអីទេ ប៉ុន្តែជួនកាលយើងប្រើវាជ្រុលហួសហេតុពេក ។ ដើម្បីកុំឲ្យអ្នកត្រូវបានរំខានដោយសារវា នោះសូមព្យាយាមប្រើព្រះគម្ពីរជាសៀវភៅផង ។ ព្រះអម្ចាស់នឹងដឹកនាំអ្នក ។ យើងនឹងរៀនបានកាន់តែច្រើន ហើយទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។

*អាយយ៉ាណា អេ អាយុ ១៣ ឆ្នាំ ទីក្រុងឡាហ្គូណា ប្រទេសហ្វីលីពីន*

### ទុកវាមួយអន្លើសិន

នៅព្រះវិហារ ខ្ញុំបានបិទសំឡេងទូរសព្ទខ្ញុំ ហើយទុកវាក្នុងហោប៉ៅ ហើយប្រើវាពេលដែលខ្ញុំប្រើព្រះគម្ពីរប៉ុណ្ណោះ ។ អំឡុងពេលសាក្រាម៉ង់ ខ្ញុំពុំមើលទូរសព្ទខ្ញុំទាល់តែសោះ ។ ខ្ញុំទុកវានៅឆ្ងាយពីដៃខ្ញុំដើម្បីចៀសវាងពីការប្រើវា ។

*វិល្លាម ដឫលយូ អាយុ ១៧ ឆ្នាំ រដ្ឋវើរជីញ៉ា ស.រ.អា.*

*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យ មិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*



### តើខ្ញុំគួរនិយាយដូចម្ដេច ពេលមិត្តភក្ដិរបស់ខ្ញុំសួរសំណួរអំពីសេចក្ដីជំនឿរបស់យើងចំពោះអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ ?

នៅក្នុង « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ប្រកាសថា អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាគ្រួសារជាផ្នែកដ៏សំខាន់មួយនៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃ កូនចៅរបស់ទ្រង់ » ( familyproclamation.lds.org ) ។

សេចក្ដីប្រកាសនេះ « គឺជាសេចក្ដីថ្លែងការណ៍មួយនៃសេចក្ដីពិតដ៏អស់កល្ប » ដែលកើតឡើងតាមរយៈ « ដំណើរការនៃវិវរណៈ » ហើយពុំមែន « គ្រាន់តែជាសេចក្ដីថ្លែងការណ៍នៃគោលនយោបាយ » ឡើយ ( ដាល្លិន អេក អូក « ផែនការ និងសេចក្ដីប្រកាស » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៣០, ២៩ ) ។ អ្នកអាចចែកចាយជំនឿផ្ទាល់របស់អ្នកថា នេះគឺជាការពិត ហើយអ្នកអាចចែកចាយពរជ័យដែលសេចក្ដីពិតទាំងនេះបានផ្ដល់ដល់អ្នក ។

ក្នុងការឆ្លើយតបទៅមនុស្សដទៃ យើងត្រូវចៀសវាងពីការគិតថាខ្លួនឯងសុចរិត ឬចៀសវាងពីជម្លោះ ។ យើងគួរតែព្យាយាមស្រឡាញ់ពួកគេ ។ អស់អ្នកដែលបើកដួងចិត្ត ហើយស្មោះសរស័ក្ដិសមនឹងទទួលបានចម្លើយស្មោះសរ ។ ប៉ុន្តែប្រសិនបើវាជាក់ស្ដែងពេកថា បុគ្គលម្នាក់លេងសើចហើយគ្រាន់តែចង់សើចចំអក ឬមើលងាយទស្សនរបស់អ្នក ឬប្រសិនបើពួកគេគ្រាន់តែចង់បង្ករឿង វាជាការល្អបំផុតដើម្បីចៀសវាងពីការពិភាក្សា ( សូមមើល ម៉ាថាយ ៧:៦ ) ។

### *តើអ្នកគិតដូចម្ដេច ?*

« តើខ្ញុំអាចមានភាពវិជ្ជមាន ទោះខ្ញុំនៅជិតមិត្តភក្ដិរបស់ខ្ញុំដែលមានការបាក់ទឹកចិត្តបានដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមផ្ញើចម្លើយរបស់អ្នក និងរូបថតមានគុណភាពច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៩ ទៅកាន់គេហទំព័រ liahona.lds.org ( សូមចុច « Submit an Article or Feedback » ) ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។



# រត់ !

ល្ងាចមួយ ពេលខ្ញុំកំពុងដើរទៅផ្ទះ ។ វានៅសល់តែចម្ងាយប្រហែលបីបួនច្រកប៉ុណ្ណោះ ពីកន្លែងដែលខ្ញុំបានជួបជាមួយមិត្តភក្តិខ្ញុំមួយចំនួនកាលពីមិនទាន់ងងឹត ប៉ុន្តែឥឡូវនេះ មេឃងងឹតទាំងស្រុងតែម្តង ។ ខ្ញុំពិបាកនឹងមើលឃើញកន្លែងដែលខ្ញុំកំពុងដើរ ។

ខ្ញុំបានដឹងថា មានយុវជនបីនាក់កំពុងដើរតាមខ្ញុំ ។ ខ្ញុំបានចាប់ផ្តើមដើរកាន់តែលឿនចេញពីពួកគេ ប៉ុន្តែពួកគេបានបន្តដើរតាមខ្ញុំ ។ ខ្ញុំមានអារម្មណ៍ភិតភ័យក្នុងចិត្តខ្ញុំ ។ បន្ទាប់មក មានគំនិតដ៏ច្បាស់មួយបានផុសឡើងនៅក្នុងចិត្តរបស់ខ្ញុំថា ៖ រត់ទៅ ! ខ្ញុំបានចាប់ផ្តើមរត់ឡើងទួល ។ ទួលនោះចោតខ្លាំងណាស់ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំមានកម្លាំងមួយដែលពុំមែនជាកម្លាំងខ្ញុំទេ ។ វាហួសពីកម្លាំងខ្ញុំ ។

ឥឡូវនេះពួកយុវជនកំពុងរត់មកដែរ ហើយខិតមកកៀកនឹងខ្ញុំ ។ ខ្ញុំពុំដឹងប្រាកដថា ត្រូវធ្វើអ្វីបន្ទាប់ទៀតឡើយ ។ ជាថ្មីម្តងទៀត គំនិតមួយដ៏ច្បាស់លាស់បានផុសក្នុងគំនិតខ្ញុំ ដែលប្រាប់ខ្ញុំថា ត្រូវរត់ចុះទៅតាមផ្លូវតូចមួយ ។ ពេលខ្ញុំរត់តាមផ្លូវនោះ ខ្ញុំរំភើបចិត្តជាខ្លាំងដោយសារខ្ញុំបានឃើញមន្ត្រីប៉ូលីសម្នាក់ ។ ដោយរត់ខ្សោះកម្លាំងអស់ចម្ងាយជាច្រើនច្រកមក ហើយហត់ស្ទើរតែដាច់ខ្យល់ នោះខ្ញុំបានសូមជំនួយពីប៉ូលីសនោះ ។ ពេលពួកយុវជនទាំងនោះបានឃើញខ្ញុំនិយាយជាមួយមន្ត្រីប៉ូលីស នោះពួកគេបានឈប់រត់ដេញតាមខ្ញុំទៀត ហើយទីបំផុតពួកគេបានដើរចេញបាត់ទៅ ។ ដើម្បីប្រាកដថា ខ្ញុំមានសុវត្ថិភាព មន្ត្រីប៉ូលីសរូបនោះបានដើរទៅផ្ទះជាមួយខ្ញុំ ។

នាយប់នោះ ខ្ញុំបានបន្តគិតអំពីការបំផុសគំនិតដែលខ្ញុំបានទទួល ។ ខ្ញុំបានទទួលអារម្មណ៍សុខសាន្ត ដោយដឹងថា ព្រះវរបិតាសួគ៌បានជួយខ្ញុំ ។ ខ្ញុំបានអធិស្ឋានថ្លែងអំណរគុណទ្រង់ចំពោះការណែនាំរបស់ទ្រង់ ។ ខ្ញុំដឹងថា ពេលយើងធ្វើតាមសំឡេងនៃព្រះវិញ្ញាណ នោះយើងនឹងមានសុវត្ថិភាព ។

*ម៉ាទីន អេស ទីក្រុងពើតូ ប្រទេសអាហ្សង់ទីន*

« អ្នកអាចរៀនពីរបៀបធ្វើតាមការណែនាំពីអ្នកដឹកនាំដ៏ល្អបំផុត—គឺការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធ ។ នោះគឺជាវិវរណៈផ្ទាល់ខ្លួន ។ មានដំណើរការមួយដែលយើងអាចត្រូវបានដឹងខ្លួនពីគ្រោះថ្នាក់ខាងវិញ្ញាណ » ។

ប្រធាន បិយដ៏ យេ ផាកកឺ (ឆ្នាំ ១៩២៤-២០១៥) ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់
« Spiritual Crocodiles » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៣១ ។

—

តើខ្ញុំអាចត្រៀមខ្លួនរួចជាស្រេចដើម្បីស្តាប់ និងធ្វើតាមការបំផុសគំនិតដូចម្តេច ?

១. **ចូរបង្អង់សិន ។**
ការចំណាយពេលស្ងប់ស្ងាត់ដើម្បីពិចារណា និងសញ្ជឹងគិតនឹងជួយអ្នកឲ្យស្តាប់ឮព្រះវិញ្ញាណ ( សូមមើល ទំនុកដំកើង ៤៦:១០ ) ។

២. **ប្រែចិត្ត ។**
ការប្រែចិត្តធ្វើឲ្យអ្នកស្អាតស្អំដើម្បីឲ្យព្រះវិញ្ញាណអាចក្លាយជាដៃគូរបស់អ្នក ( សូមមើល អាលម៉ា ៣៤:៣៦ ) ។

៣. **សិក្សា ។**
ពេលអ្នកចេះព្រះបន្ទូលរបស់ព្រះអម្ចាស់ វាអាចកាន់តែងាយស្រួលដើម្បីស្គាល់សំឡេងរបស់ទ្រង់ ( សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ១:៣៨ ) ។

រចនារូបភាពដោយ អូរីអុល វីដាល

# ការក្រោកពីដេកគឺជាការទទួលខុសត្រូវរបស់ខ្ញុំ

នៅថ្ងៃអាទិត្យម្ដាយខ្ញុំតែងតែដាស់ខ្ញុំ ដើម្បីខ្ញុំអាចរៀបចំខ្លួនទៅព្រះវិហារ ហើយទៅដល់ទីនោះមុនការប្រជុំចាប់ផ្ដើម ។ ប៉ុន្តែនៅថ្ងៃអាទិត្យមួយ ម្ដាយខ្ញុំពុំបានមកដាស់ខ្ញុំទេ ។ ខ្ញុំបានក្រោកពីដេកដោយខ្លួនឯង ហើយបានសង្កេតឃើញថា ខ្ញុំពុំឮសំឡេងដូចសព្វមួយដងដែលគ្រួសារខ្ញុំរៀបចំខ្លួនទៅព្រះវិហារឡើយ ។ ខ្ញុំបានមើលនាឡិកាទាំងអន្ទះសារ ហើយបានដឹងថា ខ្ញុំបានយឺតកន្លះម៉ោងចូលប្រជុំនៅព្រះវិហារហើយ ។ ខ្ញុំបានខកខានទទួលទានសាក្រាម៉ង់ ។ ខ្ញុំប្រហែលជានឹងខកខានរៀនថ្នាក់សាលាថ្ងៃអាទិត្យផងដែរ ។

ខ្ញុំបានទទួលអារម្មណ៍ច្របូកច្របល់ និងត្រូវគេបោះបង់ចោល ។ ហេតុអ្វីម៉ាក់ខ្ញុំមិនដាស់ខ្ញុំព្រឹកនេះ ? គាត់ដាស់ខ្ញុំជានិច្ច ។ ប៉ុន្តែក្រោយមកខ្ញុំបានដឹងថា ៖ វាពុំមែនជាការទទួលខុសត្រូវរបស់ម្ដាយខ្ញុំដើម្បីដាស់ខ្ញុំ ដើម្បីខ្ញុំអាចទៅព្រះវិហារទាន់ម៉ោងនោះទេ—វាជាការទទួលខុសត្រូវរបស់ខ្ញុំ ។ ខ្ញុំបានចុះសេចក្ដីសញ្ញាជាមួយព្រះវរបិតាសួគ៌ ហើយវាជាការទទួលខុសត្រូវរបស់ខ្ញុំដើម្បីរក្សាសេចក្ដីសញ្ញានោះ ។

ក្រោយមកនៅថ្ងៃដដែលនោះ ម្ដាយខ្ញុំបានប្រាប់ថា គាត់មិនដាស់ខ្ញុំឲ្យក្រោកទៅព្រះវិហារទៀតទេ ។ គាត់បាននិយាយថា គាត់មិនដាស់ខ្ញុំទៀតទេ ។ គាត់បានប្រាប់ខ្ញុំថា ខ្ញុំគួរតែខិតខំដោយខ្លួនឯង ហើយទទួលបានទីបន្ទាល់ផ្ទាល់ខ្លួន ។

អំឡុងពេលសប្ដាហ៍នោះ ខ្ញុំបានគិតអំពីរបៀបដែលខ្ញុំពុំអាចរស់នៅដោយពឹងលើទីបន្ទាល់របស់ឪពុកម្ដាយខ្ញុំជារៀងរហូត និងរបៀបដែលខ្ញុំគួរតែព្យាយាមកាន់តែខ្លាំងឡើង ដើម្បីពង្រឹងទីបន្ទាល់របស់ខ្ញុំផ្ទាល់ ។ ចាប់តាំងពីនោះមក ខ្ញុំបានខិតខំក្រោកពីព្រលឹមរៀងរាល់សប្ដាហ៍ ដើម្បីខ្ញុំអាចទៅព្រះវិហារទាន់ម៉ោង ហើយទទួលទានសាក្រាម៉ង់ ។ ខ្ញុំកំពុងរៀនដើម្បីមានភាពខ្លួនទីពឹងខ្លួនខាងវិញ្ញាណ ។

*លីអា អាលវេស ទីក្រុងសេអារ៉ា ប្រទេសប្រេស៊ីល*



# ពីការទាត់ទៅជាការមានសន្ដានចិត្តល្អ

ខ្ញុំកំពុងឈរតម្រង់ជួរជាមួយម្ដាយខ្ញុំដើម្បីបង់ថ្លៃគ្រឿងទេសដែលយើងបានទិញ ។ ការតម្រង់ជួរឈរចាំនោះមានមនុស្សច្រើន ដូច្នេះម្ដាយខ្ញុំបានដើរចៀសក្មេងប្រុសតូចម្នាក់ដែលនៅពីមុនយើង ដើម្បីយើងទៅទិញទំនិញ ។ ក្មេងប្រុសតូចនោះបានចាប់ផ្ដើមទាត់ម្ដាយខ្ញុំ ។ លើកទីពីរដែលគាត់បានទាត់ម្ដាយខ្ញុំ នោះម្ដាយខ្ញុំបានងាកក្រោយ ហើយនិយាយ « សូមក្មួយកុំទាត់មីងទៀតបានទេ ? »

ម្ដាយរបស់ក្មេងប្រុសនោះបានងាកមក ហើយបានប្រាប់ម្ដាយខ្ញុំថា វាជាកំហុសរបស់ម្ដាយខ្ញុំទើបបានកូនគាត់ទាត់ម្ដាយខ្ញុំ ។ គាត់បាននិយាយពាក្យប្រែមើលងាយដល់ពួកយើង ។ ខ្ញុំបានចាប់ផ្ដើមសម្លឹងមើលទៅគាត់ទាំងខឹង ពេលគាត់ងាកក្រោយ ហើយមានភាពក្រអឺតក្រទមដាក់អ្នកគិតលុយផងដែរ ! ខ្ញុំបានធ្វើដូចជាត្រជាក់ចិត្តទេ ប៉ុន្តែក្នុងចិត្តខ្ញុំវិញគឺខឹងណាស់ ។ វាបានរំខានចិត្តខ្ញុំ ។ ខ្ញុំបានដឹងថា អ្វីដែលបានកើតឡើងពុំមែនជាកំហុសរបស់ម្ដាយខ្ញុំ ឬកំហុសខ្ញុំទេ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ឈឺចាប់ ។

នៅពេលយើងទៅដល់ផ្ទះ ខ្ញុំបានទៅក្នុងបន្ទប់ខ្ញុំ ហើយបានយកព្រះគម្ពីរខ្ញុំមកអាន ។ បន្ទាប់ពីអានបានមួយនាទីមក ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវតែអធិស្ឋាន ។ ខ្ញុំគ្មានអារម្មណ៍អធិស្ឋានទេ ប៉ុន្តែខ្ញុំបានលុតជង្គង់ចុះ ហើយចាប់ផ្ដើមអធិស្ឋាន ។ ទីបំផុត ខ្ញុំបានឃើញថា ខ្ញុំបានអធិស្ឋានអំពីស្ត្រីនោះ ដែលបានប្រព្រឹត្តអាក្រក់ដាក់យើង ។ អារម្មណ៍ស្ងប់សុខដ៏ខ្លាំង ដែលខ្ញុំធ្លាប់មានបានមានពេញក្នុងខ្លួនខ្ញុំ ។ ខ្ញុំគ្មានកំហឹងក្នុងចិត្តខ្ញុំចំពោះស្ត្រីនោះទៀតឡើយ ។ ខ្ញុំបានទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ ។

*តេរេសា ជី រដ្ឋវែរជាហ្វ ស.រ.អា.*



# « កុំឲ្យខ្លាចអ្វីឡើយ ពីព្រោះយើងនៅជាមួយ »

**ដោយអែលឌើរ ដាវីឌ អេ បែដណា**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

មានគ្រាមួយ អ្នកដឹកនាំកងទ័ពដ៏ល្បីល្បាញម្នាក់បានសង្កត់ធ្ងន់ថា ៖ « ចូរកុំទទួលការទូន្មាន [ ពី ]ការភ័យខ្លាចរបស់អ្នកឡើយ » ។[១]

ពេលយើងពិចារណាអំពីអ្វីៗ ដែលកំពុងកើតឡើងនៅជុំវិញយើងទាំងអស់គ្នាសព្វថ្ងៃនេះ យើងអាចឃើញហេតុផលជាច្រើនដើម្បីភ័យខ្លាច មានចិត្តស្ទាក់ស្ទើរ ហើយឆ្ងល់ថា តើអ្វីៗនៅក្នុងជីវិតយើងអាចកើតឡើងតាមក្ដីរំពឹងជាយូរដែលយើងប៉ងដែរឬទេ ។

អ្នកអាចមានសំណួរ ឬខ្វះទំនុកចិត្តលើសមត្ថភាពរបស់អ្នកដើម្បីទទួលជោគជ័យខាងសាច់ឈាម និងខាងវិញ្ញាណ ។ ប្រហែលអ្នកឆ្ងល់ថា តើការសន្យារបស់ព្រះអម្ចាស់អំពីការជួយជ្រោមជ្រែង និងការដឹកនាំ—ដែលអ្នកបានដឹង និងទទួលស្គាល់រួចទៅហើយនៅក្នុងជីវិតមនុស្សជាច្រើនផ្សេងទៀត—នឹងកើតឡើងក្នុងជីវិតរបស់អ្នកដែរឬទេ ។ អ្នកអាចពុំប្រាកដប្រជាអំពីការស្វែងរកឱកាសមួយ ដោយសារអ្នកពុំអាចមើលឃើញពីរឿងលម្អិតទាំងអស់អំពីរបៀបដែលកិច្ចការនានានឹងកើតឡើងនោះទេ ហេតុដូច្នោះហើយ អ្នកមានចិត្តស្ទាក់ស្ទើរក្នុងការចាប់ផ្ដើម ហើយដើរលើផ្លូវនោះ ។ ឬអ្នកប្រហែលជាខ្វាយខ្វល់អំពីការធ្វើកំហុសមួយដែលអ្នកមិនបានអនុវត្តតាមសេចក្ដីជំនឿ ហើយបន្តឈានទៅមុខ ហើយបង្កើននូវភាពដូចគ្នានៃបរាជ័យដែលអ្នកភ័យខ្លាច ។

ការមិនទទួលដំបូន្មានពីសេចក្ដីភ័យខ្លាចរបស់យើង វាមានន័យយ៉ាងសាមញ្ញថា យើងពុំអនុញ្ញាតឲ្យការភ័យខ្លាច និងភាពមិនប្រាកដប្រជាកំណត់ដំណើរជីវិតយើង ដែលជះឥទ្ធិពលអវិជ្ជមានដល់លក្ខណៈ និងឥរិយាបថរបស់យើង មានឥទ្ធិពលមិនល្អលើការសម្រេចចិត្តសំខាន់របស់យើង ឬបង្វៀង ឬបង្វែរយើងចេញពីអ្វីៗទាំងអស់ក្នុងពិភពលោកនេះដែលមានគុណធម៌ គួរឲ្យស្រឡាញ់ ឬអ្វីដែលល្អ ។ ការមិនទទួលដំបូន្មានពីការភ័យខ្លាចរបស់យើង មានន័យថា សេចក្ដីជំនឿទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ គ្រប់គ្រងលើការភ័ចខ្លាចយើង ហើយយើងឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងទ្រង់ ។ ការមិនទទួលដំបូន្មានពីការភ័យខ្លាចរបស់យើង មានន័យថា យើងទុកចិត្តលើការណែនាំ ការអះអាង និងពេលវេលារបស់ព្រះនៅក្នុងជីវិតរបស់យើង ។ ខ្ញុំសន្យាថា យើងម្នាក់ៗអាច ហើយនឹងមានពរជាមួយនឹងការដឹកនាំ ការការពារ និងអំណរយូរអង្វែង ពេលយើងរៀនដើម្បីមិនទទួលដំបូន្មានពីការភ័យខ្លាចរបស់យើង ។

ពេលយើងអនុវត្តសេចក្ដីជំនឿលើព្រះគ្រីស្ទ ហើយទុកចិត្តលើការសន្យារបស់ទ្រង់ នោះយើងអាចដើរទៅក្នុងភាពងងឹតជាមួយនឹងការធានាអះអាងយ៉ាងមុតមាំថា ផ្លូវរបស់យើងនឹងត្រូវបានបំភ្លឺ—យ៉ាងហោចណាស់គ្រប់គ្រាន់ល្មមដើម្បីចាប់ផ្ដើមជំហានបន្ទាប់—បន្ទាប់មកទៀតជំហានបន្ទាប់—ហើយជំហានបន្ទាប់ទៀត ។

យ៉ូសែប ស្ម៊ីធ បានប្រកាសថា « យើងគ្មានអ្វីត្រូវភ័យខ្លាចឡើយ ប្រសិនបើយើងមានចិត្តស្មោះត្រង់នោះ » ។[២]

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានទូន្មានថា ៖ « ចូរកុំខ្លាចឡើយ ។ ចូរមានចិត្តរីករាយ ។ អនាគតគឺភ្លឺត្រចះត្រចង់ដូចជាសេចក្ដីជំនឿរបស់បងប្អូនដែរ » ។[៣]

ពេលអ្នកប្រឈមមុខនឹងអនាគតអ្នកដោយសេចក្ដីជំនឿ នោះព្រះអង្គសង្គ្រោះនឹងយាងទៅពីមុខអ្នក នឹងនៅខាងស្ដាំដៃអ្នក ហើយខាងឆ្វេងដៃអ្នក ហើយព្រះវិញ្ញាណរបស់ទ្រង់នឹងសណ្ឋិតនៅក្នុងដួងចិត្តរបស់អ្នក ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៤:៨៨ ) នៅក្នុងកិច្ចខិតខំដ៏សុចរិតទាំងអស់របស់អ្នក និងពេញមួយជីវិតរបស់អ្នក ។ ■

**ដកស្រង់ចេញមកពីសុន្ទរកថាមួយដែលបានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់–រដ្ឋហាវ៉ៃ កាលពីថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១២ ។**

**កំណត់ចំណាំ**

១. នៅក្នុង Mary Anna Jackson, *Memoirs of Stonewall Jackson* ( ឆ្នាំ ១៨៩៥ ) ទំព័រ ២៦៤ ។
២. *The Personal Writings of Joseph Smith* ed. Dean C. Jessee បានធ្វើកំណែឡើងវិញ ( ឆ្នាំ ២០០២ ) ទំព័រ ៣៣៨ ។
៣. ថូម៉ាស អេ ម៉នសុន « Be of Good Cheer » សន្និសីទទូទៅខែ មេសា ឆ្នាំ ២០០៩ ។

វេទិកា និងក្បាល រចនារូបភាពដោយ អែនឌ្រូ រ៉ូប៊ើត

*កើតនៅ*

**ទីក្រុងសាន់លៀនដ្រូ រដ្ឋកាលីហ្វញ៉ា**

*នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥២*

*បានបម្រើ*

**បេសកកម្ម**

*នៅប្រទេសអាល្លឺម៉ង់ ភាគខាងត្បូង*

*បានបម្រើជាប្រធាន*

**ប៊ី.វ៉ាយ.យូ.–អៃដាហូ**

*ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០៤*

# អែលឌើរ ដេវីឌ អេ បែដណា



*បានរៀបអាពាហ៍ពិពាហ៍នឹង ស៊ូសាន រ៉ូប៊ីនសុន នៅឆ្នាំ ១៩៧៥ នៅ*

**ព្រះវិហារបរិសុទ្ធ សលត៍ លេក**

*កាលនៅតូច លោក*

**បានជួយ គ្រួសារ របស់លោក ធ្វើផ្លែឈើ កំប៉ុង ។**

*លោកបាននិយាយកំប្លែងថា ផ្លែឈើចូលក្នុងពោះលោកច្រើនជាងចូលនៅក្នុងក្រឡ ។*

*ធ្លាប់ជា*

**កីឡាករ វាយកូនបាល់**

*នៅក្នុងក្រុមបាល់ឱបក្នុងវិទ្យាល័យរបស់លោក*

*បានជួបភរិយារបស់លោកនៅការប្រកួតកីឡាបាល់ឱបមួយ ។*

**ភរិយាលោកបានធ្វើឲ្យ លោកកោតសរសើរ**

*ពេលភរិយាលោកចាប់បានបាល់ដែលលោកគប់បានយ៉ាងឆ្ងាយ ។*

*បញ្ចប់ការសិក្សាមកពី*

**សាកលវិទ្យាល័យព្រិកហាំ យ៉ង់**

**បានបញ្ចប់កម្រិតបណ្ឌិត**

*ផ្នែកវិជ្ជារៀបចំតវិយាបថពីសាកលវិទ្យាល័យភើរឌូ ។*

*ធ្លាប់ជា*

**សាស្ត្រាចារ្យ**

*នៅសាកលវិទ្យាល័យ តិចសាស តិក និង នៅសាកលវិទ្យាល័យ អាកានសាស ។*

មាន **កូនប្រុសបីនាក់**

*ទំនុកតម្កើងដែលលោកចូលចិត្ត*

**« ព្រះប្រោសលោះ នៃអ៊ីស្រាអែល »**

*( ទំនុកតម្កើង លេខ ៦ )*

*បានគាំទ្រជាសមាជិកក្នុង*

**កូរ៉ុមនៃពួកសាវក ដប់ពីរនាក់**

*នៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៤*



យុវមជ្ឈិមវ័យ

## គ្រោងរៀបចំក្រុមគ្រួសាររបស់អ្នកឬ ?

*ខែនេះ យុវមជ្ឈិមវ័យចែកចាយបទពិសោធន៍របស់ពួកគេក្នុងការប្រឈមមុខ និងយកឈ្នះលើការប្រឆាំងនឹងការមានកូន ។*

៤២

យុវវ័យ

## ការណែនាំស្ដីពីការដាក់គោលដៅ

៥២

មរណភាព និងការកើតទុក្ខ

## ការយល់ដឹងអំពីផែនការរបស់ព្រះ

៥៤

ព្រះគម្ពីរសញ្ញាថ្មី

## ជួបប្រជាជននៅកាលីឡេ

២៦, ៥៦

CAMBODIAN
4 02186 06258 0

សាសនាចក្រនៃ
**ព្រះយេស៊ូវគ្រីស្ទ**
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ប្រិយមិត្ត

ខែ មិថុនា ឆ្នាំ ២០១៩

វគ្គរបស់កុមារនៅក្នុងទស្សនាវដ្ដី *លីអាហូណា* ដែលបោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



សួស្ដីមកពី

**សាធារណរដ្ឋដូមីនីក !**

សូមមើលទំព័រ ៤៨–៤១១



# អំណរគុណចំពោះឪពុកម្ដាយ

ដោយប្រធាន
រ័សុល អិម ណិលសុន



តើអ្នកធ្លាប់រង់ចាំអ្វីមួយល្អឲ្យកើតឡើងដែរឬទេ ? តើមានអ្វីខ្លះដែលអាចជួយអ្នកបានអំឡុងពេលអ្នករង់ចាំនោះ ?

ជីដូនជីតាទួតខ្ញុំទាំងប្រាំបីនាក់បានចូលជាសមាជិកសាសនាចក្រនៅទ្វីបអឺរ៉ុប ។ ពួកលោកមានភាពស្មោះត្រង់នៅក្នុងសាសនាចក្រ ។ បន្ទាប់ពីនោះមក ជីដូនជីតាមួយចំនួនរបស់ខ្ញុំពុំបានបន្តរស់នៅតាមដំណឹងល្អទេ ។ ដោយសាររឿងនេះ ឪពុកម្ដាយខ្ញុំពុំបានទៅព្រះវិហារច្រើនទេ កាលខ្ញុំនៅតូច ។

ខ្ញុំស្រឡាញ់ឪពុកម្ដាយរបស់ខ្ញុំ ។ ពួកលោកបានបង្រៀនខ្ញុំនូវមេរៀនសំខាន់ៗជាច្រើន ។ ខ្ញុំពុំអាចថ្លែងអំណរគុណដល់ពួកលោកគ្រប់គ្រាន់ឡើយសម្រាប់ផ្ទះដ៏រីករាយរបស់យើង ។ ប៉ុន្តែតាំងពីក្មេងម្ល៉េះ ខ្ញុំបានដឹងថា ខ្ញុំកំពុងខ្វះអ្វីម៉្យាង ដោយសារគ្រួសារយើងពុំបានទៅព្រះវិហារច្រើនទេ ។ មានថ្ងៃមួយ ខ្ញុំបានជិះរថយន្តក្រុងមួយទៅបណ្ណាគារ ដើម្បីរកសៀវភៅមួយអំពីសាសនាចក្រ ។ ខ្ញុំចូលចិត្តការរៀនសូត្រអំពីដំណឹងល្អ ។

ពេលខ្ញុំបានរៀនអំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ខ្ញុំបានដឹងថា ឪពុកម្ដាយខ្ញុំពុំបានរស់នៅតាមរបៀបដែលច្បាប់នេះបង្រៀនយើងឲ្យរស់នៅតាមឡើយ ។ ប៉ុន្តែខ្ញុំចង់ឲ្យពួកលោករស់នៅតាមច្បាប់នេះ ! ដូច្នេះនៅថ្ងៃមួយ ខ្ញុំបានបំបែកគ្រប់ដបស្រានៅក្នុងផ្ទះរបស់ខ្ញុំនៅលើកម្រាលស៊ីម៉ង់ត៍ ។ ខ្ញុំបានគិតថា ឪពុកខ្ញុំនឹងដាក់ទោសខ្ញុំ ប៉ុន្តែគាត់មិនបាននិយាយអ្វីជាមួយខ្ញុំអំពីរឿងនោះទេ ។

ពេលខ្ញុំកាន់តែធំឡើង ខ្ញុំបានបន្តរៀនសូត្រអំពីដំណឹងល្អ ។ បានចាប់ផ្ដើមយល់ពីផែនការដ៏អស្ចារ្យរបស់ព្រះវរបិតាសួគ៌ ។ ខ្ញុំបានជ្រមុជទឹក កាលខ្ញុំមានអាយុ ១៦ ឆ្នាំ ។ ជារឿយៗ នៅពេលបុណ្យគ្រីស្ទម៉ាស់ ខ្ញុំនិយាយប្រាប់ខ្លួនឯងថា « ខ្ញុំមិនចង់បានអំណោយបុណ្យគ្រីស្ទម៉ាស់ទៀតទេ ! ខ្ញុំគ្រាន់តែចង់ផ្សារភ្ជាប់ជាមួយឪពុកម្ដាយខ្ញុំនៅក្នុងព្រះវិហារបរិសុទ្ធប៉ុណ្ណោះ » ។ ខ្ញុំបានរង់ចាំអស់ជាច្រើនឆ្នាំ ដើម្បីឲ្យសុបិននោះក្លាយជាការពិត ។ ទីបំផុត ពេលឪពុកម្ដាយខ្ញុំអាយុជាង ៨០ ឆ្នាំ ពួកយើងបានផ្សារភ្ជាប់ជាក្រុមគ្រួសារ ! ខ្ញុំមានអារម្មណ៍នៃអំណរដ៏ខ្លាំងនៅថ្ងៃនោះ ។ រៀងរាល់ថ្ងៃ ខ្ញុំនៅតែមានអារម្មណ៍រីករាយថាពួកលោកបានផ្សារភ្ជាប់ជាមួយគ្នា ហើយខ្ញុំបានផ្សារភ្ជាប់ជាមួយពួកលោក ។ ●

*កែសម្រួលមកពី « វិវរណៈសម្រាប់សាសនាចក្រ វិវរណៈសម្រាប់ជីវិតរបស់យើង » សន្និសីទទូទៅខែ មេសា ឆ្នាំ ២០១៨ ។*

# ទំព័រផាត់ពណ៌



« សូមបង្វើរដួងចិត្តរបស់
បងប្អូនទៅរកព្រះវរបិតាសួគ៌ ។
សូមងាកមករកទ្រង់ទូលសូមចម្លើយ
និងការលួងលោមចិត្ត »

**—ប្រធាន**
**រ័សុល អិម ណិលសុន ។**

រចនារូបភាពដោយ យ៉ាវេឌ បើកស្ត្រេន

# ជំពូកថ្មីមួយ

ដោយ ជេន ម៉ាកប្រាយដ៍
ផ្អែកទៅលើដំណើររឿងពិត

« *ពរជ័យជាច្រើនទាំងនេះបានធ្វើឲ្យខ្ញុំទទួលអារម្មណ៍មានអំណរគុណជាខ្លាំងដើម្បីក្លាយជាខ្លួនខ្ញុំ* » ( Children's Songbook *ទំព័រ ១១* ) ។



សារ៉ាបានបើកប្រអប់មួយពេលម្ដាយនាងបានដើរចូលមកក្នុងបន្ទប់ ។

នាងបានសួរម៉ាក់នាងថា « តើយើងអាចលាបជញ្ជាំងផ្ទះពណ៌លឿងបានទេ ? »

ពួកគេទើបតែប្ដូរមករស់នៅផ្ទះមួយផ្សេងទៀត ។ សារ៉ាអាចជ្រើសរើសភួយមានញាត់សំឡី និងវាំងននសម្រាប់បន្ទប់ថ្មីរបស់នាង !

ម្ដាយពោលថា « ម៉ាក់គិតថាអាចលាបបាន។ ពណ៌លឿងគឺជាពណ៌រីករាយ » ។

សារ៉ាបានដាក់សៀវភៅមួយចំនួននៅលើធ្នើរក្បែរគ្រែគេងរបស់នាង ។ ម៉ាក់នាងពុំមានអារម្មណ៍ *រីករាយ* ជានិច្ចទេមួយរយៈពេលក្រោយនេះ ចាប់តាំងពីប៉ារបស់នាងបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍មក ។ សារ៉ាបានដាក់រូបថតប៉ារបស់នាងដែលនាងចូលចិត្តដោយប្រុងប្រយ័ត្ននៅជាប់នឹងសៀវភៅនោះ ជាកន្លែងដែលនាងអាចឃើញរូបថតនោះរៀងរាល់ព្រឹកពេលនាងភ្ញាក់ពីគេង ។

នាងបានឮសំឡេងយំខ្សឹកខ្សួល ហើយបានឃើញទឹកភ្នែកនៅក្នុងភ្នែករបស់ម៉ាក់នាង ។

សារ៉ាបាននិយាយទាំងឱបចង្កេះម្ដាយនាងយ៉ាងណែនថា « កូនស្រឡាញ់ម៉ាក់ » ។

« ម៉ាក់ស្រឡាញ់កូនខ្លាំងណាស់ » ។

នៅថ្ងៃសៅរ៍ពីមុនចាប់ផ្ដើមចូលរៀន ម៉ាក់សារ៉ា និងសារ៉ាបានស្លៀកពាក់ខោអាវចាស់ៗ រំកិលគ្រឿងសង្ហារិមទៅកណ្ដាលបន្ទប់របស់សារ៉ា ហើយទាញរទ្បូលាបថ្នាំជញ្ជាំងនៅក្នុងថាសលាបថ្នាំពណ៌លឿងដោយប្រុងប្រយ័ត្ន ។ មួយសន្ទុះក្រោយមក ជញ្ជាំងបានលាបពណ៌លឿងរួច—ហើយមុខ និងខោអាវពួកគេក៏មានប្រឡាក់ថ្នាំផងដែរ !



ម៉ាក់នាងបាននិយាយទាំងសើចថា « មើលទៅកូន ដូចជាត្រូវពន្លឺព្រះអាទិត្យខ្វាតប្រទ្បាក់អញ្ចឹង » ។

សារ៉ាបានសើចកក្អឹក ។ « ហើយមើលទៅម៉ាក់ដូចជាមានចេកមួយដែលខ្វាតនៅជាប់ម៉ាក់អញ្ចឹង ! »

ពួកគេនៅតែសើច ពេលពួកគេសម្អាតខ្លួន ។ ប៉ុន្តែស្នាមញញឹមរបស់សារ៉ាបានរសាយបាត់ ពេលនាងបានគិតអំពីការទៅថ្នាក់អង្គការបឋមសិក្សានៅថ្ងៃស្អែក និងទៅរៀននៅថ្ងៃបន្ទាប់នោះ ។

នាងបានប្រាប់ម៉ាក់នាងពេលពួកគេលាងជក់លាបថ្នាំនៅកន្លែងលាងដៃ « កូនបារម្ភអំពីព្រះវិហារ និងសាលាថ្មីរបស់កូន ។ « កូនមិនស្គាល់គ្រូបង្រៀន ឬកុមារ ឬនរណាម្នាក់ទេ » ។

ម៉ាក់បានបិទទឹក ហើយទាញសារ៉ាឱប ។

« កូននឹងមានមិត្ត ។ កូនមានសន្ដានចិត្តល្អ នោះមនុស្សដទៃនឹងរាប់អានកូនហើយ ។ ចូរធ្វើខ្លួនជាក្មេងល្អបំផុត ហើយកូននឹងមានមិត្ត » ។

សារ៉ាមានអារម្មណ៍ល្អជាងមុន ប៉ុន្តែនាងនៅតែភ័យខ្លាច ។

នាងនិយាយថា « ខ្ញុំចង់ឲ្យប៉ានៅទីនេះ ដើម្បីផ្ដល់ការប្រសិទ្ធពរមួយដល់ខ្ញុំ ។ ដូចគាត់ធ្លាប់ធ្វើជានិច្ច ពីមុនខ្ញុំត្រឡប់ចូលរៀនវិញ » ។

ម៉ាក់បាននៅស្ងៀមមួយសន្ទុះ ។ គាត់បាននិយាយថា « ចុះលោកពូយ៉ាត់នោះ ? ម៉ាក់ប្រាកដចិត្តថា គាត់រីករាយនឹងផ្ដល់ការប្រសិទ្ធពរមួយដល់កូន » ។

សារ៉ាបានងក់ក្បាល ។ ប្រហែលជាការប្រសិទ្ធពរមួយអាចជួយបាន ។

នៅយប់នោះ ពូរបស់សារ៉ាបានដាក់ដៃគាត់លើក្បាលរបស់នាង ហើយផ្ដល់ការប្រសិទ្ធពរមួយឲ្យនាង ។

គាត់បាននិយាយថា « ពូសូមប្រសិទ្ធពរក្មួយឲ្យដឹងថា ព្រះអង្គសង្គ្រោះព្រះតម្រិះពីក្មួយ ពេលក្មួយចាប់ផ្ដើមជំពូកថ្មីនៅក្នុងជីវិតនេះ ។ ទ្រង់មិនចោលក្មួយឲ្យនៅកំព្រាទេ » ។

សារ៉ាបានផ្ដោតចិត្តទុកដាក់លើពាក្យ *ជំពូកថ្មី* ។ នាងចូលចិត្តអាន ហើយមានចិត្តរំភើបជានិច្ច ដើម្បីចាប់ផ្ដើមអានជំពូកថ្មីមួយក្នុងសៀវភៅ ។

នៅថ្ងៃបន្ទាប់សារ៉ា និងម៉ាក់បានទៅព្រះវិហារ ។ បន្ទាប់ពីការប្រជុំសាក្រាម៉ង់រួច ម្ដាយបានជួយសារ៉ាស្វែងរកបន្ទប់ថ្នាក់អង្គការបឋមសិក្សា ។ ក្មេងស្រីម្នាក់នៅក្នុងថ្នាក់បានញញឹមដាក់នាង ហើយបាននិយាយថាសួស្ដី ។

ក្មេងស្រីនោះនិយាយ ដោយគោះដៃលើកៅអីទទេនៅជាប់នឹងនាងថា « អ្នកអាចអង្គុយទីនេះបាន ប្រសិនបើអ្នកចង់ » ។

សារ៉ាបានពោលថា « អរគុណ ។ ខ្ញុំឈ្មោះសារ៉ា ។ ខ្ញុំជាអ្នកចំណូលថ្មីនៅទីនេះ » ។

« ខ្ញុំឈ្មោះមេឡូឌី ។ ខ្ញុំក៏ជាអ្នកចំណូលថ្មីដែរ ! នេះគឺជាសប្ដាហ៍ទីពីររបស់ខ្ញុំ » ។

មិនយូរប៉ុន្មានក្រោយមក មេឡូឌី និងសារ៉ាបាននិយាយជាមួយកុមារដទៃទៀតនៅថ្នាក់អង្គការបឋមសិក្សា ។ គ្រូបង្រៀនរបស់ពួកគេរីករាយរាក់ទាក់ណាស់ ។

« ខ្ញុំសង្ឃឹមថា សាលារៀនក៏មានសភាពល្អបែបនេះដែរ ! សារ៉ាបានគិតពេលនាងបានចូលគេងនៅយប់នោះ ។

នៅថ្ងៃបន្ទាប់ សារ៉ាបានជិះឡានក្រុងទៅសាលារៀនថ្មីរបស់នាង ។ នាងមានចិត្តរំភើបដើម្បីឃើញកុមារមួយចំនួនមកពីថ្នាក់បឋមសិក្សា រៀននៅថ្នាក់ទីបីជាមួយនាងដែរ ។

សារ៉ាបានអធិស្ឋានដោយស្ងាត់ៗ ពេលនាងញ៉ាំអាហារថ្ងៃត្រង់ជាមួយមិត្តថ្មីរបស់នាងថា « ឱព្រះវរបិតាសួគ៌អើយ សូមអរព្រះគុណទ្រង់ ។ នេះប្រហែលជាជំពូកល្អមួយនៃជីវិត បន្ទាប់ពីអ្វីៗទាំងអស់ » ។●

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។*

# អែលឌើរឃុកទៅទស្សនកិច្ចនៅប្រទេសប្រេស៊ីល





ពួកលោកបានទៅទស្សនាទីក្រុងធំនៅ បែឡូ ហូរីស្សុនតេ ។ ឈ្មោះទីក្រុងនោះមានន័យថា « ជើងមេឃដ៏ស្រស់ស្អាត » ។ អែលឌើរឃុកបានមានប្រសាសន៍ថា វាមានព្រះអាទិត្យលិចដ៏ស្រស់ស្អាតបំផុតដែលលោកធ្លាប់បានឃើញ !

អែលឌើរ ឃ្វីនថិន អិល ឃុក និងស៊ីស្ទើរ ម៉ារី ឃុក បាន ទៅទស្សនកិច្ចប្រទេសប្រេស៊ីល ដើម្បីសួរសុខទុក្ខសមាជិកសាសនាចក្រ ។ ពួកលោកបានបង្រៀន និងចែកចាយសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ ។





អែលឌើរ និងស៊ីស្ទើរឃុកបានទៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានចែកចាយពន្លឺរបស់ព្រះយេស៊ូវគ្រីស្ទរៀងរាល់ថ្ងៃ !





កុមារមានចិត្តរីករាយដែលបានជួបសាវករបស់ព្រះ !

# ធ្វើគោមភ្លើង



ពែងក្រដាស
ដែកចោះធ្វើរន្ធ ឬខ្ទៅដៃចុងស្រួច
ពិល ឬចង្កៀងភ្លើងពណ៌

១. សូមប្រើប្រដាប់ចោះធ្វើរន្ធ ឬខ្ទៅដៃដើម្បីចោះរន្ធនៅជុំវិញពែង ។ ចោះរន្ធនៅខាងបាតផងដែរ ឬកាត់វាចេញទាំងស្រុង ( សូមឲ្យមនុស្សពេញវ័យជួយ ) ។

២. តុបតែងពែងរបស់អ្នកតាមចិត្តចង់ ។ បន្ទាប់មក ដាក់ពន្លឺ ឬចង្កៀងភ្លើងពណ៌នៅក្រោមពែងនោះ ។

៣. សូមបិទភ្លើង ហើយមើលគោមភ្លើងរបស់អ្នកភ្លឺ !

**យោបល់គន្លឹះ ៖** ប្រសិនបើអ្នកគ្មានពែងក្រដាសទេនោះ អ្នកអាចមូរក្រដាសមួយ ហើយបិទស្កត់នៅជាយសងខាង ។

## មើលព្រះអាទិត្យអស្តង្គត

សូមចំណាយពេលមើល ហើយរីករាយនឹងព្រះអាទិត្យអស្តង្គតដូចអែលឌើរឃុកបានធ្វើ ។ សូមគូររូបភាពមួយអំពីព្រះអាទិត្យអស្តង្គតដែលអ្នកបានឃើញ ។ បន្ទាប់មក សូមគិតពីមិត្តរួមថ្នាក់ អ្នកជិតខាង ឬសមាជិកគ្រួសារដែលអាចត្រូវការមិត្តភក្តិ ។ សូមធ្វើឲ្យថ្ងៃរបស់ពួកគេរីករាយឡើងដោយចែកចាយរូបភាពរបស់អ្នក ។

តើអ្នកអាចក្លាយជាពន្លឺមួយនៅផ្ទះ នៅក្នុងសហគមន៍របស់អ្នកដោយរបៀបណា ?

# ការរង់ចាំអៀន

ដោយ យូស្វេ ជេ ផាកកឺ
ទស្សនាវដ្ដី សាសនាចក្រ
ផ្អែកទៅលើដំណើររឿងពិត



*អៀនបានសួរថា « តើមានអ្វីបានកើតឡើងចំពោះខ្ញុំ ? » ។*

« *យើងចូលចិត្តនៅក្នុងថ្នាក់អង្គការបឋមសិក្សា យើងរីករាយដែលអ្នកបានមកចូលរួមដែរ* » ( Children's Songbook *ទំព័រ ២៥៦* ) ។

ពេលអៀនភ្ញាក់ឡើង គាត់ឮម្ដាយគាត់ច្រៀង ។ វាគឺបទ « ខ្ញុំស្គាល់ក្ដីស្នេហ៍ព្រះអង្គ » ។ នោះគឺជាបទថ្នាក់អង្គការបឋមសិក្សាដែលអៀនចូលចិត្ត ! គាត់បានចាប់ផ្ដើមច្រៀងតាមម្ដាយគាត់ ។

ម្ដាយគាត់បាននិយាយថា « កូនដឹងខ្លួនហើយ ! » ម្ដាយគាត់ញញឹម ហើយយំ ។ អៀនបានឃើញប៉ារបស់គាត់នៅអង្គុយក្បែរម៉ាក់របស់គាត់ ។ មើលទៅគាត់ក៏សប្បាយចិត្តដែរ ។

ម៉ាក់បាននិយាយថា « ម៉ាក់បានច្រៀងចម្រៀងដែលកូនចូលចិត្តឲ្យកូនស្ដាប់រៀងរាល់ថ្ងៃ » ។

អៀនបានញញឹម—ប៉ុន្តែគាត់ឈឺក្បាល ។ តាមពិតទៅ គាត់ឈឺខ្លួនប្រាណទាំងមូល ជាពិសេសជើងរបស់គាត់ ។

គាត់បានមើលបរិវេណជុំវិញដោយយកចិត្តទុកដាក់ ។ គាត់មិននៅផ្ទះទេ ។ គាត់កំពុងដេកនៅលើគ្រែដែកក្នុងបន្ទប់ប្លែកមួយ ។ បន្ទាប់មកគាត់បានឃើញគិលានុបដ្ឋាយិកាម្នាក់ និងគ្រែជាច្រើននៅក្បែរនោះ ។ គាត់បានគិតថា « នេះច្បាស់ជាមន្ទីរពេទ្យហើយ » ។

គាត់បានសួរថា « តើមានអ្វីកើតឡើងចំពោះខ្ញុំ ? »

ទឹកមុខម៉ាក់បានប្រែជាមានទុក្ខ ។ « កូនបានជួបគ្រោះថ្នាក់អាក្រក់មួយ ។ ទ្វារដែកមួយបានរលំលើកូន ។ កូនបាននៅសម្រាកពេទ្យអស់ពីរសប្ដាហ៍ហើយ ប៉ុន្តែកូននឹងមិនកើតអ្វីទេ » ។

ពីរសប្ដាហ៍ ! អៀនបានគិតថា « អ៊ូ វាជាការដេកដ៏យូរមួយ » ។ រឿងចុងក្រោយដែលគាត់បានចាំនោះគឺ គាត់បាននៅអគារសាសនាចក្រ ហាត់សមកម្មវិធីសម្រាប់ថ្នាក់អង្គការបឋមសិក្សា ។ . . .

អ៊ូ អត់ទេ ! កម្មវិធី !

អៀនបានសួរ « តើខ្ញុំបានខកខានមិនបានចូលរួមកម្មវិធីថ្នាក់អង្គការបឋមសិក្សាឬ ? » គាត់បានទន្ទឹងរង់ចាំកម្មវិធីនោះអស់ពេលជាយូរមកហើយ ! គាត់ចូលចិត្តច្រៀងជាមួយមិត្តភក្តិរបស់គាត់ ។

ម៉ាក់បានញញឹម ហើយគ្រវីក្បាលរបស់គាត់ ។ « អត់ទេ កូនមិនបានខកខាននឹងកម្មវិធីនោះទេ ។ សមាជិកវួដបានសម្រេចចិត្តពន្យាកម្មវិធីនោះរហូតដល់កូនដឹងខ្លួនឡើងវិញ ដើម្បីកូនអាចចូលរួមកម្មវិធីនោះដែរ » ។

« ពិតមែនឬ ? »

ប៉ាបាននិយាយថា « ពិតមែនហើយ ។ កុមារនៅថ្នាក់អង្គការបឋមសិក្សាទាំងអស់បានសូមប៊ីស្សពឲ្យរង់ចាំសិន ។ ពួកគេចង់ឲ្យកូនទៅកម្មវិធីនោះដែរ ។ ពួកគេបានដឹងថា កូនរំភើបចិត្តខ្លាំងប៉ុណ្ណាចំពោះកម្មវិធីនេះក្នុងឆ្នាំនេះ » ។

អៀនមានចិត្តរីករាយដែលគាត់អាចនៅតែចូលរួមកម្មវិធីថ្នាក់អង្គការបឋមសិក្សា ។ ប៉ុន្តែគាត់ត្រូវតែបានធូរស្បើយជាមុនសិន ។ ហើយវាចំណាយពេលច្រើន ។ គាត់ត្រូវបន្តស្នាក់នៅមន្ទីរពេទ្យមួយរយៈពេលយូរទៀត ។ ទីបំផុតពេលគាត់ត្រឡប់ទៅផ្ទះវិញ គាត់នៅតែមិនអាចដើរ ឬលេងបាន ។

ប៉ុន្តែមិត្តភក្តិរបស់គាត់ត្រូវមកសួរសុខទុក្ខគាត់ ។ អៀនបានសួរពួកគេអំពី



សាលារៀន និងព្រះវិហារ ។ ហើយពួកគេបានសួរគាត់ថា តើពេលណាទើបគាត់អាចត្រឡប់មកវិញបាន ។

គាត់បានប្រាប់ពួកគេថា « ខ្ញុំមិនអាចទៅបានទេ រហូតដល់ជើងរបស់ខ្ញុំបានធូរស្បើយសិន ។ ខ្ញុំពុំទាន់ដើរបាននៅឡើយ » ។

ខែតុលាបានបន្តចូលទៅខែវិច្ឆិកា ហើយអៀនបានធូរស្បើយដោយសន្សឹមៗ ។ ថ្ងៃមួយ មិត្តភក្តិរបស់គាត់បានអញ្ជើញគាត់ឲ្យមក ហើយមើលរឿងជាមួយពួកគេ ។ ម៉ាក់ និងប៉ារបស់អៀនបានជួយយកគាត់ទៅទីនោះ ។

សេសជាមិត្តរបស់គាត់បានសួរគាត់ថា « តើជើងរបស់ឯងនៅតែឈឺទៀតឬ ? »

សេសបានសួរថា « បាទ ។ ប៉ុន្តែវាបានធូរស្បើយជារៀងរាល់ថ្ងៃ » ។

ម៉ារៀបានសួរថា « តើឯងអាចដើរបានហើយមែនទេ ? »

អៀនបានពោលថា « ខ្ញុំមិនដឹងទេ » ។

សេសបាននិយាយថា « អញ្ចឹងសាកល្បងមើល » ។ នាងបានជួយអៀនឲ្យក្រោកឈរ ។ អៀនបានដាក់ជើងរបស់គាត់ចុះក្រោមដោយប្រុងប្រយ័ត្ន ។ គាត់បានរំកិលខ្លួនគាត់ទៅមុខ ។ គាត់ឈរនៅស្ងៀមនៅឡើយ ! វាជាជំហានដំបូងរបស់គាត់ក្នុងរយៈពេលជាងមួយខែ ! មនុស្សគ្រប់គ្នាបានទះដៃ ។

សេសបាននិយាយថា « នេះមានន័យថា ឯងអាចត្រឡប់មកព្រះវិហារវិញហើយ ! »

ហើយនាងពិតជានិយាយត្រូវមែន ! នៅក្នុងរយៈពេលពីរបីសប្ដាហ៍ទៀត ទីបំផុតជើងរបស់អៀនបាត់ឈឺ ។ វេជ្ជបណ្ឌិតបានដកប៉ង់ស៊ីម៉ង់ត៍ពីជើងគាត់ចេញ ហើយដាក់រណបជំនួសវិញ ។ នៅពេលថ្ងៃអាទិត្យមកដល់ វាជាពេលសម្រាប់កម្មវិធីថ្នាក់អង្គការបឋមសិក្សា ។

អំឡុងពេលការប្រជុំសាក្រាម៉ង់ អៀនបានដើរទៅខាងមុខសាលាជំនុំជាមួយមិត្តរបស់គាត់ ។ គាត់បានក្រោកឈរយ៉ាងត្រង់ខ្លួន ហើយញញឹមដាក់ម៉ាក់ និងប៉ារបស់គាត់ ។ អំឡុងពេលច្រៀង គាត់បានច្រៀងឮៗតាមដែលគាត់អាចធ្វើបាន ។ ពេលដល់វេនរបស់គាត់ គាត់បានឈរនៅលើវេទិកា ហើយចែកចាយទីបន្ទាល់របស់គាត់ ។ គាត់មានអំណរគុណចំពោះមិត្តភក្តិថ្នាក់បឋមសិក្សារបស់គាត់ ។ ហើយគាត់រីករាយដែលគាត់អាចចូលរួមកម្មវិធីថ្នាក់អង្គការបឋមសិក្សា បន្ទាប់ពីអ្វីៗទាំងអស់បានកើតឡើង ។●

**ក្មេងប្រុសនៅក្នុងរឿងនេះរស់នៅសាធារណៈរដ្ឋដូមីនីក ។ សូមអានអត្ថបទបន្ទាប់ទៀតដើម្បីរៀនបន្ថែមអំពីប្រទេសនេះ !**

រូបភាពដោយ ម៉ីលា គ្រាម

# សួស្ដី មកពី សាធារណរដ្ឋដូមីនីក !









## សាធារណរដ្ឋដូមីនីក

សាធារណរដ្ឋដូមីនីកគឺនៅក្នុងប្រទេសការីបៀន ។ វាមានទីតាំងនៅលើកោះមួយជាមួយប្រទេសហៃទី ។ មានប្រជាជនប្រហែលជា ១០ លាននាក់រស់នៅសាធារណរដ្ឋដូមីនីក រួមមានសមាជិកសាសនាចក្រប្រែលជា ១៣០០០០ នាក់ ។

សាន់តូ ដូមីងហ្គូ




នៅក្នុងសាធារណរដ្ឋដូមីនីក ពួកគេនិយាយភាសាអេស្ប៉ាញ ។ នេះគឺជាក្មេងប្រុសម្នាក់ដែលមាន el Libro de Mormón—ព្រះគម្ពីរមរមន ។



កុមារជាច្រើននៅសាធារណរដ្ឋដូមីនីកចូលចិត្តលេងវាយកូនបាល់ ។ វាជាកីឡាដ៏មានប្រជាប្រិយបំផុតនៅក្នុងប្រទេសនេះ ។



ឆ្នាំមុនៗប្រធានណិលសុនបានទៅទស្សនកិច្ចសាធារណរដ្ឋដូមីនីក ហើយបានមានប្រសាសន៍ទៅកាន់មនុស្សជាភាសាអេស្ប៉ាញ ។




សាធារណរដ្ឋដូមីនីកមានព្រះវិហារបរិសុទ្ធមួយនៅ សាន់តូ ដូមីងហ្គោ ។ អក្សរនេះសរសេរថា «Santidad al Señor: La Casa del Señor » ។ វាមានន័យថា « បរិសុទ្ធដល់ព្រះយេហូវ៉ា ៖ ដំណាក់នៃព្រះអម្ចាស់ » ។



ប្រជាជននៅសាធារណរដ្ឋដូមីនីកបរិភោគបន្លែ និងផ្លែឈើត្រូពិចច្រើន ។ ក្មេងប្រុសទាំងនេះផឹកទឹកដូង !

## សូមជួបមិត្តភក្តិមួយចំនួនមកពីសាធារណរដ្ឋដូមីនីក !



« ខ្ញុំចូលចិត្តជួយកុមារតូចៗនៅក្នុងថ្នាក់អង្គការបឋមសិក្សា ពេលពួកគេមាត់រ៉ៅរ៉ៅ ។ ខ្ញុំសរសេរចម្រៀងនៅលើក្រដាសសៀវភៅ ហើយជួយពួកគេឲ្យច្រៀង ។ ខ្ញុំជួយពួកគេឲ្យយល់ ពេលយើងអានព្រះគម្ពីរ » ។

អាំបា អូ អាយុ ១១ ឆ្នាំ សាធារណរដ្ឋដូមីនីក



« ខ្ញុំស្រឡាញ់ព្រះយេស៊ូវ ហើយខ្ញុំមានអារម្មណ៍ខិតកាន់តែជិតទ្រង់ ។ ខ្ញុំក៏ចូលចិត្តទំនុកតម្កើង និងចម្រៀងថ្នាក់អង្គការបឋមសិក្សាផងដែរ » ។

អៀន អរ អាយុ ៨ ឆ្នាំ សាធារណរដ្ឋដូមីនីក

តើអ្នកមកពីសាធារណរដ្ឋដូមីនីកឬ ? សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។

សូមអរគុណចំពោះការមកទស្សនាសាធារណរដ្ឋដូមីនីកជាមួយពួកយើង ។ ឥឡូវនេះ យើងរៀបចំសម្រាប់ដំណើរផ្សងព្រេងបន្ទាប់ទៀតរបស់យើង !




រូបភាពទង់ជាតិ ដើមត្នោត និងក្មេងប្រុសលេងវាយកូនបាល់មកពី GETTY IMAGES រចនារូបភាពដោយ ខាធី ម៉ាក់ឌី

# ព្រះវិញ្ញាណប

ដោយ ម៉ារីស
ទស្សនាវដ្ដីស




**១. ជាសមាជិកមួយនៃក្រុមព្រះ ។** នោះមាន
និងព្រះយេស៊ូវគ្រីស្ទដើម្បីជួយយើង ។ ព
ដោយសារទ្រង់គ្មានព្រះកាយទេ ។

**២. អំណោយមួយដែលកើតមានជាមួយបុ**
អ្នកនឹងទទួលការប្រសិទ្ធពរពិសេសមួយ
ត្រូវបានអញ្ជើញឲ្យទទួលព្រះវិញ្ញាណបរិ

**៣. ការសន្យាមួយមកពីព្រះវរបិតាសួគ៌ ។**
ថាបន្តធ្វើតាមព្រះយេស៊ូវ ។ ត្រឡប់មកវិ
បរិសុទ្ធនឹងគង់នៅជាមួយអ្នក ។






# ...ិសុទ្ធគឺជា . . .

...ប្បា វ៉ែដឌីសុន
...សាសនាចក្រ

...ន័យថា ទ្រង់ធ្វើការជាមួយព្រះវរបិតាសួគ៌ ...ជួនកាលគេហៅទ្រង់ថា ព្រះវិញ្ញាណ

**...ល្យជ្រមុជទឹក ។** បន្ទាប់ពីងើបចេញពីទឹកមក ...ហៅថា « ការបញ្ជាក់ » ជាពេលដែលអ្នក ...សុទ្ធ ។

...នៅពេលអ្នកទទួលទានសាក្រាម៉ង់ អ្នកសន្យា ...ញ ព្រះវរបិតាសួគ៌សន្យាថា ព្រះវិញ្ញាណ

ដូចជា **សារទូត** ពីព្រះវរបិតាសួគ៌ ។ ព្រះវិញ្ញាណបរិសុទ្ធ អាចជួយអ្នកឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់ និង ការយល់ដឹងរបស់ព្រះ នូវអ្វីដែលទ្រង់សព្វព្រះទ័យឲ្យអ្នកដឹង ។





ដូចជា **ទីសម្គាល់** ជួយអ្នក ដឹងពីកន្លែងដែលត្រូវទៅ ។ ពេលអ្នកធ្វើការជ្រើសរើស នោះ ទ្រង់អាចជួយអ្នកបន្តលើផ្លូវ ទៅកាន់ជីវិតអស់កល្បជានិច្ច ។



ដូចជា **កល្យាណមិត្ត** ដែលចង់នៅជាមួយអ្នក ជានិច្ច ! តាមរយៈការធ្វើការជ្រើសរើសត្រឹមត្រូវ នោះ អ្នកយាងអញ្ជើញទ្រង់ឲ្យបន្តគង់នៅជាមួយអ្នក ។

**នៅក្នុងព្រះគម្ពីរ ៖**
យ៉ូហាន ១៤:២៦
កាឡាទី ៥:២២
នីហ្វៃទី ២ ៣១:១៧–១៨
គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០:២២

រូបភាពដោយ ខេធី ព្រូវស៊ីល



ដោយ បេកឃី ក្រាវិន
ទីប្រឹក្សាទីពីរក្នុងគណៈប្រធាន
យុវនារីទូទៅ

# ការរស់នៅតាមបទដ្ឋានរបស់ខ្ញុំ

*« ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល » ( ម៉ូសាយ ១៨:៩ ) ។*

ឪពុករបស់ខ្ញុំបាននៅក្នុងជួរកងទ័ព ដូច្នេះយើងបានប្តូរទីលំនៅច្រើនដង កាលខ្ញុំនៅក្មេង ។ រឿងមួយដ៏លំបាកបំផុតអំពីការប្តូរទីលំនៅនោះគឺ ការចេញពីមិត្តភក្តិរបស់ខ្ញុំ ។ ខ្ញុំមានការលំបាកក្នុងការរាប់អានមិត្តភក្តិថ្មី ដោយសារខ្ញុំអៀនខ្មាស ។ ដោយអំណរគុណ មនុស្សមានភាពរួសរាយជានិច្ចទាំងនៅសាលារៀន និងនៅថ្នាក់អង្គការបឋមសិក្សា ។



នៅព្រះវិហារវាមិនជាបញ្ហាអ្វីនោះទេ ទោះបីយើងមានភាពខុសប្លែកគ្នាប៉ុណ្ណាក្តី ។ យើងទាំងអស់គ្នាគឺជាមិត្តភក្តិនឹងគ្នា ។

របៀបមួយដែលខ្ញុំយកឈ្នះលើភាពអៀនខ្មាសរបស់ខ្ញុំគឺជួយកិច្ចការនៅព្រះវិហារ ។ ខ្ញុំបានចាប់ផ្តើមជាមួយថ្នាក់អង្គការបឋមសិក្សា ។ ខ្ញុំបានចែកចាយខគម្ពីរមួយនៅម៉ោងពេលវេលាចែកចាយ ។ ខ្ញុំបានអានខគម្ពីរនោះឮៗនៅក្នុងថ្នាក់ ។ បន្តិចម្តងៗ ខ្ញុំមានអារម្មណ៍ថា មានទំនុកចិត្តកាន់តែច្រើន ។ វាបានជួយខ្ញុំឈររឹងប៉ឹងចំពោះជំនឿរបស់ខ្ញុំ ។

កាលខ្ញុំរៀនថ្នាក់ទីបួន ឬទីប្រាំ គ្រួសារខ្ញុំបានរស់នៅរដ្ឋម៉ារីលែន ស.រ.អា. ។ គ្មានសមាជិកសាសនាចក្រច្រើននៅសាលាខ្ញុំទេ ។ ខ្ញុំមានមិត្តភក្តិដែលជាសមាជិកសាសនាចក្រ និងមិនមែនជាសមាជិកសាសនាចក្រ ។

កាលនៅវ័យជំទង់ មិត្តភក្តិមួយចំនួនរបស់ខ្ញុំបានធ្វើរឿងដែលផ្ទុយពីបទដ្ឋានរបស់ខ្ញុំ ។ ប៉ុន្តែពួកគេពុំបានព្យាយាមឲ្យខ្ញុំធ្វើរឿងទាំងនោះទេ ។ ខ្ញុំមានអំណរគុណដែលមិត្តភក្តិរបស់ខ្ញុំបានគោរពសេចក្តីជំនឿរបស់ខ្ញុំ ។ ជួនកាលខ្ញុំមានអារម្មណ៍ថាឯកោ ដោយសារខ្ញុំពុំអាចធ្វើអ្វីគ្រប់យ៉ាង ដែលមិត្តភក្តិនៅសាលារបស់ខ្ញុំធ្វើបានទេ ។ ប៉ុន្តែ ខ្ញុំមានអារម្មណ៍ល្អពីការធ្វើតាមបទដ្ឋានរបស់ខ្ញុំជានិច្ច ។ ខ្ញុំបានសម្រេចចិត្តថា ខ្ញុំចង់រស់នៅតាមដំណឹងល្អ មិនថាមានអ្វីកើតឡើងនោះទេ ។ ទីបន្ទាល់របស់ខ្ញុំបានរឹងមាំឡើងនៅក្នុងថ្នាក់អង្គការបឋមសិក្សា និងរាត្រីជួបជុំក្រុមគ្រួសារ ។ ខ្ញុំបានដឹងច្បាស់ថា ខ្ញុំជាកូនរបស់ព្រះ ។

ជាច្រើនឆ្នាំក្រោយមក ខ្ញុំបានដឹងថា មិត្តភក្តិពីរនាក់នៅសាលារៀនរបស់ខ្ញុំបានចូលជាសមាជិកសាសនាចក្រ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ! ពួកគេបានប្រាប់ខ្ញុំថា ការមើលខ្ញុំរស់នៅតាមដំណឹងល្អ កាលពីពួកគេនៅតូចបានជួយពួកគេសម្រេចចិត្តស្តាប់ពួកអ្នកផ្សព្វផ្សាយសាសនា ។

មិត្តវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំអើយ ក្មួយៗគឺជាបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌របស់យើង ។ ពេលក្មួយៗចងចាំអំពីសេចក្តីពិតដ៏សំខាន់នេះ *រៀងរាល់ថ្ងៃ* នោះការរស់នៅតាមដំណឹងល្អរបស់ក្មួយៗនឹងកាន់តែងាយស្រួល ។●

រចនារូបភាពដោយ ស៊ើហ្សា អាប៊ីប៊ី

ខ្ញុំអាច មានសន្តានចិត្តល្អ ។

ខ្ញុំអាច
ស្ដាប់ តាម
ព្រះវិញ្ញាណ
បរិសុទ្ធ ។

ខ្ញុំអាចធ្វើកិច្ចការនានា
នៅថ្ងៃឈប់សម្រាក
ដែលជួយខ្ញុំចងចាំ
ព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំអាចបង្ហាញ
**ការគោរព**
ចំពោះព្រះ មនុស្សដទៃ
និងខ្លួនខ្ញុំ ។

ខ្ញុំអាច
ស្លៀកពាក់
ហើយប្រព្រឹត្ត
**សមរម្យ** ។

ខ្ញុំអាច ប្រែចិត្ត ហើយសាកល្បង
ម្ដងទៀត ពេលខ្ញុំធ្វើខុស ។



ខ្ញុំអាចធ្វើជា
**មនុស្សស្មោះត្រង់** ។

# ខ្ញុំអាចជ្រើសរើសត្រូវ

ខ្ញុំអាច
និយាយ
ពីព្រះ
*ដោយគារវភាព* ។

ខ្ញុំអាចប្រើ
**ពាក្យល្អៗ** ។

ខ្ញុំអាចរៀបចំខ្លួនពីឥឡូវនេះដើម្បីទៅព្រះវិហារបរិសុទ្ធ ។

ខ្ញុំអាចរកមើល
**មិត្តល្អៗ** ។

ខ្ញុំអាចរក្សាគំនិត
និងរូបកាយខ្ញុំ
**ឲ្យមានសុខភាពល្អ** ។

រូបភាពលម្អិតមកពី *ព្រះគ្រីស្ទ និងកម្លោះអ្នកមាន* ដោយ ហែនរិច ហូហ្វម៉ាន់

ខ្ញុំអាច **គោរព**
ឪពុកម្ដាយខ្ញុំ ហើយ
**ជួយ** គ្រួសារខ្ញុំ ។

ខ្ញុំអាចអាន មើល
ហើយស្ដាប់អ្វីដែលល្អៗ ។

# ព្រះយេស៊ូវស្រឡាញ់ខ្ញុំ ។ ខ្ញុំអាចរៀន ធ្វើតាមទ្រង់បន្តិចម្ដងៗ ។



គំនូរដោយ ប៊ែន ស៊ីម៉ុនសិន

# កម្មវិធីបង្ហាញ ហើយនិទានប្រាប់



ខ្ញុំលេងជាមួយមិត្តរបស់ខ្ញុំដែលឯកោ ។

អាឡិចសិស អេច អាយុ ៧ ឆ្នាំ ទីក្រុង ណូវ៉ា ស្កូទីអា ប្រទេសកាណាដា



ខ្ញុំទន្ទឹងចាំទទួលបព្វជិតភាព និងទៅព្រះវិហារបរិសុទ្ធ ដើម្បីធ្វើបុណ្យជ្រមុជទឹកសម្រាប់ឈ្មោះគ្រួសារខ្ញុំ ដែលម្ដាយខ្ញុំ និងខ្ញុំបានរកឃើញ !

ប្រ៊ីងហាំ ដបុលយូ អាយុ ១១ ឆ្នាំ ទីក្រុង វីក្តូរីយ៉ា ប្រទេសអូស្ត្រាលី



ខ្ញុំចូលចិត្តការរៀនពីព្រះយេស៊ូវ ។ ខ្ញុំមានអំណរគុណចំពោះការលះបង់ដែលទ្រង់បានធ្វើសម្រាប់យើង ។

សារ៉ា ឌី អាយុ ៦ ឆ្នាំ រីអូ ហ្គ្រង់ឌី ដូ សុល ប្រទេសប្រេស៊ីល



ហ្វីលីព ដបុលយូ អាយុ ៨ ឆ្នាំ ទីក្រុង ឡានកាសៀ្ស ប្រទេសអង់គ្លេស



នៅសាលារៀនរបស់ខ្ញុំ ខ្ញុំបានឃើញសំរាមនៅលើកន្លែងលេងកម្សាន្ត ។ ដូច្នេះខ្ញុំបានសួរនាយកសាលាប្រសិនបើខ្ញុំអាចរើសសំរាមនោះជាមួយមិត្តភក្ដិខ្ញុំ ។ ខ្ញុំសប្បាយចិត្តដែលខ្ញុំធ្វើជាពលរដ្ឋល្អ ។

អែលលៀ ឌី អាយុ ១០ ឆ្នាំ ទីក្រុង បាដិន វើធេមបើក ប្រទេសអាល្លឺម៉ង់



ខ្ញុំជួយម្ដាយខ្ញុំមើលប្អូនប្រុសតូចៗរបស់ខ្ញុំ ។

សាម៉ាថា អេស អាយុ ៨ ឆ្នាំ ទីក្រុងបើរឡាំង ប្រទេសអាល្លឺម៉ង់





ហ្វើរ៉ានមី អេហ្វ អាយុ ៨ ឆ្នាំ ទីក្រុងឡាហ្គោស ប្រទេសនីហ្សេរីយ៉ា

លំនាំចំណងជើងផ្ទៃខាងក្រោយមកពី GETTY IMAGES


និយាយ
សួស្ដីទៅកាន់
ហាលីម !



**យើងអាចមានសន្តានចិត្តល្អ**

« យើងម្នាក់ៗអាចអភិវឌ្ឍភាពរាប់អានគ្នាជាបងប្អូននៅផ្ទះ សាលារៀន កន្លែងធ្វើការ ឬនៅកន្លែងលេងកម្សាន្ត » ។

ប្រធាន រ័សុល អិម ណិលសុន « These . . . Were Our Examples » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៦២ ។

**ដោយ ខាធី ខាធី រ៉ីដ័យ**
ផ្អែកទៅលើដំណើររឿងពិត

*« អ្នករាល់គ្នាបានទទួលទទេ ត្រូវឲ្យទទេដែរ » ( ម៉ាថាយ ១០:៨ ) ។*

នៅសាលារៀននាព្រឹកនោះ ម៉ាគើសបានសង្កេតឃើញក្មេងប្រុសចំណូលថ្មីម្នាក់ដើរចូលមកក្នុងថ្នាក់រៀន ។

អ្នកគ្រូប៉ៃកឃើរបាននិយាយពេលសិស្សគ្រប់គ្នាស្ងាត់ស្ងៀមថា « អរុណសួស្តីប្អូនៗ ។ នេះគឺហាលីម ។ គាត់ជាអ្នកចំណូលថ្មីនៅសាលារៀនយើង ។ តាមពិតទៅ គាត់ជាអ្នកចំណូលថ្មីមកក្នុងប្រទេសយើង ។

ហាលីមបានឱនមុខមើលកម្រាលឥដ្ឋពេលគាត់និយាយថាសួស្តី ។ ម៉ាគើសបានគិតថា សំឡេងរបស់គាត់ដូចជាមានសំឡេងខុសប្លែក ។ អ្នកគ្រូប៉ៃកឃើរបន្តនិយាយទៀត ។

« ពួកយើងរីករាយដែលគាត់នៅទីនោះ ហើយគាត់នឹងក្លាយជាសិស្សក្នុងថ្នាក់យើង ។ អ្នកគ្រូសង្ឃឹមថា យើងទាំងអស់គ្នាជួយឲ្យគាត់មានអារម្មណ៍កក់ក្ដៅ » ។

ពេលអ្នកគ្រូប៉ៃកឃើរបង្ហាញតុអង្គុយឲ្យហាលីម ម៉ាគើសបានគិតអំពីការភ័យខ្លាចរបស់គាត់ ប្រសិនបើគាត់បានប្ដូរទៅប្រទេសថ្មីមួយ និងសាលារៀនថ្មីមួយ ។

បន្ទាប់ពីម៉ោងញ៉ាំអាហារសម្រន់រួច អ្នកគ្រូប៉ៃកឃើរបានប្រាប់សិស្សគ្រប់គ្នាថា គាត់មានអ្វីមួយភ្ញាក់ផ្អើលបង្ហាញពួកគេ ។ ម៉ាគើសបានអង្គុយយ៉ាងត្រង់ខ្លួន ដើម្បីគាត់អាចមើលឃើញអ្វីដែលអ្នកគ្រូដកចេញពីកាបូបរបស់គាត់ ។ វាជាធុងតូចៗ ។ គាត់បានចាប់ផ្ដើមហុចធុងនោះតៗគ្នាទៅសិស្សក្នុងថ្នាក់ ។

គាត់បាននិយាយពេលគាត់ហុចធុងពណ៌លឿងឲ្យម៉ាគើស « យើងម្នាក់ៗមានធុងនៃក្ដីស្រមៃមួយនៅក្នុងចិត្តយើងម្នាក់ៗ ។ មនុស្សបំពេញធុងរបស់យើងពេលពួកគេធ្វើរឿងល្អៗដល់យើង ។ ហើយយើងអាចបំពេញធុងរបស់មនុស្សដទៃតាមរយៈការធ្វើល្អចំពោះពួកគេដែរ ។ ឧទាហរណ៍ ពេលម្ដាយប្អូនឱបប្អូន គាត់កំពុងបំពេញធុងរបស់ប្អូន ។ ពេលប្អូនៗនិយាយអ្វីមួយល្អៗទៅកាន់នរណាម្នាក់ នោះប្អូនៗកំពុងបំពេញធុងរបស់ពួកគេ ។

ម៉ាគើសបានមើលទៅមិត្តជិតស្និទរបស់គាត់ឈ្មោះកាលីប ។ គាត់ក៏បានធុងពណ៌លឿងផងដែរ !

អ្នកគ្រូប៉ៃកឃើរបាននិយាយថា « សប្ដាហ៍នេះ យើងនឹងទុកធុងទាំងនេះនៅលើតុរបស់យើង ដូច្នេះយើងអាចសរសេរកំណត់ចំណាំល្អៗសម្រាប់គ្នាទៅវិញទៅមក » ។ គាត់បានមូរក្រដាសតូចមួយ ហើយទម្លាក់វាចូលក្នុងធុងនោះ ។ « ហើយវានឹងជួយយើងឲ្យចងចាំពីធុងនៃក្ដីស្រមៃ ដែលមនុស្សគ្រប់គ្នាមាននៅក្នុងធុងនោះ ។ យើងចង់មានសន្តានចិត្តល្អ ដើម្បីឲ្យយើងធ្វើជាអ្នកបំពេញធុងនោះ ។

ម៉ាគើសបានទាញយកក្រដាសមួយសន្លឹកមក ហើយបានគិតអំពីអ្វីៗដែលគាត់អាចសរសេរទៅកាន់កាលីប ដូចជាថាគាត់ពូកែលេងកីឡា ។ ប៉ុន្តែក្រោយមកគាត់បានមើលទៅហាលីម ។ ស្មារបស់គាត់ហាក់ដូចកោងដោយកើតទុក្ខ ។

ម៉ាគើសឆ្ងល់ថា តើហាលីមមានកល្យាណមិត្តម្នាក់ នៅកន្លែងដែលគាត់ធ្លាប់រស់នៅដែរឬទេ ។ វាប្រហែលជាលំបាកណាស់ដើម្បីនិយាយលាពួកគេ ហើយភ័យខ្លាចចំពោះការប្ដូរទៅរស់នៅឆ្ងាយ ។

ម៉ាគើសបានមើលទៅក្រដាសសៀវភៅទទេនៅលើតុរបស់គាត់ ។ គាត់មានគំនិតមួយ បន្ទាប់មកគាត់បានសរសេរថា

« ជូនចំពោះហាលីម

សូមស្វាគមន៍មកសាលារៀនរបស់យើង ។ ប្រសិនបើឯងចង់ យើងអាចលេងជាមួយគ្នាពេលម៉ោងចេញលេង ។ ខ្ញុំនឹងធ្វើជាមិត្តភក្តិរបស់ឯង ។ ហើយខ្ញុំគិតថា កាលីបនឹងធ្វើជាមិត្តរបស់ឯងដែរ ។

ពីខ្ញុំ ម៉ាគើស » ។

បន្ទាប់មកគាត់បានមូរក្រដាសនោះដោយប្រុងប្រយ័ត្ន ហើយទម្លាក់វាចូលក្នុងធុងរបស់ហាលីម ។ ហាលីមបានញញឹម ។ ម៉ាគើសបានទទួលអារម្មណ៍កក់ក្ដៅ និងរីករាយក្នុងចិត្ត ។ គាត់ចូលចិត្តធ្វើជាអ្នកបំពេញធុង ! ●

*អ្នកនិពន្ធរស់នៅរដ្ឋ អ៊ែដាហូ ស.រ.អា ។*





# ព្រះយេស៊ូវបាន បង្រៀនអំពីសាក្រាម៉ង់



ពីមុនព្រះយេស៊ូសុគត ទ្រង់បានសោយអាហារពិសេសមួយជាមួយពួកសិស្សរបស់ទ្រង់ ។
គេហៅវាថាអាហារយប់ថ្ងៃចុងក្រោយ ។

ព្រះយេស៊ូវគ្រីស្ទបានយកនំប៉័ង ហើយប្រទានពរវា ។ ព្រះយេស៊ូវបានប្រទានវាឲ្យទៅពួកសិស្សរបស់ទ្រង់ ។ ទ្រង់បានឲ្យពួកលោកបរិភោគវា ដើម្បីជួយពួកលោកឲ្យចងចាំទ្រង់ ។





ព្រះយេស៊ូវគ្រីស្ទបានយកពែងមួយ ហើយប្រទានវាឲ្យទៅពួកសិស្សរបស់ទ្រង់ ។ ទ្រង់បានឲ្យពួកលោកផឹកវា ដើម្បីជួយពួកលោកឲ្យចងចាំទ្រង់ ។

ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ក៏បានច្រៀងទំនុកតម្កើងមួយផងដែរ ។



រចនារូបភាពដោយ អាលែន ស្មិត



ខ្ញុំអាចចងចាំព្រះយេស៊ូវ តាមរយៈការទទួលទានសាក្រាម៉ង់រៀងរាល់សប្ដាហ៍
ដូចទ្រង់បានសុំឲ្យពួកយើងធ្វើ ។ ●

*សូមអានអ្វីដែលព្រះយេស៊ូវបានបង្រៀននៅក្នុង*
*ម៉ាថាយ ២៦:២៦–២៨; កូរិនថូសទី ១ ១១:២៤–២៥ ។*

# ព្រះយេស៊ូវគ្រីស្ទបានប្រទានសាក្រាម៉ង់ដល់ពួកយើង



សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះមាតាបិតា

**ក្រុមគ្រួសារជាច្រើន** គ្មានឪពុក និងម្ដាយដែលបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ប្រធាន វ៉េសុល អិម ណិលសុន បានចម្រើនវ័យធំឡើងនៅក្នុងគ្រួសារមួយដែលមានស្ថានភាពដូចនោះ ។ មិនថាអ្នកមានស្ថានភាពគ្រួសារបែបណានោះទេ យើងអាចបង្រៀនកូនៗរបស់យើងឲ្យទន្ទឹងរង់ចាំពរជ័យដ៏មហិមានៃព្រះវិហារបរិសុទ្ធ ។ ហើយយើងអាចជួយពួកគេឲ្យធ្វើកិច្ចការពង្សប្រវត្តិ ដើម្បីឲ្យជីដូនជីតាយើងអាចមានពរជ័យទាំងនោះផងដែរ ។ អ្នកអាចអាននៅ ទំព័រ ខ២ អំពីរបៀបដែលប្រធានណិលសិនរង់ចាំឲ្យគ្រួសាររបស់លោក បានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

សូមសរសេរសំបុត្រមកពួកយើង អំពីរបៀបដែលគ្រួសារអ្នកបានប្រើប្រាស់រឿង និងសកម្មភាពនានានៅក្នុងទស្សនាវដ្ដី *ប្រិយមិត្ត* ក្នុងខែនេះ ។

ដោយក្ដីស្រឡាញ់
ទស្សនាវដ្ដី *ប្រិយមិត្ត*

បន្ថែម ប្រសិនបើអ្នកគ្មានកូននៅផ្ទះ សូមគិតពីការចែកទស្សនាវដ្ដី *ប្រិយមិត្ត* ជាមួយអ្នកដែលមានកូន ។

New *Friend*
50 E. North Temple St.,
Room 2393
Salt Lake City, UT 84150 USA
liahona@ldschurch.org



សូមស្វែងរករូបលីអាហូណាដែលលាក់នៅខាងក្នុង !

## មាតិកា

ខ២ សារលិខិតគណៈប្រធានទីមួយ ៖ អំណរគុណចំពោះឪពុកម្ដាយ
ខ៤ ជំពូកថ្មីមួយ
ខ៦ ពួកសាវកនៅជុំវិញពិភពលោក ៖ អែលឌើរឃុកទៅទស្សនកិច្ចនៅប្រទេសប្រេស៊ីល
ខ៨ ការរង់ចាំអៀន
ខ១០ សួស្ដីមកពីសាធារណរដ្ឋដូមីនីក !
ខ១២ ព្រះវិញ្ញាណបរិសុទ្ធគឺជា . . .
ខ១៤ ការរស់នៅតាមបទដ្ឋានរបស់ខ្ញុំ
ខ១៥ ខ្ញុំអាចជ្រើសរើសត្រូវ
ខ១៦ ប័ណ្ណប្រកាសស្ដីពីគំនិតឆ្លាតវៃ ៖ ព្រះយេស៊ូវស្រឡាញ់ខ្ញុំ
ខ១៧ កម្មវិធីបង្ហាញ ហើយនិទានប្រាប់
ខ១៨ និយាយសួស្ដីទៅកាន់ហាលីម !
ខ២០ រឿងក្នុងព្រះគម្ពីរ ៖ ព្រះយេស៊ូវបានបង្រៀនអំពីសាក្រាម៉ង់
ខ២៣ ទំព័រផាត់ពណ៌ ៖ ព្រះយេស៊ូវគ្រីស្ទបានប្រទានសាក្រាម៉ង់ដល់ពួកយើង

នៅលើក្របទស្សនាវដ្ដី *ប្រិយមិត្ត*
រចនារូបភាពដោយ ស្ទេន ខ្លូស្ទើរ

© ២០១៥ BY INTELLECTUAL RESERVE, INC. ALL RIGHTS RESERVED

CAMBODIAN
4 02186 06258 0